# ថ្ងៃទី០២ ខែ កុម្ភៈ ឆ្នាំ២០២៣

## កម្ពុជា-ថៃ បន្តកិច្ចសហការទប់ស្កាត់ និងបង្ក្រាបអំពើជួញ ដូរមនុស្សឆ្លងដែន

https://dap-news.com/national/2023/02/01/309407/ ByPH104Posted on February 1, 2023

ភ្នំពេញ ៖ សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង លោក Chardkiat ATTHAKOR ឯកអគ្គរាជទូតថៃ ប្រចាំកម្ពុជា ទើបតែងតាំងថ្មី បានប្តេជ្ញារួមគ្នាបន្តកិច្ចសហការទប់ស្កាត់ និងបង្ក្រាបនូវអំពើជួញដូរ មនុស្សឆ្លងដែន។

ក្នុងជំនួបពិភាក្សាការងារជាមួយ សម្តេច ស ខេង នាថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣ លោក Chardkiat ATTHAKOR បានកោតសរសើរ ចំពោះក្រសួងមហាផ្ទៃ កម្ពុជា ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសបទល្មើសឆបោក តាមប្រព័ន្ធទូរគមនាគមន៍ ដូចជា ការរត់ពន្ធមនុស្សឆ្លងដែន ដែលក្នុងរយៈពេលកន្លងទៅនេះ បានទទួលនូវលទ្ធផល គួរឱ្យកត់សម្គាល់ ។ លោក បន្តថា បញ្ហានេះ គឺជាបញ្ហាសម្រាប់តំបន់ ដែលត្រូវសហការគ្នា ដោះស្រាយ មិនមែនតែជាបញ្ហា របស់ប្រទេសណាមួយនោះទេ គឺភាគីពាក់ព័ន្ធទាំងអស់ ត្រូវមានកិច្ច សហប្រតិបត្តិការ ជាមួយគ្នាជា ពិសេសរវាងអាជ្ញាធរ មានសមត្ថកិច្ច ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំង ទៅនឹងបញ្ហាឧក្រិដ្ឋកម្មឆ្លងដែននេះ។

នាឱកាសនោះ សម្តេច ស ខេង និងលោកអគ្គរាជទូត បានផ្លាស់ប្តូរ យោបល់គ្នា ទៅវិញ ទៅមក លើបញ្ហាមួយចំនួន ក្នុងស្មារតីធ្វើយ៉ាងណាសម្រួល ដល់ការចេញចូលឆ្លងកាត់ព្រំដែន រវាងប្រទេសទាំងពីរ និងកិច្ចសហការក្នុងការឆ្លើយតបទៅនឹង គ្រោះមហន្តរាយនានា នៅតាមបណ្តាខេត្តជាប់ព្រំដែន នៃប្រទេសទាំងពីរ ឱ្យកាន់តែទទួលបានលទ្ធផលល្អប្រសើរ ។ លើសពីនេះ ភាគីទាំងពីរ ក៏បានពិភាក្សាផ្លាស់ប្តូរយោបល់ ទៅលើការជួយគាំទ្រ ដល់ពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងបំពេញការងារនៅប្រទេសថៃ និងបន្តកិច្ចសហការជិតស្និទ្ធ ក្នុងការទប់ស្កាត់ និងបង្ក្រាបនូវអំពើជួញដូរមនុស្សឆ្លងដែន ផងដែរ៕

## នគរបាលម៉ាឡេស៊ីគូសបញ្ជាក់ ពីភាពលំបាកក្នុងការបែងចែករវាងនណារជាជនរងគ្រោះនិងនណារជាជនឆបោក ខណៈជនជាតិម៉ាឡេស៊ី៦នាក់កំពុងរង់ចាំធ្វើមាតុភូមិនិវត្តន៍ពីកម្ពុជា

https://www.khmertimeskh.com/501230109// Khmer Times January 31, 2023

ប្រធាននាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្មរបស់នគរបាលម៉ាឡេស៊ី លោក Datuk Seri Abd Jalil Hassan បាននិយាយថា ជនរងគ្រោះជាជនជាតិម៉ាឡេស៊ីចំនួន ៦ នាក់ទៀតក៏ត្រូវបានជួយសង្គ្រោះដោយជោគជ័យដែរ ប៉ុន្តែបច្ចុប្បន្នកំពុងត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងនៅប្រទេសកម្ពុជាពីបទបំពានច្បាប់អន្តោប្រវេសន៍។ មនុស្ស ៥ នាក់ទៀតដែលត្រូវបានអាជ្ញាធរកម្ពុជាដោះលែងបានហោះត្រឡប់ទៅផ្ទះវិញកាលពីថ្ងៃសុក្រសប្តាហ៍មុន។ "យើងបានជួបជាមួយអគ្គនាយកអន្តោប្រវេសន៍របស់កម្ពុជា ហើយយើងពិតជារំភើបចំពោះអាជ្ញាធរដែលបានជួយសម្របសម្រួលជនរងគ្រោះទាំង៥នាក់។ Jalil បានប្រាប់អ្នកសារព័ត៌មាននៅអាកាសយានដ្ឋានអន្តរជាតិ Kuala Lumpur ថា "បើផ្អែកលើពេលវេលាធម្មតា វានឹងចំណាយពេលយ៉ាងហោចណាស់មួយខែដើម្បីដំណើរការការដោះលែងពួកគេ ប៉ុន្តែនាយកដ្ឋានអន្តោប្រវេសន៍នៅទីនោះបានពន្លឿនចំណាត់ការ និងដោះលែងពួកគេពីការឃុំឃាំងក្នុងរយៈពេលតិចជាង២៤ ម៉ោង ដូច្នេះយើងអាចនាំពួកគេត្រឡប់ទៅផ្ទះវិញបាន" ។ លោកបានបន្ថែមថា អាជ្ញាធរបានយល់ស្របថាមាន "ការពិបាក"ក្នុងការបែងចែកថានរណាជាជនរងគ្រោះនៃការឆបោក ឬនណារជាជនឆបោក។ លោក

បានបន្តថា អ្នកដែលទៅប្រទេសកម្ពុជាដឹងមុនថាពួកគេនឹងធ្វើការជាអ្នកបោកប្រាស់ក្នុងវិស័យដែលមិនត្រូវបានទទួលស្គាល់ទូលំទូលាយ ដូចជាឧស្សាហកម្មហ្គេម។

"ការស៊ើបអង្កេតបានបង្ហាញថា បុគ្គលទាំងនេះភាគច្រើនមិនមែនជាជនរងគ្រោះនៃការជួញដូរមនុស្សទេ ប៉ុន្តែបានហៅខ្លួនឯងថាជាជនរងគ្រោះ ដូច្នេះពួកគេអាចត្រូវបានគេជួយសង្គ្រោះ។ លោកបាននិយាយថា "បុគ្គលទាំងនេះខ្លះបង្កើតរឿងរ៉ាវនៃការជួញដូរនៅពេល ដែលពួកគេមិនអាចសម្រេចបាននូវការងារដែលដាក់ចេញដោយថៅកែរបស់ពួកគេ"ដោយបន្ថែមថាអ្នកដែលអាចបំពេញការងារបានសម្រេចជ្រើសរើសមិនត្រឡប់ទៅម៉ាឡេស៊ីវិញ។ Abd Jalil បន្ថែមថា អាជ្ញាធរកម្ពុជាក៏បានរកឃើញថា បុគ្គលមួយចំនួនដែលអះអាងថាជាជនរងគ្រោះពិតជាជំពាក់លុយពីការល្បែងស៊ីសង ខ្ចីលុយពីអ្នកចងការ ឬរកឃើញថាខ្លួនស្ថិតក្នុងស្ថានភាពដែលពួកគេមិនអាចមានលទ្ធភាពស្នាក់នៅសណ្ឋាគារ។ លោកបានបន្តថា អាជ្ញាធរកម្ពុជានឹងលែងទទួលយកព័ត៌មានដែលមិនទាន់បានផ្ទៀងផ្ទាត់ពីអង្គការមិនមែនរដ្ឋាភិបាល ឬទីភ្នាក់ងារដែលអាចបង្ខូចដល់ប្រតិបត្តិការជួយសង្គ្រោះរបស់ពួកគេ។

លោកបាននិយាយថា គិតត្រឹមថ្ងៃទី ២៦ ខែមករា ឆ្នាំនេះ របាយការណ៍សរុបចំនួន ២៦២ ពាក់ព័ន្ធនឹងជនរងគ្រោះយ៉ាងហោចណាស់ ៣៣០ នាក់ត្រូវបានបញ្ជូនទៅឃុំខ្លួន ខណៈជនរងគ្រោះសរុបចំនួន ១១៣ នាក់នៅតែជាប់គាំងក្នុងប្រទេសកម្ពុជា មីយ៉ាន់ម៉ា ឡាវ និងប្រទេសដទៃទៀត។ «ក្នុងករណីប្រទេសកម្ពុជា របាយការណ៍ចំនួន ១១៤ ពាក់ព័ន្ធនឹងជនរងគ្រោះ ១៤៥ នាក់ត្រូវបានដាក់ជូនទៅអាជ្ញាធរ។ លោកបានថ្លែងថា៖ «យើងបាននាំជនរងគ្រោះដល់ទៅ ១១៦ នាក់ត្រឡប់ទៅផ្ទះវិញ ខណៈជនរងគ្រោះ ២៩ នាក់កំពុងជាប់គាំងនៅកម្ពុជា»។ ជនរងគ្រោះនៃការឆបោកការងារត្រូវបានគេរាយការណ៍ថាបានធ្វើការរហូតដល់១៥ ម៉ោងក្នុងមួយថ្ងៃ ហើយថែមទាំងប្រឈមមុខនឹងការដាក់ទោសយ៉ាងធ្ងន់ធ្ងរដូចជាត្រូវបានឆក់ដោយចរន្តអគ្គិសនី ការបង្ខំអោយប្រើប្រាស់គ្រឿងញៀន ការរំលោភ ប្រសិនបើពួកគេមិនសម្រេចបានផែនការការងារដែលដាក់ចេញដោយថៅកែរបស់ពួកគេ។ *Malay Mail*

## ពលរដ្ឋស៊ីឈ្នួលចិញ្ច្រាំជំឡូងមី បានប្រាក់កម្រៃសមរម្យ ចៀសវាងចំណាកស្រុកទៅថៃ

https://kohsantepheapdaily.com.kh/article/1676835.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ប៉ៃលិន៣១ ខែ មករា ឆ្នាំ ២០២៣ ម៉ោង ១៤:៣៤

ខេត្តប៉ៃលិន ៖ រហូតមកដល់ថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣នេះ គេសង្កេតឃើញប្រជាពលរដ្ឋធ្វើដំណើរមកពីតាមបណ្តាខេត្តនានាដូចជា ខេត្តបាត់ដំបង ខេត្តបន្ទាយមានជ័យ ខេត្តពោធិ៍សាត់ ខេត្តកំពង់ឆ្នាំង និងខេត្តតាកែវ បានចូលមកស៊ីឈ្នួលកាប់ចិញ្ច្រាំ មើមដំឡូងមី នៅក្នុងភូមិប៉ាងរលឹម សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ដើម្បីបានថវិកាសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ ខណៈដែលថៅកែបានទិញមើមដំឡូងមីពីតាមចំការប្រជាពលរដ្ឋយកទៅចាក់គរឱ្យពួកគាត់នាំគ្នាកា.ប់ចិញ្ច្រាំដាក់ហាលស្ងួត រួចទើបគេប្រមូលលក់ក្នុងតម្លៃខ្ពស់ជាងមើមដំឡូងមីស្រស់តែម្តង។

បើតាមការរៀបរាប់ពីស្ត្រីឈ្មោះ ព្រំ សុភា រស់នៅខេត្តពោធិ៍សាត់ ស្ត្រីឈ្មោះ ណារី អាយុ៤៥ឆ្នាំ និងឈ្មោះស្រីស អាយុ៣២ឆ្នាំ រស់នៅខេត្តបាត់ដំបង បានរៀបរាប់ឱ្យដឹងដូចៗគ្នាថា ក្រោយសម្រាកពីការងារស្រែចំការនៅឯស្រុកកំណើតរៀងៗខ្លួន ពួកគាត់បានធ្វើដំណើរចូលមកក្នុងខេត្តប៉ៃលិន ដើម្បីបោះតង់សម្រាក ស៊ីឈ្នួលកា.ប់ចិញ្ច្រាំមើមដំឡូងមីឱ្យថៅកែនៅក្នុងខេត្តប៉ៃលិន បានថវិកាសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃ។ តាមប្រភពបន្តទៀតថា ការកាប់ចិញ្ច្រាំមើមដំឡូងមីនេះ ក្នុង១កញ្ជេទទួលបានប្រាក់កម្រៃ១.០០០រៀល ដោយក្នុង១ថ្ងៃៗ ពួកគាត់ដែលកាប់ចិញ្ច្រាំលឿនទទួលបានថវិកាចាប់ពី៣ទៅ៤ម៉ឺនរៀល អ្នកខ្លះទៀត មានកូនប្រពន្ធ និងប្តី ជួយកា.ប់ចិញ្ច្រាំគ្នា ក៏បានថវិការហូតដល់១ថ្ងៃ ចាប់ពី៨ទៅ៩ម៉ឺនរៀលផងដែរ។

អ្នកខ្លះទៀត ធ្វើការពេលថ្ងៃហើយ រហូតដល់ពេលយប់នាំគ្នាដាក់ភ្លើងអគ្គិសនីបំភ្លឺ កា.ប់ចិញ្ច្រាំបន្ថែម រហូតដល់យប់ជ្រៅ ទើបនាំគ្នាឈប់សម្រាក ដោយទទួលបានប្រាក់កម្រៃកាន់តែច្រើន ព្រោះពួកគាត់មិនចង់ធ្វើចំណាកស្រុកទៅស៊ីឈ្នួលធ្វើការងារឱ្យគេនៅប្រទេសថៃនោះទេ លំបាកក្នុងការធ្វើដំណើរចេញចូល ត្រូវបង់ថ្លៃលិខិតឆ្លងដែន បើមានបញ្ហាជំងឺរោគាកើតឡើងក៏លំបាកក្នុងការរកពេទ្យព្យាបាល ពិសេសគឺនឹកដល់ផ្ទះសម្បែងផងដែរ។ តាមប្រភពបញ្ជាក់ទៀតថា អ្នកខ្លះ ចូលមកស៊ីឈ្នួលកាប់ចិញ្ច្រាំមើមដំឡូងមីនេះ អស់រយៈពេល២ទៅ៣ខែមកហើយ អ្នកខ្លះទៀតតែចូលមកបោះតង់ ស្នាក់នៅលើដី ដែលថៅកែជួលគេ ដើម្បីនាំគ្នាធ្វើការកា.ប់ចិញ្ច្រាំមើមដំឡូងមី រហូតដល់ពេលរដូវធ្លាក់ភ្លៀងនាខែខាងមុខ ទើបពួកគាត់នាំគ្នាឈប់សម្រាកត្រឡប់ទៅធ្វើស្រែឯស្រុកកំណើតរបស់ខ្លួនវិញ។

សូមបញ្ជាក់ផងដែរថា តម្លៃទីផ្សារមើមដំឡូងមីពេលនេះ ឡើងថ្លៃខ្ពស់ខ្លាំង ដោយឈ្មួញទិញ១គីឡូក្រាម តម្លៃ៣.៣បាទ (ប្រាក់ថៃ) ជាង៣០០រៀល លុះកា.ប់ចិញ្ច្រាំហាលស្ងួត លក់បាន១គីឡូក្រាម តម្លៃចាប់ពី៧.៥ទៅ៧.៨បាត ជាង៧០០រៀលក្នុង១គីឡូក្រាម ដែលតម្លៃនេះ គេចាត់ទុកថា ឡើងខ្ពស់ ជាងឆ្នាំនានាកន្លងមក ដែលមិនធ្លាប់មានផងដែរ ៕

## សមត្ថកិច្ចស្រាវជ្រាវតាមបណ្តឹង Hotline រកឃើញជនជាតិបរទេស៨នាក់ នៅខេត្តឧត្តរមានជ័យ និងស្វាយរៀង

http://freshnewsasia.com/index.php/en/localnews/276050-2023-01-31-14-12-34.html 2023-01-31 09:12pm

**(ព្រះសីហនុ)៖** ការស្រាវជ្រាវតាមបណ្តឹង Hotline កាលពីថ្ងៃទី២៧ និងថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៣ កន្លងទៅនេះ សមត្ថកិច្ចបានរកឃើញជនជាតិបរទេសចំនួន ៨នាក់។ នេះបើតាមការបញ្ជាក់របស់ នាយឧត្តមសេនីយ៍ ខៀវ សុភ័គ អ្នកនាំពាក្យក្រសួងមហាផ្ទៃ។ ជនបរទេសដែលសមត្ថកិច្ចកម្ពុជាស្វែងរកឃើញ រួមមានជនជាតិថៃចំនួន ៣នាក់ ដែលត្រូវបានរកឃើញនៅក្រុងបាវិត ខេត្តស្វាយរៀង និងជនជាតិចិនចំនួន៥ ត្រូវបានរកឃើញនៅខេត្តឧត្តរមានជ័យ ប៉ុន្តែទោះជាយ៉ាងនេះក្តី ក្នុងចំណោមជនជាតិចិន ៥នាក់ដែលត្រូវបានរកឃើញនេះ មានជនជាតិចិន ១នាក់ បានរត់ចេញវិញ។ បើតាមនាយឧត្តមសេនីយ៍, នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០២៣ នេះ ក្រសួងមហាផ្ទៃ ក៏បានទទួលពាក្យបណ្តឹងមួយករណីផងដែរ ដើម្បីឲ្យជួយស្វែងរកជនជាតិចិនមួយនាក់៕

## សម្តេចក្រឡាហោម ស ខេង ៖ ក្រសួងមហាផ្ទៃចេញសេចក្តីសម្រេចចាត់តាំងក្រុមការងារ ដើម្បីត្រួតពិនិត្យនិងជំរុញការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព

http://nokorwatnews.com/archives/959541 02/02/2023

ភ្នំពេញ ៖ សម្តេចក្រឡាហោម សខេង ឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចេញសេចក្តីសម្រេចស្តីពីការចាត់តាំងក្រុមការងារត្រួតពិនិត្យនិងជំរុញ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃនៅថ្នាក់ក្រោមជាតិ មានចំនួន ២៤ក្រុម ក្នុងចំណោម ២៥រាជធានី-ខេត្ត ។ លេខាធិការដ្ឋានក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ ជាលេខាធិការដ្ឋាននៃក្រុមការងារនេះ។ ក្រុមការងារត្រួតពិនិត្យនិងជំរុញការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃនៅថ្នាក់ក្រោមជាតិ មានតួនាទីភារកិច្ចដូចខាងក្រោម៖

-សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីរៀបចំការផ្សព្វផ្សាយគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ជូនដល់មន្ត្រីរាជការ កងកម្លាំងមានសមត្ថកិច្ច សមាគម អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានឱ្យបានជ្រួតជ្រាប និងចូលរួមអនុវត្ត។

-សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត រៀបចំគោលការណ៍ វិធានការ និងផែនការអនុវត្តតាមដំណាក់កាលនីមួយៗ សហការណែនាំដល់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឱ្យរៀបចំផែនការសកម្មភាពជាក់ស្តែងដើម្បី អនុវត្តផែនការសកម្មភាព។

– រួមជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងអ្នកពាក់ព័ន្ធនានា ដើម្បីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងជំរុញការអនុវត្តផែនការសកម្មភាពតាមដំណាក់កាលនីមួយៗ និងជំរុញ ឱ្យក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

– សហការដឹកនាំជំរុញឱ្យមានចលនាប្រឡងប្រណាំងតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីវាយតម្លៃលក្ខណសម្បត្តិរបស់ភូមិ ឃុំ សង្កាត់ និងបុគ្គលដែលមានស្នាដៃក្នុងការចាត់តាំងអនុវត្តចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ស្ថិត ក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ។

– ធ្វើការបូកសរុបវាយតម្លៃសភាពការណ៍ និងលទ្ធផលប្រតិបត្តិការ ព្រមទាំងចំណាត់ថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប្រចាំខែជូនមកក្រសួងមហាផ្ទៃតាមរយៈលេខាធិការដ្ឋានដោយផ្អែកលើ តារាងទិន្នន័យដែលបានកំណត់ដោយក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ "ភូមិ- ឃុំ-សង្កាត់ មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ។

– រៀងរាល់បីខែម្តង ត្រូវត្រួតពិនិត្យវាយតម្លៃលទ្ធផលការងារ បញ្ហាប្រឈម និងវិធានការដោះស្រាយ ដើម្បីពង្រឹងបន្ថែមការអនុវត្តការងារ ព្រមទាំងដាក់ចេញនូវទិសដៅការងារសម្រាប់រយៈពេលបន្ត ទៀត។

–ក្នុងការអនុវត្តការងារខាងលើនេះ ក្រុមការងារត្រូវសហការជាមួយលេខាធិការដ្ឋានក្រុមប្រឹក្សា ប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព»។ បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

លេខាធិការដ្ឋានមានតួនាទីភារកិច្ចដូចខាងក្រោម៖

– ធ្វើសេនាធិការជូនក្រសួងមហាផ្ទៃក្នុងការតាមដានត្រួតពិនិត្យការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ព្រមទាំងផ្តើមស្នើគោលការណ៍ វិធានការនានាជូនក្រសួងមហាផ្ទៃ ដើម្បីជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។

–ជួយក្រសួងមហាផ្ទៃក្នុងការផ្សព្វផ្សាយផែនការ គោលការណ៍ផ្សេងៗរបស់ក្រសួងមហាផ្ទៃឱ្យទៅ អាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ដែលមានការពាក់ព័ន្ធ និងក្រុមការងារដូចមានចែងក្នុង ប្រការទី១ នៃសេចក្តីសម្រេចនេះ។

–រៀបចំកិច្ចប្រជុំ និងបំពេញកិច្ចការរដ្ឋបាលពាក់ព័ន្ធដល់ការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ និងបូកសរុបសភាពការណ៍ និងលទ្ធផលនៃការចាត់តាំងអនុវត្តគោលនយោបាយ "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព ក្នុងក្របខណ្ឌ ទូទាំងប្រទេសតាមដំណាក់កាលនីមួយៗជូនក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល។

– រៀបចំគម្រោងថវិកា មធ្យោបាយ សម្ភារៈបម្រើដល់ការចាត់តាំងអនុវត្តជូនក្រសួងមហាផ្ទៃពិនិត្យសម្រេច បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

ក្រុមការងារមានសិទ្ធិជ្រើសតាំង និងប្រើប្រាស់មន្ត្រីតាមនាយកដ្ឋាន អង្គភាព ចូលរួមជាសមាជិកក្នុង ក្រុមការងារ ដើម្បីជានាអនុវត្តឱ្យបានសម្រេចភារកិច្ចដែលប្រគល់ជូន។ លេខាធិការដ្ឋានមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទដើម្បីជួយបំពេញការងារតាមការចាំបាច់។

សេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ លេខ ១៩០៩ សសរ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការ ចាត់តាំងក្រុមការងារទទួលខុសត្រូវដឹកនាំត្រួតពិនិត្យការអនុវត្តគោលនយោបាយ "ភូមិ-ឃុំមានសុវត្ថិភាព» តាមរាជធានីខេត្ត ត្រូវជំនួសដោយសេចក្តីសម្រេចនេះ។ បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋាន ភស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម គ្រប់នាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
ក្រសួងមហាផ្ទៃ

លេខ: ៩៣២ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការចាត់តាំងក្រុមការងារត្រួតពិនិត្យនិងជំរុញ ការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃនៅថ្នាក់ក្រោមជាតិ

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- យោងគោលនយោបាយរបស់រាជរដ្ឋាភិបាល លេខ ០១ គនប ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០២១ ស្តីពី "ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព"
- បានឃើញប្រកាសលេខ ៤៣៩៨ ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានសម្រាប់គាំទ្រការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព»
- យោងតាមសំណូមពរនៃការងារ

## សម្រេច

**ប្រការ១.**_

ចាត់តាំងក្រុមការងារត្រួតពិនិត្យនិងជំរុញការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃនៅថ្នាក់ក្រោមជាតិ ដែលមានសមាសភាពដូចខាងក្រោម៖

**ក្រុមការងារទី១៖ រាជធានីភ្នំពេញ**

| | | |
|---|---|---|
| ១. ឯកឧត្តម សន្តិបណ្ឌិត **ខៀវ សុភ័គ** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **សួន ឈាងលី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ជា សុគន្ធា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**ក្រុមការងារទី២៖ ខេត្តកណ្ដាល**

| | | |
|---|---|---|
| ១. ឯកឧត្តម **អេង មង្គល** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **មួន សារ៉ែន** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ឯម សំណាង** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**ក្រុមការងារទី៣៖ ខេត្តកំពង់ចាម**

| | | |
|---|---|---|
| ១. ឯកឧត្តម សន្តិបណ្ឌិត **គេង សាវឌ្ឍ** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ថោង សំអាត** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ស៊ុម សុខម្ភ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**ក្រុមការងារទី៤៖ ខេត្តព្រៃវែង**

| | | |
|---|---|---|
| ១. ឯកឧត្តម សន្តិបណ្ឌិត **ចាន់ អ៊ីវ៉ាន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **អ៊ុច សាមី** | រដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **សរ សិទ្ធិ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**ក្រុមការងារទី៥៖ ខេត្តស្វាយរៀង**

| | | |
|---|---|---|
| ១. ឯកឧត្តម **រស់ ចរុណា** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **សម តារា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ឡឿន សុវណ្ណ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**ក្រុមការងារទី៦៖ ខេត្តតាកែវ**

| | | |
|---|---|---|
| ១. ឯកឧត្តម សន្តិបណ្ឌិត **ម៉ៅ ច៊ុនណារិន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ផុន ម៉ិនថាល់** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ខួន ស៊ីផាន់** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**ក្រុមការងារទី៧៖ ខេត្តបាត់ដំបង**

| | | |
|---|---|---|
| ១. ឯកឧត្តម សន្តិបណ្ឌិត **សុខ ផល** | រដ្ឋលេខាធិការ | ប្រធាន |

| | | |
|---|---|---|
| ២. ឯកឧត្តម **ឈឹម សុផា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **អ៊ុច សុខុន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី៨៖ ខេត្តប៉ៃលិន</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម **ម៉ុន ហុន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **អ៊ូច ចាន់ណូរ៉ា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **បេ ឆាឡេង** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី៩៖ ខេត្តសៀមរាប</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម **លេង ទី** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **សួស អង្គារ៍** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **គេង សួន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១០៖ ខេត្តឧត្តរមានជ័យ</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម **យុន ឈុន្លី** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ជាំ ឫទ្ធី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ង ឫឡឺ** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១១៖ ខេត្តកំពត និងខេត្តកែប</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម សន្តិបណ្ឌិត **ម៉ៅ ចំន្ទតារា** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ឪ សុភដាន** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **ហ៊ូ សាគុណា** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១២៖ ខេត្តកំពង់ស្ពឺ</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម **សំរិទ្ធ ឪ** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **ថោង លឹម** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **សេក គូម៉ី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១៣៖ ខេត្តបន្ទាយមានជ័យ</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម **ឆាន់ ចាន់ធុល** | រដ្ឋលេខាធិការ | ប្រធាន |
| ២. លោកជំទាវ **អុខ សុតាទី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម **អាត់ ខែម** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១៤៖ ខេត្តកំពង់ធំ</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម **អ៊ុត សំអន** | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម **សុខ មុនី** | អនុរដ្ឋលេខាធិការ | អនុប្រធាន |

| | | |
|---|---|---|
| ៣. ឯកឧត្តម រស់ សាផល | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១៥៖ ខេត្តកំពង់ឆ្នាំង</u>**

| | | |
|---|---|---|
| ១. លោកជំទាវ ជូ ប៊ុនអេង | រដ្ឋលេខាធិការ | ប្រធាន |
| ២. លោកជំទាវ ជួញ សុខនៃ | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម ហោង ពិន្ទុ | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១៦៖ ខេត្តពោធិ៍សាត់</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម ហ៊ុយ ចណ្ណៈ | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម ហ៊ុយ ហឿន | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម ស្រ៊ុន លិញ | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១៧៖ ខេត្តស្ទឹងត្រែង</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម ឡាំ ជា | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម ចាន់ គឹមសេង | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. លោកជំទាវ គង់ ស៊ីផា | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១៨៖ ខេត្តរតនគិរី</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម ង៉ិច ហាមផាន | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម ម៉ុម សារឿន | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម អ៊ូន សុធា | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី១៩៖ ខេត្តព្រះសីហនុ</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម កៅ ខុនដាវ៉ា | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម សោម ចំនួនឱណា | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម ទ្រី សុខហេង | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី២០៖ ខេត្តកោះកុង</u>**

| | | |
|---|---|---|
| ១. ឯកឧត្តម មៀច សុផាន់ណា | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម គីម ជាតិ | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម ស្រេង ចន្ទ្យហៀង | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី២១៖ ខេត្តក្រចេះ</u>**

| | | |
|---|---|---|
| ១. ឯកឧត្តមបណ្ឌិត ស៊ាង ប៊ុនលាង | រដ្ឋលេខាធិការ | ប្រធាន |
| ២. ឯកឧត្តម ឡាយ ណារុធ | អនុរដ្ឋលេខាធិការ | អនុប្រធាន |
| ៣. ឯកឧត្តម អ៊ុច លាង | អនុរដ្ឋលេខាធិការ | អនុប្រធាន |

**<u>ក្រុមការងារទី២២៖ ខេត្តត្បូងឃ្មុំ</u>**

១. ឯកឧត្តម **កុល ធីរក្ស** រដ្ឋលេខាធិការ ប្រធាន

២. ឯកឧត្តម **គាង សេង** អនុរដ្ឋលេខាធិការ អនុប្រធាន

៣. លោកជំទាវ **យត់ សុខា** អនុរដ្ឋលេខាធិការ អនុប្រធាន

**<u>ក្រុមការងារទី២៣៖ ខេត្តមណ្ឌលគិរី</u>**

១. ឯកឧត្តម **ទី ចំរ្ទនផល** រដ្ឋលេខាធិការ ប្រធាន

២. ឯកឧត្តម **ពីម សំណាង** អនុរដ្ឋលេខាធិការ អនុប្រធាន

៣. ឯកឧត្តម **ម៉ៅ សំបុណ្ណ** អនុរដ្ឋលេខាធិការ អនុប្រធាន

**<u>ក្រុមការងារទី២៤៖ ខេត្តព្រះវិហារ</u>**

១. ឯកឧត្តម **អ៊ុំ ម៉ារ៉ា** រដ្ឋលេខាធិការ ប្រធាន

២. ឯកឧត្តម **ឆាង ពៅ** អនុរដ្ឋលេខាធិការ អនុប្រធាន

៣. ឯកឧត្តម **សុខ ច័ន្ទរិទ្ធី** អនុរដ្ឋលេខាធិការ អនុប្រធាន

**ប្រការ២.** _

លេខាធិការដ្ឋានក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ដែលស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ ជាលេខាធិការដ្ឋាននៃក្រុមការងារនេះ។

**ប្រការ៣.** _

ក្រុមការងារត្រួតពិនិត្យនិងជំរុញការអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃនៅថ្នាក់ក្រោមជាតិ មានតួនាទីភារកិច្ចដូចខាងក្រោម៖

- សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត ដើម្បីរៀបចំការផ្សព្វផ្សាយគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ជូនដល់មន្ត្រីរាជការ កងកម្លាំងមានសមត្ថកិច្ច សមាគម អង្គការមិនមែនរដ្ឋាភិបាល វិស័យឯកជន និងប្រជាពលរដ្ឋគ្រប់មជ្ឈដ្ឋានឱ្យបានជ្រួតជ្រាប និងចូលរួមអនុវត្ត។
- សហការជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត រៀបចំគោលការណ៍ វិធានការ និងផែនការអនុវត្តតាមដំណាក់កាលនីមួយៗ
- សហការណែនាំដល់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ឱ្យរៀបចំផែនការសកម្មភាពជាក់ស្តែងដើម្បីអនុវត្តផែនការសកម្មភាព។
- រួមជាមួយគណៈបញ្ជាការឯកភាពរដ្ឋបាលរាជធានី ខេត្ត និងអ្នកពាក់ព័ន្ធនានា ដើម្បីតាមដានត្រួតពិនិត្យ វាយតម្លៃ និងជំរុញការអនុវត្តផែនការសកម្មភាពតាមដំណាក់កាលនីមួយៗ និងជំរុញឱ្យក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ចាត់ចែងអនុវត្តឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។
- សហការដឹកនាំជំរុញឱ្យមានចលនាប្រឡងប្រណាំងតាមរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីវាយតម្លៃលក្ខណសម្បត្តិរបស់ភូមិ ឃុំ សង្កាត់ និងបុគ្គលដែលមានស្នាដៃក្នុងការចាត់តាំង

អនុវត្តចលនាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ។

- ធ្វើការបូកសរុបវាយតម្លៃសភាពការណ៍ និងលទ្ធផលប្រតិបត្តិការ ព្រមទាំងចំណាត់ថ្នាក់ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប្រចាំខែជូនមកក្រសួងមហាផ្ទៃតាមរយៈលេខាធិការដ្ឋានដោយផ្អែកលើតារាងទិន្នន័យដែលបានកំណត់ដោយក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ។
- រៀងរាល់បីខែម្តង ត្រូវត្រួតពិនិត្យវាយតម្លៃលទ្ធផលការងារ បញ្ហាប្រឈម និងវិធានការដោះស្រាយដើម្បីពង្រឹងបន្ថែមការអនុវត្តការងារ ព្រមទាំងដាក់ចេញនូវទិសដៅការងារសម្រាប់រយៈពេលបន្តទៀត។
- ក្នុងការអនុវត្តការងារខាងលើនេះ ក្រុមការងារត្រូវសហការជាមួយលេខាធិការដ្ឋានក្រុមប្រឹក្សាប្រឡងប្រណាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព»។
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៤.**_

លេខាធិការដ្ឋានមានតួនាទីភារកិច្ចដូចខាងក្រោម៖

- ធ្វើសេនាធិការជូនក្រសួងមហាផ្ទៃក្នុងការតាមដានត្រួតពិនិត្យការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ព្រមទាំងផ្តើមស្នើគោលការណ៍ វិធានការនានាជូនក្រសួងមហាផ្ទៃ ដើម្បីជំរុញការអនុវត្តឱ្យមានប្រសិទ្ធភាព និងទទួលបានជោគជ័យ។
- ជួយក្រសួងមហាផ្ទៃក្នុងការផ្សព្វផ្សាយផែនការ គោលការណ៍ផ្សេងៗរបស់ក្រសួងមហាផ្ទៃឱ្យទៅអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់ដែលមានការពាក់ព័ន្ធ និងក្រុមការងារដូចមានចែងក្នុងប្រការទី១ នៃសេចក្តីសម្រេចនេះ
- រៀបចំកិច្ចប្រជុំ និងបំពេញកិច្ចការរដ្ឋបាលពាក់ព័ន្ធដល់ការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាព» ស្ថិតក្នុងសមត្ថកិច្ចក្រសួងមហាផ្ទៃ និងបូកសរុបសភាពការណ៍ និងលទ្ធផលនៃការចាត់តាំងអនុវត្តគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ក្នុងក្របខណ្ឌទូទាំងប្រទេសតាមដំណាក់កាលនីមួយៗជូនក្រសួងមហាផ្ទៃ និងរាជរដ្ឋាភិបាល
- រៀបចំគម្រោងថវិកា មធ្យោបាយ សម្ភារៈបម្រើដល់ការចាត់តាំងអនុវត្តជូនក្រសួងមហាផ្ទៃពិនិត្យសម្រេច
- បំពេញភារកិច្ចផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៥.**_

ក្រុមការងារមានសិទ្ធិជ្រើសតាំង និងប្រើប្រាស់មន្ត្រីតាមនាយកដ្ឋាន អង្គភាព ចូលរួមជាសមាជិកក្នុងក្រុមការងារ ដើម្បីធានាអនុវត្តឱ្យបានសម្រេចភារកិច្ចដែលប្រគល់ជូន។

លេខាធិការដ្ឋានមានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទដើម្បីជួយបំពេញការងារតាមការចាំបាច់។

**ប្រការ៦.**_

សេចក្តីសម្រេចរបស់ក្រសួងមហាផ្ទៃ លេខ ១៩០៩ សសរ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការចាត់តាំងក្រុមការងារទទួលខុសត្រូវដឹកនាំត្រួតពិនិត្យការអនុវត្តគោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» តាមរាជធានី ខេត្ត ត្រូវជំនួសដោយសេចក្តីសម្រេចនេះ។

**ប្រការ៧.**_

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៨.**_

អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល អគ្គាធិការនៃអគ្គាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធនាគារ អគ្គនាយកនៃអគ្គនាយកដ្ឋានអន្តោប្រវេសន៍ អគ្គនាយកនៃអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង ប្រធានក្រុមប្រឹក្សានីតិកម្ម គ្រប់នាយកដ្ឋាន-អង្គភាពពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ១០កើត ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែមករា ឆ្នាំ២០២៣

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

**កន្លែងទទួល**:

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានី ខេត្ត
- ដូចប្រការ៨
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ថ្ងៃទី០៦ ខែ កុម្ភៈ ឆ្នាំ២០២៣

## សមត្ថកិច្ចស្រាវជ្រាវ តាមបណ្ដឹងសុំអន្តរាគមន៍ ២ករណីទៀត រកឃើញជនបរទេស ២នាក់ ប៉ុន្តែពុំមែនជាករណីបង្ខាំង និងធ្វើទារុណកម្មឡើយ

https://freshnewsasia.com/index.php/en/localnews/276216-2023-02-02-08-11-47.html 2023-02-02 03:11pm

**(ភ្នំពេញ)៖** កម្លាំងសមត្ថកិច្ចកម្ពុជា បានស្រាវជ្រាវតាមបណ្ដឹងសុំអន្តរាគមន៍ចំនួន២ករណីបន្ថែមទៀត ដោយបានរកឃើញជនបរទេសជាតិចិន ១នាក់ និងជនជាតិវៀតណាម ១នាក់ ប៉ុន្តែពុំមែនជាករណីបង្ខាំង និងធ្វើទារុណកម្មឡើយ។

បើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ, ការស្រាវជ្រាវនេះ ធ្វើឡើងបន្ទាប់ពីមានបណ្ដឹងចំនួន២ តាមបណ្ដាញ Hotline ថាមានករណីបង្ខាំង ធ្វើទារុណកម្ម។

ក្នុងករណីទី១ សមត្ថកិច្ចបានប្រតិបត្តិការ នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៣ ដោយបានរកឃើញជនរងគ្រោះ១នាក់ ភេទប្រុស សញ្ជាតិចិន នៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០២៣។ ជនរងគ្រោះនេះមានឈ្មោះ WEI Zhongcheng។

ចំណែកករណីមួយទៀត នៅថ្ងៃទី២៩ ខែមករា ឆ្នាំ២០២៣ សមត្ថកិច្ចបានស្រាវជ្រាវស្វែងរកឃើញជនរងគ្រោះ១នាក់ ភេទប្រុសជនជាតិវៀតណាម ឈ្មោះ VU VAN CHIEN។

ដោយឡែកសម្រាប់នៅថ្ងៃទី៣០ ខែមករា ដល់ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជា ពុំបានទទួលសុំណើ សំណូមពរឱ្យជួយអន្តរាគមន៍នោះឡើយ៕

## អន្តរក្រសួងពិភាក្សាលើសេចក្តីព្រាងស្តីពីការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស ដើម្បីចុះកិច្ចព្រមព្រៀងជាមួយកូរ៉េ

https://btv.com.kh/article/19740 2023/02/02 04:58:58 pm

ភ្នំពេញ ៖ នារសៀលថ្ងៃទី០២ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រសួងមហាផ្ទៃបានបើកកិច្ចប្រជុំអន្តរក្រសួង ដើម្បីពិភាក្សារៀបចំសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នា(MOU) រវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ពាក់ព័ន្ធនឹងកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន។

មានប្រសាសន៍ក្នុងកិច្ចប្រជុំនោះ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រ ធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ)បានថ្លែងថា កិច្ចប្រជុំនេះ ធ្វើឡើងយោងតាមចំណាររបស់សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានប្រគល់ភារកិច្ចជូនលោកជំទាវ ដើម្បីដឹកនាំប្រជុំពិនិត្យ និងផ្តល់យោបល់។ លោកជំទាវបន្តថា ដើម្បីឈានទៅដល់ការរៀបចំសេចក្តីព្រាងអនុស្សរណៈទ្វេភាគី រវាងរដ្ឋាភិបាលនៃប្រទេសទាំងពីរ ចាំបាច់ត្រូវសិក្សាស្វែងយល់អំពីទំនាក់ទំនង និងទិន្នន័យពាក់ព័ន្ធមួយចំនួនជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានក្នុងការដាក់បញ្ចូលក្នុងអនុស្សរណៈដែលជាកិច្ចសហប្រតិបត្តិការក្នុងការប្រ យុទ្ធប្រឆាំងអំពើជួញដូរមនុស្សរវាងប្រទេសទេសទាំងពីរ។ លោកជំទាវបន្ថែមថា មុននឹងឈានដល់ការបង្កើតគំនិតផ្តួចផ្តើមរៀបចំអនុស្សរណៈទ្វេភាគីនេះឡើង គឺបន្ទាប់ពីមានការពិភាក្សា និងឆ្លងឆ្លើយតាមរយៈលិខិតជាផ្លូវការរវាងសម្តេចក្រឡាហោម ស ខេង ជាមួយនឹងឯកឧត្តម ស៊ិន ចាយ៉ុង អនុរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃសាធារណរដ្ឋកូរ៉េ។

ក្នុងកិច្ចប្រជុំនេះ អន្តរក្រសួងបានពិភាក្សា និងពិគ្រោះយោបល់លើបទពិសោធន៍ពាក់ព័ន្ធ និងធាតុចូលសំខាន់ៗនានាពីគ្រប់សមាជិកអង្គប្រជុំ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកំណត់យកជាខ្លឹមសារសម្រាប់ដាក់បញ្ចូលក្នុង MOU ទ្វេភាព ឱ្យមានភាពគ្រប់ជ្រុងជ្រោយ និងមានវិសាលភាពទូលំទូលាយ លើកិច្ចសហការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនរវាងប្រទេសទាំងពីរឱ្យ មានប្រសិទ្ធភាពខ្ពស់។

ក្រៅពីថ្លែងអំណរគុណចំពោះអន្តរក្រសួងដែលបានចែករំលែកបទពិសោធន៍ ព្រមទាំងធាតុចូលសំខាន់ ៗ នៅក្នុងកិច្ចប្រជុំនេះ លោកជំទាវ ជូ ប៊ុនអេង ក៏បានបញ្ជាក់បន្ថែមដែរថា កិច្ចប្រជុំនេះនឹងត្រូវរៀបចំជាបន្តបន្ទាប់ទៀត ដើម្បីពិភាក្សាលើវឌ្ឍនភាព និងរហូតឈានដល់ទទួលបានការឯកភាពគ្នាទាំងស្រុង៕ ដោយៈ គង់ ឌិន

## កិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនរវាងកម្ពុជា និងកូរ៉េ កំពុងត្រូវបានមន្ត្រីអន្តរក្រសួងពិភាក្សា

https://www.postkhmer.com/national/2023-02-03-1048-246606.html ភ្នំពេញ ប៉ុស្តិ៍ | Publication date 03 February 2023 | 10:48 ICT

**ភ្នំពេញៈ** ក្រសួងមហាផ្ទៃ កាលពីថ្ងៃទី ២ កុម្ភៈ បានបើកកិច្ចប្រជុំអន្តរក្រសួងដើម្បីធ្វើការពិភាក្សារៀបចំសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នា (MOU) រវាងរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េពាក់ព័ន្ធនឹងកិច្ចសហការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែន។

កិច្ចប្រជុំនេះត្រូវបានធ្វើឡើងក្រោមអធិបតីភាព លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) ដោយមានការអញ្ជើញចូលរួមពីរដ្ឋលេខាធិការក្រសួងមហាផ្ទៃ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ អគ្គនាយកដ្ឋាន នៃក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមន្ត្រីជំនាញផងដែរ។ លោកស្រី ជូ ប៊ុនអេង បានថ្លែងថា កិច្ចប្រជុំពិគ្រោះយោបល់ និងពិភាក្សាផ្តួចផ្តើមរៀបចំសេចក្តីព្រាងអនុស្សរណៈយោគយល់គ្នានេះ គឺធ្វើឡើង ដើម្បីឈានទៅដល់ការរៀបចំសេចក្តីព្រាងអនុស្សរណៈទ្វេភាគី រវាងរដ្ឋាភិបាលនៃប្រទេសទាំង២ ដែលចាំបាច់ត្រូវសិក្សាស្វែងយល់អំពីទំនាក់ទំនង និងទិន្នន័យពាក់ព័ន្ធមួយចំនួន ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់ជាមូលដ្ឋានក្នុងការដាក់បញ្ចូលក្នុងអនុស្សរណៈដែលជាកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរវាងប្រទេសទាំង២។

មុននឹងឈានដល់ការបង្កើតគំនិតផ្តួចផ្តើមរៀបចំអនុស្សរណៈទ្វេភាគីនេះឡើង គឺបន្ទាប់ពីមានការពិភាក្សា និងឆ្លងឆ្លើយតាមរយៈលិខិតផ្លូវការរវាងលោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាមួយនឹងលោក ស៊ិន ចាយ៉ុង អនុរដ្ឋមន្ត្រីក្រសួងយុត្តិធម៌នៃសាធារណរដ្ឋកូរ៉េ។ អង្គប្រជុំបានពិភាក្សា និងពិគ្រោះយោបល់គ្នាលើបទពិសោធន៍ពាក់ព័ន្ធ និងធាតុចូលសំខាន់ៗនានាពីគ្រប់សមាជិកអង្គប្រជុំដែលជាតំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ សម្រាប់ធ្វើជាមូលដ្ឋានក្នុងការកំណត់យកជាខ្លឹមសារសម្រាប់ដាក់បញ្ចូលក្នុងអនុស្សរណៈយោគយល់ទ្វេភាគី មានភាពគ្រប់ជ្រុងជ្រោយ និងមានវិសាលភាពទូលំទូលាយ លើកិច្ចសហការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងឧក្រិដ្ឋកម្មឆ្លងដែនរវាងប្រទេសទាំង២ឱ្យមានប្រសិទ្ធភាពខ្ពស់។

កិច្ចប្រជុំពិគ្រោះយោបល់នេះ នឹងត្រូវរៀបចំប្រជុំជាបន្តបន្ទាប់ទៀត ដើម្បីពិភាក្សាគ្នាលើវឌ្ឍនភាព និងរហូតឈានដល់ទទួលបានការឯកភាពគ្នាទាំងស្រុង។ ទន្ទឹមនេះ លោកស្រី ជូ ប៊ុនអេង ក៏បានណែនាំឱ្យសមាជិកនៃអង្គប្រជុំទាំងអស់ជួយសិក្សាស្រាវជ្រាវ និងរៀបចំជាធាតុចូលសំខាន់ៗបន្ថែមទៀត សម្រាប់បំពេញបន្ថែមនៅក្នុងកិច្ចប្រជុំពេលក្រោយ៕,

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៣ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៣នាក់

http://freshnewsasia.com/index.php/en/localnews/276303-2023-02-03-07-06-25.html 2023-02-03 02:06pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេសចំនួន ០៣នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧២៥ករណី មានមនុស្ស ១,៧៦៨នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៥៨សំណើ និងបិទសំណុំរឿង ២៣៦សំណើ (រកឃើញមនុស្ស ១,០៧៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១២២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣១ករណី៕

## ជនជាតិម៉ាឡេស៊ីជនរងគ្រោះ
## ដោយសារការឆបោកការងារនៅកម្ពុជា៖ អង្គការមិនមែនរដ្ឋាភិបាលនិយាយថា នគរបាលម៉ាឡេស៊ីបានប្រព្រឹត្តខុស ដោយទុកចោលជនរងគ្រោះ៥នាក់ នៅកម្ពុជា

https://www.khmertimeskh.com/501232743//?p=1232743 Khmer Times February 4, 2023

អង្គការមិនមែនរដ្ឋាភិបាលមួយបាននិយាយថា នគរបាលម៉ាឡេស៊ីបានធ្វើខុសនៅពេលដែលខ្លួននិយាយថា មិនអាចនាំជនជាតិម៉ាឡេស៊ី ៥ នាក់ទៅផ្ទះវិញដោយសារតែច្បាប់អន្តោប្រវេសន៍នៅកម្ពុជា។ លោក Adrian Pereira នាយកប្រតិបត្តិ North South Initiative នៃអង្គការសិទ្ធិជនចំណាកស្រុកបាននិយាយថា ជនរងគ្រោះនៃការបោកប្រាស់ការងារ គឺជាបុគ្គលដែលត្រូវបានជួញដូរ ហើយក្រោមអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការជួញដូរ ពួកគេមិនអាចត្រូវចាប់ខ្លួនក្រោមបទល្មើសអន្តោប្រវេសន៍បានទេ។ "ជនរងគ្រោះពីការបោកប្រាស់ការងារអាចត្រូវបានគេជួយសង្គ្រោះបានកាន់តែងាយស្រួល ប្រសិនបើអាជ្ញាធរប្រើប្រាស់ការមិនដាក់ទណ្ឌកម្មជនរងគ្រោះនៃការជួញដូរក្រោមក្រុមសម្របសម្រួលអន្តរទីភ្នាក់ងារប្រឆាំងនឹងការជួញដូរមនុស្ស និងច្បាប់អន្តរជាតិមួយចំនួនទៀតដែលការពារសិទ្ធិរបស់ជនរងគ្រោះ។ «នៅក្នុងករណីថ្មីៗនេះ លោក Abdul Jalil ប្រធាននាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្មសហព័ន្ធ ដែលបានដឹកនាំបេសកកម្មជួយសង្គ្រោះនៅកម្ពុជា បាននិយាយថា មនុស្ស៥នាក់ដែលត្រូវបានជួយសង្គ្រោះមិនអាចត្រឡប់មកវិញបានទេ ដោយសារបានបំពានច្បាប់អន្តោប្រវេសន៍របស់ប្រទេស។ "ទោះជាយ៉ាងនេះក្តី អ្នកដែលត្រូវបានចាត់ថ្នាក់ជាជនរងគ្រោះពីការជួញដូរមនុស្ស នឹងត្រូវបានការពារក្រោមច្បាប់ប្រឆាំងការជួញដូរ។ លោក Adrian Pereira បានប្រាប់ Malaysiakini ថា "សិទ្ធិមនុស្ស និងអ្នកអនុវត្តយុត្តិធម៌ព្រហ្មទណ្ឌបានលើកឡើងពីការព្រួយបារម្ភថា ការចាប់ខ្លួន ការចោទប្រកាន់ ការឃុំខ្លួន ការកាត់ទោស ឬការដាក់ទណ្ឌកម្មលើជនរងគ្រោះដែលត្រូវបានជួញដូរដោយបានប្រព្រឹត្តបទឧក្រិដ្ឋនឹងមានភាពអយុត្តិធម៌"។ លោកបានបន្ថែមទៀតថា ជនរងគ្រោះពីការឆបោកការងារត្រូវបានឃុំខ្លួនដោយខុសច្បាប់ ធ្វើទារុណកម្ម ឆក់ខ្សែភ្លើង រំលោភបំពានផ្លូវភេទ បៀតបៀន និងការបង្អត់អាហារ ដែលអាចចាត់ថ្នាក់ថាជាជនរងគ្រោះពីការជួញដូរ។

៦ខែនៃការរង់ចាំការសង្គ្រោះនៅក្នុងសន្និសីទសារព័ត៌មាននៅព្រលានយន្តហោះ KLIA នៅថ្ងៃទី២៧ ខែមករា ប្រធាននាយកដ្ឋានស៊ើបអង្កេតឧក្រិដ្ឋកម្មសហព័ន្ធបាននិយាយថាក្នុងចំណោមជនជាតិម៉ាឡេស៊ី៣៣០នាក់ដែលបានជាប់គាំងនៅក្នុងប្រទេសកម្ពុជា ឡាវ មីយ៉ាន់ម៉ា និងប្រទេសដទៃទៀត ប្រជាជនម៉ាឡេស៊ីសរុប២១១នាក់ត្រូវបានជួយសង្គ្រោះហើយ១១៣ នាក់ទៀតកំពុងជាប់គាំងនៅបរទេស។ លោកបានបន្តថា ក្នុងចំណោមមនុស្ស ១៤៥ នាក់ដែលគេស្គាល់ថាជាជនរងគ្រោះដោយសារការឆបោកការងារនៅកម្ពុជា មាន១១៦ នាក់ត្រូវបានគេជួយសង្គ្រោះ ខណៈ ២៩ នាក់ទៀតនៅជាប់គាំងនៅទីនោះ។

លោក Jalil បាននិយាយថា "មនុស្ស៥នាក់ផ្សេងទៀត ដែលត្រូវបានជួយសង្គ្រោះក្នុងអំឡុងពេលបេសកកម្មរបស់នគរបាល មិនអាចត្រឡប់មកវិញបានទេ ដោយសារបំពានច្បាប់អន្តោប្រវេសន៍របស់ប្រទេស"។ លោក Jalil ក៏បានបន្ថែមដែរថា បេសកកម្មរយៈពេល៤ ថ្ងៃរបស់ក្រុមនគរបាលគឺបានសម្របសម្រួលដោយនគរបាល ក្រសួងការបរទេស ស្ថានទូតម៉ាឡេស៊ីនៅចន្លោះថ្ងៃទី២៤ ដល់ថ្ងៃទី២៧ ខែមករា។ ទន្ទឹមនឹងនេះ លោក Pereira បាននិយាយថា ជនរងគ្រោះនៃការជួញដូរនៅក្នុងប្រទេសម៉ាឡេស៊ីអាចត្រូវបានគេជួយសង្គ្រោះក្នុងរយៈពេលមួយសប្តាហ៍ ហើយពួកគេត្រូវបានធ្វើមាតុភូមិនិវត្តន៍ភ្លាមៗ។ ទោះជាយ៉ាងណាក៏ដោយ អាជ្ញាធរម៉ាឡេស៊ីមិនអាចជួយជនជាតិម៉ាឡេស៊ីដែលបានធ្លាក់ខ្លួនធ្វើជាឈ្លើយរបស់អ្នកជួញដូរនៅបរទេសនោះទេ។

"ខ្ញុំមិនយល់ទេថា ហេតុអ្វីបានជានៅពេលដែលជនជាតិម៉ាឡេស៊ីដែលរងគ្រោះដោយការចាញ់បោកការងារត្រូវបានឃុំខ្លួនក្នុងប្រទេសផ្សេងទៀតដូចជាកម្ពុជា ឡាវ វៀតណាម និងមីយ៉ាន់ម៉ា ដោយក្រុមជួញដូរមនុស្ស ត្រូវការពេលរហូតដល់ជាង៦ខែដើម្បីជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍។ «យើងកំពុងដោះស្រាយករណីមួយដែលពាក់ព័ន្ធនឹងជនជាតិម៉ាឡេស៊ីម្នាក់ត្រូវបានឃុំខ្លួនក្នុងប្រទេសមីយ៉ាន់ម៉ា។ វាមានរយៈពេលជិតប្រាំមួយខែហើយ យើងនៅតែមិនអាចជួយសង្គ្រោះជនរងគ្រោះបានទេ។ លោកបានបន្ថែមថា "អង្គការក្រៅរដ្ឋាភិបាលនៅទីនេះគិតថាមានកិច្ចការជាច្រើនដែលត្រូវធ្វើនៅកម្រិតអាស៊ាន ដើម្បីពន្លឿនដំណើរការជួយសង្គ្រោះ និងការធ្វើមាតុភូមិនិវត្តន៍។ ក្រុមគ្រួសារជនរងគ្រោះទទួលរងនូវភាពតានតឹង និងការធ្វើទារុណកម្មផ្លូវចិត្តចំពោះសុវត្ថិភាពរបស់ជនរងគ្រោះ"។

ជនរងគ្រោះត្រូវបានគេបង្ខំឱ្យធ្វើជាអ្នកបោកប្រាស់ Glorene Das នាយកប្រតិបត្តិ Tenaganita បាននិយាយថា នគរបាលម៉ាឡេស៊ីមានការលំបាកក្នុងការជួយសង្គ្រោះជនរងគ្រោះ ខណៈដែលបញ្ហាទាំងនោះកំពុងកើតឡើងនៅក្រៅប្រទេសម៉ាឡេស៊ី។ លោកស្រីបានបន្តថា ជនរងគ្រោះនៃការឆបោកការងារត្រូវបានឃុំខ្លួនដោយប្រាក់លោះ ហើយត្រូវបានបង្ខំឱ្យធ្វើដើម្បីលោះខ្លួន។ នៅទីតាំងទាំងនេះ ជនរងគ្រោះត្រូវបានបង្ខំឱ្យធ្វើសកម្មភាពឧក្រិដ្ឋកម្មតាមអ៊ីនធឺណិត ដូចជា "ការបោកប្រាស់តាមរយៈរូបភាពស្នេហា" និងការក្លែងបន្លំគ្រីបតូ រហូតដល់ការលាងលុយកខ្វក់ និងការលេងល្បែងស៊ីសងខុសច្បាប់តាមអ៊ីនធឺណិត។ "យើងក៏បានទទួលរបាយការណ៍អំពីការរំលោភផ្លូវភេទ ហើយស្ត្រីមួយចំនួនត្រូវបានជ្រើសរើសឱ្យធ្វើការនៅក្នុងមជ្ឈមណ្ឌលបោកប្រាស់ដោយទទួលរងការកេងប្រវ័ញ្ចផ្លូវភេទ។ ពួកគេក៏ត្រូវបានគេធ្វើទារុណកម្មផ្លូវចិត្ត និងផ្លូវកាយផងដែរ។ លោកស្រីបានបន្តថា "ពួកគេក៏ត្រូវបានបង្ខំឱ្យចុះហត្ថលេខាលើកិច្ចសន្យា ឬបង់ថ្លៃលោះដែលអាចមានរហូតដល់ RM៨០,០០០ក្នុងមនុស្សម្នាក់"។ លោកស្រីបានបន្ថែមទៀតថា ជាទូទៅ ក្រុមអ្នកជួញដូរកំពុងកំណត់គោលដៅលើយុវជនដែលមានការអប់រំ ចេះកុំព្យូទ័រ និងអាចនិយាយភាសាអង់គ្លេស ឬភាសាចិនកុកងឺ ដូច្នេះពួកគេមានជំនាញក្នុងការធ្វើការក្នុងអាជីវកម្មបោកប្រាស់តាមទូរស័ព្ទ។ អ្នកស្រីបន្តថា ភាគច្រើនជនរងគ្រោះមិនទទួលបានប្រាក់ខែដូចដែលបានសន្យានោះទេ ខណៈអ្នកខ្លះទៀតមិនទទួលបានប្រាក់ខែទាល់តែសោះ។

"ក្រុមជួញដូរដំណើរធ្វើសកម្មភាពរបស់ពួកគេដោយប្រើគណនីក្លែងក្លែង និងគេហទំព័រខុសច្បាប់ ហើយបង្ហោះឱកាសការងារនៅក្រៅប្រទេសតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គម ដើម្បីបោកបញ្ឆោតយុវជននៅក្នុងប្រទេសម៉ា

ឡេស៊ី។ "ជនរងគ្រោះបានរាយការណ៍ពីការរំលោភបំពានលើរាងកាយធ្ងន់ធ្ងរដោយក្រុមអ្នកជួញដូរ។ នេះរួមបញ្ចូលទាំងការវាយដំ ឆក់ចរន្តអគ្គិសនី និងបង្អត់អាហារ។ លោកស្រីបានបន្ថែមថា៖ «ជនរងគ្រោះត្រូវបានបង្ខំឱ្យចូលទៅក្នុងបន្ទប់តូចមួយដែលពិបាកក្នុងការឈរ មិនមានពន្លឺ ដោយបង្អត់ទឹក និងអាហារអស់រយៈពេលច្រើនម៉ោង។ លោកស្រី Glorene បាននិយាយថា ក្រៅពីជនជាតិម៉ាឡេស៊ី ជនជាតិមកពីឥណ្ឌូនេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន ថៃ និងវៀតណាម ត្រូវបានគេកំណត់អត្តសញ្ញាណ បន្ថែមពីលើជនរងគ្រោះជាច្រើនមកពីក្រៅតំបន់អាស៊ាន រួមទាំងមកពីប្រទេសចិន ហុងកុង តៃវ៉ាន់ បង់ក្លាដែស ឥណ្ឌា ប៉ាគីស្ថាន អេត្យូពី កេនយ៉ា និងប្រេស៊ីល។

"ជនរងគ្រោះជាច្រើនក៏ត្រូវបាននគរបាល ឬអាជ្ញាធរអន្តោប្រវេសន៍ឃុំខ្លួនផងដែរ បន្ទាប់ពីបានជួយសង្គ្រោះ។ នៅកម្ពុជា ជនរងគ្រោះត្រូវបាននគរបាលឃុំខ្លួន និងសួរចម្លើយរហូតដល់មួយសប្តាហ៍»។ លោកស្រីបានបន្តថា ជនរងគ្រោះជួបភាពលំបាកទ្វេដងនៅមណ្ឌលឃុំឃាំងអន្តោប្រវេសន៍ ដោយបានចោទប្រកាន់មន្ត្រីអន្តោប្រវេសន៍ថាបានទាមទារថ្លៃគ្រែដេក និងអាហារ។ ទន្ទឹមនឹងនេះ ការឃុំខ្លួនយូរក៏បណ្តាលឱ្យជនរងគ្រោះត្រូវបានជួញដូរឡើងវិញផងដែរ។ «កាលពីខែតុលាឆ្នាំមុន នៅកម្ពុជា ជនរងគ្រោះដោយការជួញដូរជនជាតិចិនជាច្រើននាក់ដែលបានដោះលែងពីមជ្ឈមណ្ឌលអន្តោប្រវេសន៍បណ្តោះអាសន្នត្រូវបានបង្ខំឱ្យចូលរថយន្តភ្លាមៗ និងត្រូវបានគេដឹកទៅ ហើយជនរងគ្រោះមកពីប្រទេសម៉ាឡេស៊ីបានរាយការណ៍ថាគាត់បានរត់គេចខ្លួន ហើយទៅប៉ុស្តិ៍នគរបាលក្បែរនោះដើម្បីស្វែងរកជំនួយ។

លោកស្រីបានចោទប្រកាន់ថា៖ «នគរបាលបានជូនដំណឹងដល់អ្នកជួញដូរភ្លាមៗ ហើយបានប្រគល់ជនរងគ្រោះទៅឲ្យអ្នកជួញដូរដោយទទួលប្រាក់ចំនួន ៥.០០០ ដុល្លារអាមេរិក។ លោកស្រីបាបបន្ថែមថា ស្ថានទូតម៉ាឡេស៊ីនៅក្នុងប្រទេសទាំងនេះដឹងពីប្រតិបត្តិការបោកប្រាស់ទាំងនេះ ដោយសារអ្នកដែលរត់គេចខ្លួនបានស្វែងរកជំនួយដើម្បីត្រឡប់ទៅផ្ទះវិញ។ ក្នុងករណីមួយក្នុងប្រទេសកម្ពុជា លោកស្រីបាននិយាយថា ជនរងគ្រោះដែលរត់គេចខ្លួនបានស្វែងរកជំនួយពីស្ថានកុងស៊ុលដើម្បីត្រឡប់មកផ្ទះវិញ ខណៈលិខិតឆ្លងដែនរបស់គាត់ត្រូវបានក្រុមជួញដូរដកហូត។ ទោះជាយ៉ាងនេះក្តី បុគ្គលិកស្ថានទូតត្រូវបានគេចោទប្រកាន់ថា បានណែនាំជនរងគ្រោះឱ្យដាក់របាយការណ៍ទៅនគរបាលដោយរាយការណ៍ថាបាត់លិខិតឆ្លងដែន ដែលតាមពិតទៅបានដឹងថាលិខិតឆ្លងដែននោះត្រូវបានក្រុមជនពាលកាន់កាប់។ នេះមានន័យថា ទោះបីជាជនរងគ្រោះត្រូវបានឃុំខ្លួនផ្ទុយពីឆន្ទៈ គាត់ត្រូវបង់ពិន័យសម្រាប់ការស្នាក់នៅលើសកំណត់។ គាត់ក៏ត្រូវបានបង្ខំឱ្យបង់ប្រាក់ចំនួន $៣០ ដើម្បីទទួលបានច្បាប់ចម្លងនៃរបាយការណ៍នគរបាល ដើម្បីគាត់អាចទទួលបានលិខិតឆ្លងដែនថ្មី។ លោកស្រីបានបន្តថា "ជនរងគ្រោះបានត្អូញត្អែរថាគាត់ត្រូវបង់ប្រាក់សរុបចំនួន៧០០ ដុល្លារ តាមរយៈស្ថានទូតម៉ាឡេស៊ីសម្រាប់របាយការណ៍នគរបាល ការពិន័យអន្តោប្រវេសន៍ ការធ្វើដំណើរ និងឯកសារផ្សេងៗទៀត"។

ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជា លោក Datuk Eldeen Husaini Mohd Hashim បានប្រាប់កាសែតខ្មែរថាមស៍ថា "នៅក្នុងពិភពលោកបច្ចុប្បន្ន ការដោះស្រាយបញ្ហាប្រឈមណាមួយនឹងអាស្រ័យលើធាតុពាក់ព័ន្ធរបស់យើង រួមទាំងផ្នែកគោលការណ៍ការទូត។ ខ្ញុំជឿថា យើងគួរតែមើលឃើញអនាគតមិនមែនជាអ្វីដែលស្ថិតក្រោមការគ្រប់គ្រងរបស់យើងនោះទេ ប៉ុន្តែជាអ្វីដែលយើងអាចរៀបចំឱ្យកាន់តែប្រសើរឡើងតាមរយៈការខិតខំប្រឹងប្រែងជាក់ស្តែង និងសមូហភាព។ បើយើងរួបរួមគ្នា បញ្ហាបោកប្រាស់នេះនឹងត្រូវបានដោះស្រាយ និងលុបបំបាត់ជាអចិន្ត្រៃយ៍»។

អាជ្ញាធរកម្ពុជាដែលដឹងពីការចោទប្រកាន់នេះបានប្រាប់កាសែតខ្មែរថាមស៍ថា យើងបាននិយាយម្តងហើយម្តងទៀតថា គ្មានជនជាតិម៉ាឡេស៊ីត្រូវបានគេធ្វើទារុណកម្ម និងបដិសេធការចោទប្រកាន់ផ្សេងទៀតពីបទសំណូកនិងការបង់ប្រាក់ផ្សេងៗ។ "ម៉ាឡេស៊ីមានច្បាប់អន្តោប្រវេសន៍របស់ខ្លួន ដែលពលករខុសច្បាប់ត្រូវបានឃុំខ្លួនក្នុង

ស្ថានភាពដ៏អាក្រក់មុនពេលត្រូវបានធ្វើមាតុភូមិនិវត្តន៍ ហើយកម្ពុជាក៏មានច្បាប់ផ្ទាល់របស់ខ្លួន។ អង្គការមិនមែនរដ្ឋាភិបាលគួរដឹងគុណដែលពលរដ្ឋម៉ាឡេស៊ី៥នាក់ត្រូវបានដោះលែងហើយបានត្រឡប់ទៅវិញជាមួយនគរបាលម៉ាឡេស៊ី។ «អ្នកនៅសេសសល់នឹងអនុវត្តតាមក្រោយនៅពេលដែលការស៊ើបអង្កេតរបស់យើងត្រូវបានបញ្ចប់ ខណៈដែលការចោទប្រកាន់ជាច្រើនគ្រាន់តែជាការចោទប្រកាន់ប៉ុណ្ណោះ»។ *Malaysiakini/Khmer Times*

# ថ្ងៃទី០៧ ខែ កុម្ភៈ ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា<br>បន្តទទួលបានបណ្តឹង ៣ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៤នាក់

http://freshnewsasia.com/index.php/en/localnews/276602-2023-02-04-09-19-54.html 2023-02-04 04:19pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០២ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេសចំនួន ០៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧២៧ករណី មានមនុស្ស ១,៧៧១នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៦១សំណើ និងបិទសំណុំរឿង ២៣៩សំណើ (រកឃើញមនុស្ស ១,០៧៩នាក់, ឃាត់ខ្លួនជនសង្ស័យ ១២២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៧ករណី៕

## ហ្វីលីពីននឹងធ្វើមាតុភូមិនិវត្ត<br>ជនជាតិខ្លួនដែលត្រូវបានបង្ខំឲ្យធ្វើការជាអ្នកឆបោកគ្រីបតូនៅកម្ពុជា

https://www.khmertimeskh.com/501232903//?p=1232903 Khmer Times February 5, 2023

ក្រសួងការបរទេសបាននិយាយថា ខ្លួនបានដឹងអំពីជនជាតិហ្វីលីពីនដែលត្រូវបានគេជ្រើសរើសអោយធ្វើជាអ្នកបោកប្រាស់រូបិយបណ្ណគ្រីបតូនៅកម្ពុជា ខណៈដែលខ្លួនបានធានាដល់សាធារណជនថា រដ្ឋាភិបាលកំពុងរៀបចំដំណើរការធ្វើមាតុភូមិនិវត្តន៍របស់ពួកគេ។

អនុរដ្ឋលេខាធិការក្រសួងការបរទេស ទទួលបន្ទុកកិច្ចការពលករចំណាកស្រុក និងជាអ្នកនាំពាក្យ Teresita Daza បាននិយាយថា ទីភ្នាក់ងារកំពុងរៀបចំរួចហើយសម្រាប់ការវិលត្រឡប់របស់ជនរងគ្រោះហ្វីលីពីនមិនត្រឹមតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ ថែមទាំងនៅក្នុងតំបន់ផ្សេងទៀតនៃអាស៊ីអាគ្នេយ៍ផងដែរ។ លោកស្រីក៏បានលើកពី "ការងារក្លែងក្លាយ" ដែលត្រូវបានសន្យាដល់ប្រជាជនហ្វីលីពីន "នៅក្នុងប្រទេសមួយចំនួនដោយបានបង្ខំឱ្យធ្វើការនៅក្នុងប្រតិបត្តិការខុសច្បាប់ដូចជាការបោកប្រាស់តាមអ៊ីនធឺណិត" ។

Daza បាននិយាយថា "ក្រសួងការបរទេស តាមរយៈស្ថានទូតរបស់ខ្លួន នឹងសហការជាមួយអាជ្ញាធរមូលដ្ឋាន ដើម្បីនាំយកជនជាតិរបស់យើងពីកន្លែងនានាដូចជាកម្ពុជា ឡាវ និងមីយ៉ាន់ម៉ា"។ បន្ទាប់មក ក្រសួងការបរទេស បានណែនាំសាធារណជនឱ្យមានការប្រុងប្រយ័ត្ន និងអនុវត្តតាមនីតិវិធីចេញដោយនាយកដ្ឋានពលករ

ចំណាកស្រុក (DWM) និងទីភ្នាក់ងារការងារក្រៅប្រទេសហ្វីលីពីន (POEA) មុនពេលចាកចេញទៅធ្វើការនៅបរទេស។

កាលពីថ្ងៃទី១៨ ខែមករា ព្រឹទ្ធសមាជិក Risa Hontiveros បានលាតត្រដាងពីស្ថានភាពជនជាតិហ្វីលីពីនដែលត្រូវបានជ្រើសរើសដោយក្រុមម៉ាហ្វីចិនឱ្យមកធ្វើការនៅកម្ពុជា។ Hontiveros បានដឹងពីស្ថានការណ៍នេះ បន្ទាប់ពីជនរងគ្រោះម្នាក់បានស្វែងរកជំនួយ។ គេបានដឹងថា ជនជាតិហ្វីលីពីនទាំង៦នាក់នោះ ត្រូវបានបញ្ជូនទៅកាន់ប្រទេសហ្វីលីពីនវិញហើយ កាលពីសប្តាហ៍មុន។ *Manila Bulletin/Khmer Times*

## ប្រតិបត្តិការឆបោកដែលមានមូលដ្ឋាននៅកម្ពុជា ត្រូវបានគេចោទប្រកាន់ថាជា ឋាននរក

https://www.khmertimeskh.com/501232966//?p=1232966 Khmer Times February 5, 2023

ជនរងគ្រោះដែលត្រូវបានចោទប្រកាន់ថាត្រូវបានជួញដូរ វាយដំ និងឃុំឃាំងឆ្ងាយពីគ្រួសាររបស់គាត់នៅប្រទេសចិន Lu គឺជាមនុស្សម្នាក់ក្នុងចំណោមមនុស្សរាប់ពាន់នាក់នៅក្នុងប្រទេសកម្ពុជា ដែលត្រូវបានបង្ខំឱ្យធ្វើប្រតិបត្តិការបោកប្រាស់តាមអ៊ីនធឺណិត។ កូវីដ-១៩ បានធ្វើឱ្យកម្មករសំណង់បាត់បង់ការងារ ដូច្នេះហើយនៅពេលដែលគាត់បានលឺថា គាត់អាចរកប្រាក់ចំណូលបាន ២,០០០ ដុល្លារក្នុងមួយខែនៅក្នុងគម្រោងសាងសង់មួយក្នុងប្រទេសកម្ពុជា គាត់ក៏បានចាប់យកឱកាសនេះ។ ប៉ុន្តែភ្លាមៗនោះ គាត់បានដឹងថា គាត់បានចាញ់បោកក្រុមជនពាល អោយទៅធ្វើការក្នុងបរិវេណទីតាំងមួយក្នុងក្រុងព្រះសីហនុ រួមជាមួយមនុស្សរាប់រយនាក់ទៀត។ នៅទីនោះ គាត់ត្រូវបានគេបង្ខំឱ្យធ្វើការពី១២ ទៅ១៦ ម៉ោង នៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម និងកម្មវិធីណាត់ជួប ដើម្បីស្វែងរកជនរងគ្រោះបោកប្រាស់យកលុយ។

Lu បានប្រាប់ទីភ្នាក់ងារសារព័ត៌មានបារាំង AFP ថា "នៅពេលដែលខ្ញុំមកដល់ គឺយឺតពេលទៅហើយក្នុងការរត់គេច" ។ "ប៉ុន្តែដរាបណាខ្ញុំនៅមានជីវិត ខ្ញុំនឹងបន្តព្យាយាម"។ ប្រជាជនមកពីបណ្តាប្រទេសជុំវិញអាស៊ី រួមទាំងវៀតណាម ហ្វីលីពីន ថៃ ម៉ាឡេស៊ី ចិន តៃវ៉ាន់ ហុងកុង បង់ក្លាដែស និងឥណ្ឌា ត្រូវបានធ្លាក់ចូលទៅក្នុងប្រតិបត្តិការស្រដៀងគ្នានេះ។ អ្នកខ្លះដូចជា Lu អាយុ៣៤ឆ្នាំបានរត់ចេញរួច ដោយមនុស្សរាប់ពាន់នាក់ផ្សេងទៀតត្រូវបានបន្តនៅជាប់ឃុំ។

កាលពីខែសីហាឆ្នាំមុន លោក Vitit Muntarbhorn អ្នករាយការណ៍ពិសេសរបស់អង្គការសហប្រជាជាតិទទួលបន្ទុកស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជាបាននិយាយថា ជនរងគ្រោះដោយការជួញដូរ "ទទួលរងនូវការធ្វើទារុណកម្ម និងអាចស្លាប់"។ ក្រុងព្រះសីហនុ ធ្លាប់ជាទីក្រុងរមណីយដ្ឋានមានភាពស្ងប់ស្ងាត់ ប៉ុន្តែបានផ្លាស់ប្តូរដោយការហូរចូលនៃការវិនិយោគរបស់ចិនយ៉ាងច្រើន។ កាស៊ីណូជាច្រើនបានលេចឡើងក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ដែលធ្វើឱ្យតំបន់នេះក្លាយជាមជ្ឈមណ្ឌលសម្រាប់អ្នកលេងល្បែងជនជាតិចិន និងទាក់ទាញក្រុមជនពាលអន្តរជាតិ។ នៅពេលដែលមានការរឹតបន្តឹងក្នុងអំឡុងពេលជំងឺរាតត្បាត ក្រុមទាំងនេះបានផ្លាស់ប្តូរយុទ្ធសាស្ត្រ។

លោក Jeremy Douglas មកពីការិយាល័យអង្គការសហប្រជាជាតិប្រឆាំងគ្រឿងញៀន និងឧក្រិដ្ឋកម្ម (UNODC) បាននិយាយថា "ក្រុមឧក្រិដ្ឋជនបានផ្លាស់ប្តូរអាជីវកម្មកាស៊ីណូតាមអ៊ិនធឺណិត ហើយមួយចំនួនទៀតបានបោកប្រាស់តាមអ៊ីនធឺណិត និងតាមទូរស័ព្ទ"។ សមាជិកក្រុមជនពាលម្នាក់បានប្រាប់ AFP ក្នុងលក្ខខណ្ឌអនាមិកថា មនុស្សដំបូងគេដែលធ្លាក់ចូលទៅក្នុងប្រតិបត្តិការដូចជាគាត់គឺជាពលរដ្ឋចិនដែលរស់នៅក្នុងប្រទេសកម្ពុជា។ បន្ទាប់មក ក្រុមជនពាលបានចាប់ផ្តើមជួញដូរមនុស្សចូលក្នុងប្រទេស។ លោក Douglas បានបន្តថា "រាប់ពាន់នាក់ ហើយអ្នកខ្លះបានប៉ាន់ស្មានថា ប្រហែលជារាប់ម៉ឺននាក់" ត្រូវបានជាប់ឃុំ។ ដើម្បីមិនអោយជនរងគ្រោះអាចរត់គេចខ្លួនបាន ទីតាំងទាំងនោះត្រូវរុំព័ទ្ធដោយលួសបន្លា និងចំរឹងបង្អូចដែក។ សមាជិកក្រុមជនពាលនោះបានបន្តថា

៖ «នៅពេលពួកគេមកដល់ក្នុងបរិវេណនោះ ពួកគេមិនអាចចាកចេញបានទេ។ មនុស្សត្រូវបានគេវាយដំ ឬធ្វើទារុណកម្ម ហើយលក់ ប្រសិនបើពួកគេមិនព្រមបោកប្រាស់អ្នកដទៃ។ ប្រភពដដែលបន្តថា នៅក្នុងប្រទេសកម្ពុជាខ្លះត្រូវបានគេលក់ទៅឲ្យក្រុមជនពាលផ្សេងទៀត។ អ្នកដែលមានចំណេះដឹងខាងផ្នែកបច្ចេកវិទ្យាព័ត៌មាន ឬជំនាញភាសាអង់គ្លេសអាចលក់បានរហូតដល់ ៥០,០០០ ដុល្លារ។

AFP បានសម្ភាសជនរងគ្រោះ៤នាក់ពីការជួញដូរដោយពួកគេបាននិយាយថាពួកគេក៏ទទួលបានការផ្តល់ជូនការងារនេះក្នុងអំឡុងពេលជំងឺរាតត្បាត។ បុរសជនជាតិម៉ាឡេស៊ីអាយុ៣៨ ឆ្នាំម្នាក់ឈ្មោះ Roy បានរៀបរាប់ថាជិះយន្តហោះមកភ្នំពេញ ហើយត្រូវបាននារីម្នាក់ជួយសម្របសម្រួលគាត់នៅផ្នែកអន្តោប្រវេសន៍ ហើយបានជិះឡានរយៈពេលប្រាំម៉ោងទៅខេត្តព្រះសីហនុ។ នៅទីនោះ គាត់ត្រូវបានគេនាំទៅអគារអាផាតមិនដែលមានកម្ពស់រាប់សិបជាន់។ Roy បានប្រាប់ AFP ថា "វាមើលទៅដូចជាការិយាល័យធម្មតា ដែលមានតុបីជួរមានម៉ូនីទ័រ និងក្តារចុច ដូចហាងកាហ្វេអ៊ីនធឺណេត"។ ប៉ុន្តែគាត់បាននិយាយថា "ពេលចាប់ផ្តើមធ្វើ យើងដឹងថានេះមិនមែនការងារផ្តល់សេវាអតិថិជន"។ Roy និងអ្នកផ្សេងទៀតត្រូវបានដកហូតលិខិតឆ្លងដែន ហើយត្រូវបានណែនាំឱ្យបង្កើតគណនីក្លែងក្លាយនៅលើកម្មវិធី និងគេហទំព័រណាត់ជួបរួមទាំង TikTok Facebook Instagram និង WhatsApp ។

នៅក្រោមការគំរាមកំហែងឥតឈប់ឈរនៃអំពើហឹង្សា ពួកគេត្រូវបោកជនរងគ្រោះផ្សេងទៀតអោយបណ្តាក់ទុនទៅក្នុងរូបិយប័ណ្ណគ្រីបតូ ឬវេទិកាវិនិយោគផ្សេងទៀត។ អ្នកផ្សេងទៀតត្រូវបានបង្ខំឱ្យបង្កើតទំនាក់ទំនង "ស្នេហា" តាមអ៊ីនធឺណិតដើម្បីបោកប្រាស់អ្នកផ្សេងទៀត។ មិនមានតួលេខដែលអាចជឿទុកចិត្តបានអំពីចំនួនប្រាក់ដែលក្រុមជនពាលបានរកបានពីការឆបោកនោះទេ ទោះបីជាលោក Douglas បាននិយាយថាចំនួននេះ "គឺច្រើន" ក៏ដោយ។ លោកបានបន្ថែមថា វាមិនច្បាស់ថាលុយទៅទីណានោះទេ ទោះបីជាប្រាក់ទទួលបានពីឧក្រិដ្ឋកម្មច្រើនតែត្រូវបានប្រមូលផ្តុំរួមជាមួយនឹងប្រាក់ចំណេញនៃការភ្នាល់តាមអ៊ីនធឺណែត ជាមួយនឹងទីតាំងឆបោកជាច្រើនដែលនៅជិតអាជីវកម្មល្បែងស្របច្បាប់។

សមាជិកក្រុមជនពាលនៅខេត្តព្រះសីហនុបានប្រាប់ AFP ថា គាត់មិនបានដឹងថាគាត់ធ្វើការអោយអ្នកណាអោយប្រាកដនោះទេ។ "យើងមិនដឹងថានរណាជានរណាទេ"។ "ពួកគេជាម៉ាហ្វីយ៉ាពិតប្រាកដ"ជនរងគ្រោះដែលប្រកែកមិនធ្វើតាម និងទទួលរងការធ្វើបាន។ Lu បាននិយាយថាគាត់ត្រូវបានគេ "វាយដំជាញឹកញាប់" ដោយសារតែគាត់បានព្យាយាមរត់គេច។ អ្នកផ្សេងទៀតបាននិយាយថា ជនរងគ្រោះត្រូវបានគេចក់ ឬឃុំនៅក្នុងបន្ទប់តូចពេកដែលមិនអាចឈរបាន ដោយបង្អត់ទឹក អាហារ និងពន្លឺរាប់ម៉ោង។ Roy បាននិយាយថា៖ «ពួកយើងត្រូវបានគេទាត់ដូចឆ្កែ។ "ជួនកាល [ពួកគេ] ឆក់ ទាត់។ ពួកគេនឹងវាយយើងពី៥ នាទីទៅ១០ នាទី" ។ បន្ទាប់ពីត្រូវបានគេប្រាប់ថាគាត់ត្រូវបង់ប្រាក់២០,០០០ ដុល្លារជាថ្នូរនឹងការដោះលែង គាត់ត្រូវបានជួយសង្គ្រោះបន្ទាប់ពីបានទាក់ទងទៅអង្គការប្រឆាំងការជួញដូរសកល (GASO) ។ ក្រុមនេះធ្វើការជាមួយមន្ត្រីកម្ពុជាដើម្បីសម្រួលដល់ការជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍។ អ្នកផ្សេងទៀតបានព្យាយាមរត់ដោយប្រើវិធីផ្សេងទៀត៖ ដូចជាក្នុងខែសីហា កម្មករវៀតណាមរាប់សិបនាក់បានរត់គេចពីកាស៊ីណូមួយនៅខេត្តកណ្តាល ដោយហែលឆ្លងទន្លេទៅកាន់ប្រទេសកំណើតរបស់ពួកគេ។

នៅពេលព្រឹត្តិការណ៍នេះបានកើនឡើង៖ សហរដ្ឋអាមេរិកក្នុងខែកក្កដា ឆ្នាំ ២០២២ បានទម្លាក់ចំណាត់ថ្នាក់ប្រទេសកម្ពុជានៅក្នុងរបាយការណ៍ប្រចាំឆ្នាំរបស់ខ្លួនស្តីពីការជួញដូរមនុស្ស។ បន្ទាប់មក លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានបញ្ជាឱ្យតាមប្រមាញ់មេខ្លោង និងបញ្ជាអោយវាយឆ្មក់ដ៏ធំមួយនៅក្នុងខែសីហា ឆ្នាំ២០២២។ ក្នុងខែកញ្ញា ឆ្នាំ២០២២ នគរបាលបានដោះលែងជនបរទេសជាង១ពាន់នាក់ ចេញពីបរិវេណក្រុងព្រះសីហនុចំនួន៣ទីតាំង។ នៅទីតាំងមួយ បានរឹបអូសកទូរស័ព្ទដៃជិត ៩,០០០ គ្រឿង កុំព្យូទ័រ៨០០ គ្រឿ ខ្នោះដៃ និងឧបករណ៍ឆក់អគ្គិ

សនី។ វាគឺអំឡុងពេលការវាយឆ្មក់មួយដែល Lu ត្រូវបានគេដោះលែង។ លោកបានបន្តថា៖ «ការចាប់ក្រុមជនពាលអោយមកទទួលខុសត្រូវមុខច្បាប់គឺមានសារៈសំខាន់ណាស់ប្រសិនបើយើងសង្ឃឹមថា នឹងលុបបំបាត់បញ្ហានេះ»។ មានការព្រួយបារម្ភថា បន្ទាប់ពីបិទទីតាំងមួយចំនួន ក្រុមទាំងនោះបានផ្លាស់ប្តូរទៅទីតាំងថ្មី។

លោក Douglas បាននិយាយថា "ថ្ងៃនេះ វាគឺជាប្រតិបត្តិការមួយនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែថ្ងៃស្អែក ក្រុមជនពាលទាំងនោះនឹងទៅប្រទេសមីយ៉ាន់ម៉ា ឡាវ ឬហ្វីលីពីន ហើយរឿងទាំងនេះពិតជាបានកើតឡើងមែន"។ ត្រលប់មកប្រទេសកម្ពុជាវិញ អ្នកដែលត្រូវបានជួយសង្គ្រោះដោយនគរបាល ដូចជា Lu ប្រឈមនឹងអនាគតមិនច្បាស់លាស់។ ខណៈដែលគាត់បានគេចពីការឃុំខ្លួនជនអន្តោប្រវេសន៍ គាត់បានប្រាប់ AFP ថា គាត់មិនមានលទ្ធភាពត្រឡប់ទៅកេប្រពន្ធ និងកូនអាយុ ៩ ឆ្នាំរបស់គាត់នៅប្រទេសចិនវិញទេ។

អ្នកនាំពាក្យក្រសួងការបរទេសចិនបានប្រាប់ AFP ថា រដ្ឋាភិបាលកំពុងធ្វើការជាមួយកម្ពុជា និងប្រទេសដទៃទៀត ដើម្បីប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ហើយ«រក្សាយ៉ាងម៉ឺងម៉ាត់នូវសុវត្ថិភាព និងសិទ្ធិស្របច្បាប់របស់ពលរដ្ឋចិននៅបរទេស»។ បើតាម Lu គាត់មិនបានទទួលជំនួយពីស្ថានទូតចិនទេ។ លោកបានបន្តថា៖ «ស្ថានទូតចិនបាននិយាយថា៖ «មនុស្សពេញវ័យត្រូវទទួលខុសត្រូវលើការសម្រេចចិត្តរបស់ខ្លួន»។

ខ្មែរថាមស៍ តាមរយៈការស៊ើបអង្កេតមូលដ្ឋានរបស់ខ្លួនចាប់តាំងពីខែសីហា ឆ្នាំ២០២១ បានរកឃើញថា ខណៈដែលផ្នែកតូចមួយនៃការអះអាងទាំងនេះពីការធ្វើទារុណកម្ម និងការវាយដំគឺជាការពិត ប៉ុន្តែមនុស្សជាច្រើនផ្សេងទៀតធ្វើឡើងដើម្បីទទួលបានការអាណិតអាសូរជាសាធារណៈ និងពន្លឿនការចាកចេញរបស់ពួកគេពីទីតាំងទាំងនោះ។ ហេតុផលរបស់ពួកគេមានភាពខុសប្លែកគ្នា អ្នកខ្លះមិនចូលចិត្តនឹងអាហារដែលពួកគេត្រូវបានផ្តល់ ការបន្តការបង្ខាំងមនុស្ស មិនអាចទំនាក់ទំនងតាមទូរស័ព្ទ មិនអាចបំពេញការងារដែលបានដាក់អោយដើម្បីទទួលបានប្រាក់បៀវត្សរ៍ដែលបានសន្យារបស់ពួកគេ។ល។ ខ្មែរថាមស៍ បានអោយដឹងទៀតថាទោះជាយ៉ាងនេះក្តី មនុស្សជាច្រើនត្រូវបានជួយសង្គ្រោះ និងខ្លះត្រូវបានសង្គ្រោះ គឺជាមេដឹកនាំក្រុមអ្នកបោកប្រាស់ ដែលបានក្លាយជា "ទាសករ" រត់គេចខ្លួន ហើយពេលត្រឡប់មកប្រទេសកំណើតវិញ បានទៅបោកអ្នកផ្សេងទៀត ឱ្យមកកន្លែងទាំងនេះដែល ពួកគេអះអាងថាជានរក។

នគរបាលម៉ាឡេស៊ីក្នុងអំឡុងពេលសហការរបស់ពួកគេជាមួយនគរបាលកម្ពុជា បានដឹងពីរឿងនេះរួចហើយ ហើយបាននិយាយដូច្នេះនៅក្នុងសន្និសីទសារព័ត៌មានមួយកាលពីពេលថ្មីៗនេះ។ បោះពុម្ពលើកដំបូងដោយកាសែត Manila Times ។ AFP និង ខ្មែរថាមស៍

## ពលករខ្មែរមួយចំនួននៅប្រទេសថៃដាច់ស្បៀង ក្រោយពីថៅកែមិនបើកលុយឱ្យ

https://www.rfa.org/khmer/news/economy/a-group-of-cambodia-workers-working-in-thailand-ran-out-of-food-after-their-employers-did-not-pay-them-for-months-02052023173728.html ដោយ ជី វិតា 2023.02.05

ពលករខ្មែរធ្វើការនៅប្រទេសថៃមួយចំនួនដាច់ស្បៀងអាហារ ដោយសារថៅកែមិនបានបើកប្រាក់ឈ្នួលឱ្យពួកគាត់ អស់រយៈពេលពីរខែមកហើយ។ មន្ត្រីសង្គមស៊ីវិលថា រដ្ឋាភិបាលគួរតែជួយអន្តរាគមន៍ដល់ពលករទាំងនោះជាបន្ទាន់ ដើម្បីពួកគាត់បានប្រាក់ទិញស្បៀងអាហារហូបចុកប្រចាំថ្ងៃ។ ពលករខ្មែរដែលធ្វើការនៅប្រទេសថៃលើកឡើងថា ពួកគាត់ដាច់ស្បៀងអាហារអស់រយៈពេល២ខែមកហើយ ពោលគឺចាប់តាំងពីថៅកែថៃមិនបើកប្រាក់ឈ្នួលដល់ពួកគាត់រហូតមក។ពួកគាត់បារម្ភថាបើសិនជាថៅកែមិនបើកឱ្យបានឆាប់ៗ ទេនោះទេ អាចនឹងមានជីវភាពកាន់តែលំបាកជាងនេះ ដែលអាចនឹងប៉ះពាល់ដល់សុខភាព ជាពិសេសប៉ះពាល់ការលូតលាស់របស់កុមារ។

នៅក្នុងបន្ទប់ដ៏តូចមួយដែលមានគ្នា៥នាក់ ភាគច្រើនជាស្ត្រី និងកូនក្មេងផងនោះ លោកស្រី មាន សារៀម ដែលបច្ចុប្បន្នមកធ្វើការសំណង់នៅខេត្តសាមុតប្រាកាន ប្រទេសថៃ (Samut Prakan) អស់រយៈពេលជាង៥ខែ ជាកម្មករសំណង់។ លោកស្រីអាចរកចំណូលបានជាង៣រយបាត (៣០០បាត) ក្នុងមួយថ្ងៃ ដើម្បីចិញ្ចឹមកូន៣នាក់ និងសល់លុយខ្លះផ្ញើទៅឱ្យអ្នកផ្ទះនៅឯស្រុកដើម្បីសងបំណុលធនាគារ។ លោកស្រីប្រាប់វិទ្យុអាស៊ីសេរីនៅថ្ងៃទី៥ ខែកុម្ភៈថា ឥឡូវនេះ លោកស្រីគ្មានលុយសម្រាប់ទិញបាយហូបនោះទេ ដោយសារតែថៅកែមិនបើកលុយឱ្យអស់រយៈពេល២ខែមកហើយ៖

*«ពិបាកនឹងឯងយើងជំពាក់គេនៅឯស្រុកផង ហើយមិនមានលុយឱ្យគេ ម៉ែឪនៅឯផ្ទះក៏ឈឺ ហើយយើងយកកូនមកក៏មិនបានរៀនបានសូត្រ។ ចំណាយច្រើន យើងធ្វើការតែពីនាក់ហើយ កូនដេកស៊ី កូនក្មេងវាដែលដូចយើងមនុស្សធំ បើវាទា (សុំញ៉ាំ) គឺទាយកតែពីបាន ដល់ពេលអត់តាំងយំរំពង»*។

អ្នកខេត្តបន្ទាយមានជ័យរូបនេះ រៀបរាប់ទាំងអស់សង្ឃឹមថា ពេលខ្លះបើថៅកែ បើកលុយឱ្យ១ពាន់បាត ស្មើនឹងជាង១០ម៉ឺនរៀល គឺគ្រាន់ទុកទិញអាហារហូបចុកបន្តិចបន្តួចព្រឹកល្ងាច ដើម្បីរស់នៅតែប៉ុណ្ណោះ។ លោកស្រីបន្តថា មិនដឹងត្រូវធ្វើបែបណានោះទេ បើសិនជាជូនដំណឹងដល់ស្ថានទូតខ្មែរនៅប្រទេសថៃ ខ្លាច ប៉ូលិសថៃចាប់ពួកគាត់បញ្ជូនមកខ្មែរវិញ ព្រោះលោកស្រី និងពលករមួយចំនួនទៀតធ្វើការដោយខុសច្បាប់ ព្រោះមិនមានលុយធ្វើលិខិតឆ្លងដែន ឬប៉ាស្ប័រ និងប័ណ្ណការងារទេ។

ស្រដៀងគ្នានេះដែរ ពលករម្នាក់ទៀត គឺលោកស្រី ចុង ម៉ៅ ដែលនៅក្បែរនឹងលោកស្រី មាន សារៀម ដែរនោះ លើកឡើងថា លោកស្រីមិនអាចត្រឡប់ទៅប្រទេសខ្មែរវិញបានទេ ព្រោះលោកស្រីជំពាក់លុយបងប្អូន និងធនាគារ ដែលតម្រូវឱ្យលោកស្រីត្រូវប្រឹងប្រែងរកចំណូល ដូច្នេះលោកស្រីមានតែតស៊ូលំបាករង់ចាំ ថៅកែបើកលុយឱ្យ។ ទោះយ៉ាងណា លោកស្រីទទូចឱ្យស្ថានទូតខ្មែរជួយសម្រួលដល់ពួកគាត់ក្នុងការធ្វើប៉ាស្ប័រ និងប័ណ្ណការងារក្នុងតម្លៃទាប ដើម្បីឱ្យពួកគាត់អាចរស់នៅដោយស្របច្បាប់នៅប្រទេសថៃ។ *«ខ្ញុំជួបផលលំបាកតែរឿងអត់ហូប អត់បាយអត់លុយ ហើយមានកូនក្មេងតូចៗផង។ ចង់ឱ្យបងៗជួយរកការងារថ្មី ឱ្យពួកខ្ញុំធ្វើខ្លាចទៅកន្លែងផ្សេងគេធ្វើប៉ាស្ប័រឱ្យ។ ថៅកែកាលពីមុនៗលុយគាត់ចេញ ដល់ពេលចូលមកដល់ខែនេះ មិនដឹងម៉េចគាត់ខាតគាត់អីក៏មិនដឹងគាត់មិនមានលុយបើកឱ្យ»*។

អ្នកស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យរូបនេះអះអាងថា ពលករខ្មែរដែលធ្វើការសំណង់ដោយខុសច្បាប់ជាមួយនឹងលោកស្រីនៅខេត្តសាមុតប្រាកាននេះមានជាង២០គ្រួសារ ដែលមានចំនួនមនុស្សចាស់ជិត៣០នាក់ និងមានកុមារ៥នាក់។ លោកស្រីថា ភាគច្រើនជាអ្នកមកពីខេត្តបន្ទាយមានជ័យ ហើយពួកគាត់រស់នៅដោយការភ័យខ្លាចប៉ូលិសថៃចាប់។

វិទ្យុអាស៊ីសេរីមិនអាចទាក់ទងរដ្ឋលេខាធិការក្រសួងការងារ លោក ហេង សួរ និងមន្ត្រីស្ថានទូតខ្មែរប្រចាំទីក្រុងបាងកក ដើម្បីសុំអត្ថាធិប្បាយជុំវិញបញ្ហាពលករដាច់ស្បៀងនេះ បានទេនៅថ្ងៃទី០៥ ខែមករា ដោយហៅទូរស័ព្ទចូលតែគ្មានអ្នកទទួល។

ជុំវិញរឿងនេះ មន្ត្រីផ្នែកអន្តោប្រវេសន៍ប្រចាំប្រទេសថៃ នៃអង្គការសង់ត្រាល់ (Central) លោក លឹង សុផុន មានប្រសាសន៍ថា កាលពីថ្មីៗនេះ លោកបានទៅជួបនឹងពលករជាង២០គ្រួសារ នោះហើយ ដោយលោកសង្កេតឃើញថា ពលករភាគច្រើនខ្វះខាត ហើយគ្មានលុយទិញបាយហូបចុកឱ្យបានត្រឹមត្រូវ។ លោកថា បញ្ហានេះមិនមែនទើបតែមានទេ គឺមានស្ទើរតែគ្រប់កន្លែងឱ្យតែ មានពលករខ្មែរធ្វើការ ដោយសារភាគច្រើនពួកគេចាញ់បោកមេខ្យល់។ លើសពីនេះ លោកទទូចស្ថានទូតខ្មែរប្រចាំនៅប្រទេសថៃ ជួយដោះស្រាយបញ្ហាអត់ស្បៀងដល់ពលករខ្មែរឱ្យបានទាន់ពេលវេលា ដើម្បីជួយសម្រួលដល់ការរស់នៅរបស់ពួកគាត់៖

*«ខាងរដ្ឋាភិបាលគាត់គួរតែមានវិធានការជួយជ្រុងជ្រែង ជួយអប់រំពលករតាមតំបន់ឱ្យពួកគាត់យល់ដឹងបន្ថែមអំពីការធ្វើយ៉ាងម៉េច ឱ្យយើងនឹងមានសិទ្ធិពេញលេញមានសិទ្ធក្នុងការធ្វើការងារដោយស្របច្បាប់នៅស្រុកគេ។ សូមបញ្ជាក់បន្ថែមថា បើសិនជាវិធានការណាមួយដើម្បីឱ្យបងប្អូនយើង វាជារឿងល្អជាពិសេសសម្រាប់បងប្អូនយើងពលករ»*។

របាយការណ៍របស់ក្រសួងការងារកម្ពុជា ឱ្យដឹងថា បច្ចុប្បន្ន មានពលករខ្មែរជាង ១លាន ២សែននាក់កំពុង ធ្វើការនៅប្រទេសថៃ។ ប៉ុន្តែរបាយការណ៍របស់អង្គការ (Central) បង្ហាញថា មានពលករខ្មែរកំពុង ធ្វើការដោយស្របច្បាប់ និងមិនស្របច្បាប់នៅប្រទេសថៃប្រមាណ ២លាននាក់ ដោយមួយចំនួនពួកគាត់ទទួលរងការរំលោភបំពានសិទ្ធិការងារ និងបាត់បង់ផលប្រយោជន៍ ដែលប៉ះពាល់ដល់បញ្ហាផ្នែកសេដ្ឋកិច្ចគ្រួសារ។ អ្នកឃ្លាំមើលបញ្ហាសង្គមនៅកម្ពុជា សង្កេតឃើញថាបញ្ហាចំណាកស្រុក ដោយខុសច្បាប់របស់ពលករខ្មែរកើតមានជាច្រើនឆ្នាំមកនេះ ជាចំណុចដែលរដ្ឋាភិបាលគួរយកចិត្តទុកដាក់ខ្ពស់។ ពួកគេបារម្ភថា កន្លងមករដ្ឋាភិបាលហាក់មិនសូវយកចិត្តទុកដាក់ដោះស្រាយនោះទេ ដែលធ្វើឱ្យពលរដ្ឋនៅតែបន្តឆ្លងដែនដោយខុសច្បាប់ទៅរកការងារធ្វើនៅក្រៅប្រទេស ដោយសារតែពួកគេមានជីវភាពខ្វះខាត ខណៈដែលតម្លៃឯកសារផ្សេងៗ និងលិខិតឆ្លងដែនមានតម្លៃខ្ពស់ ហួសពីលទ្ធភាពរបស់ពួកគាត់។ ដូច្នេះពួកគេ ទទូចឱ្យអាជ្ញាធរកម្ពុជា សហការនឹងអាជ្ញាធរថៃជួយសម្រួលក្នុងការធ្វើលិខិតឆ្លងដែនក្នុងតម្លៃទាបសមរម្យដែលពលរដ្ឋខ្មែរអាចធ្វើបាន និងជួយឧបត្ថម្ភស្បៀងកំឡុងពេលដែលពួកគាត់កំពុងខ្វះខាតដូចពេលនេះ។ ពលករចំណាកស្រុកធ្វើការនៅប្រទេសថៃភាគច្រើនលើកឡើងថា ការធ្វើចំណាកស្រុកទៅក្រៅប្រទេសឃ្លាតឆ្ងាយពីគ្រួសារ ដោយសារតែគ្មានការងារធ្វើនៅកម្ពុជា ឬការងារក្នុងស្រុកបានប្រាក់ចំណូលទាប បើធៀបនឹងប្រទេសថៃ៕

## ចាប់បានឈ្មួញកណ្ដាលនាំពលរដ្ឋថៃទៅធ្វើការនៅកូរ៉េខាងត្បូង

https://kbn.news/archives/287124 February 6, 2023

ប្រទេសថៃ ៖ កាលពីថ្ងៃទី៣ ខែកុម្ភៈ កន្លងមក ក្រសួងការបរទេសថៃបានជូនដំណឹងដល់ពលរដ្ឋថៃនៅប្រទេសកូរ៉េខាងត្បូង ដែលលួចចូលធ្វើការខុសច្បាប់ឱ្យទៅបង្ហាញខ្លួននៅការិយាល័យប៉ូលិសអន្តោប្រវេសន៍កូរ៉េខាងត្បូង ត្រឹមថ្ងៃទី២៨ ខែកុម្ភៈ នេះ ។ បើហួសកំណត់ ពួកគេនឹងត្រូវបានពិន័យជាប្រាក់៣០លានវ៉ុន ឬប្រមាណ៨សែនបាត ។ ក្រោយមក នៅថ្ងៃទី៤ ខែកុម្ភៈ ប៉ូលិសបានចាប់ខ្លួនស្រីឈ្មួញកណ្ដាលជនជាតិថៃ ដែលបោកប្រាស់ពលករថៃទៅធ្វើការនៅកូរ៉េខាងត្បូង ជាដំបូងរកឃើញថា មានអ្នកចាញ់បោកជាង៥០នាក់ ។

ស្រីឈ្មួញកណ្ដាលរូបនេះឈ្មោះ អ៊ីន ថុន ត្រូវបានប៉ូលិសចាប់ខ្លួននៅផ្ទះលេខ៤/៣ ឃុំហ្វាហ្វាំង ស្រុកម៉ែព្រិក ខេត្តឡាំប៉ាង ដោយស្ត្រីរូបនេះអះអាងថា នឹងនាំពលករថៃទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូង ហើយអ្នកជឿ ក៏ព្រមផ្ទេរប្រាក់ថ្លៃរត់ការឯកសារចាប់ពីរាប់ម៉ឺនបាត ដល់រាប់សែនបាតឱ្យនាង ។ តាមការសាកសួរបឋម ស្ត្រីជាប់ចោទបានយល់ព្រមសារភាព ហើយប៉ូលិសនឹងចាត់វិធានការតាមច្បាប់បន្តទៀត ។ កាលពីខែកក្កដា ឆ្នាំ២០២២ កន្លងមក មានអ្នកចាញ់បោកស្ត្រីខាងលើនេះជាច្រើននាក់បានមកដាក់ពាក្យបណ្ដឹងនៅប៉ុស្តិ៍ប៉ូលិស ក្នុងករណីឆបោកប្រជាពលរដ្ឋ និងបោកបញ្ឆោតមនុស្សទៅធ្វើការនៅក្រៅប្រទេស ។ ជនរងគ្រោះនិយាយថា ស្ត្រីរូបនេះអះអាងថាខ្លួនអាចនាំពលករថៃទៅធ្វើការនៅប្រទេសកូរ៉េខាងត្បូងបាន ដោយទាមទារប្រាក់ដល់ខ្ទង់សែនបាត ដោយនិយាយថា ប្រាក់នេះសម្រាប់ធានារ៉ាប់រងលើការធ្វើដំណើរ ប៉ុន្តែពលរដ្ឋថៃទាំងនោះមិនបានទៅធ្វើការពិតប្រាកដឡើយ ខណៈពួកគេបានផ្ទេរប្រាក់ទៅឱ្យនាងរួចហើយ ប៉ុន្តែមិនអាចទាក់ទងបានទៀត ។

ប៉ូលិសបានសាកសួរទៅកាន់ការិយាល័យកណ្តាលផ្នែកចុះឈ្មោះរកការងារ និងការពារសិទ្ធិអ្នករកការងារធ្វើ ដើម្បីស្វែងរកប្រវត្តិស្ត្រីឈ្មោះ អ៊ីន ថុន ។ តាមការស្រាវជ្រាវបង្ហាញថា ស្ត្រីឈ្មោះ អ៊ីន ថុន មិនបានទទួលការអនុញ្ញាតដើម្បីរកការងារឱ្យពលករថៃទៅធ្វើការនៅក្រៅប្រទេស និងមិនបានចុះឈ្មោះជាឈ្មួញកណ្តាលទេ ។ តាមទិន្នន័យរបស់នាយកដ្ឋានស្វែងរកការងារបង្ហាញថា មានជនរងគ្រោះចំនួន១៦នាក់បានទៅតវ៉ា ដោយសារពួកគេម្នាក់ៗចំណាយប្រាក់អស់៤សែនបាត ហើយគ្មានការងារធ្វើ ៕

# ថ្ងៃទី០៨ ខែ កុម្ភៈ ឆ្នាំ២០២៣

## ពិរុទ្ធជនចិន៣នាក់ សុំតុលាការកំពូល ដោះលែងក្រៅឃុំ ជាប់ពាក់ព័ន្ធនឹង បទល្មើសជួញដូរមនុស្ស និងចាប់បង្ខាំងមនុស្សដើម្បីជំរិតទារប្រាក់

https://cen.com.kh/archives/614090.html Posted ByPen Srey NeatFebruary 6, 2023

ភ្នំពេញៈ តុលាការកំពូលកាលពីព្រឹក ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០២៣ នេះ បានបើកសវនាការជំនុំជម្រះលើកបណ្តឹងសាទុក្ខ ស្នើសុំស្ថិតនៅក្រៅឃុំបណ្តោះអាសន្ន របស់ជនជាប់ចោទ ជនជាតិចិនចំនួន ៣នាក់ ដែលត្រូវបានតុលាការថ្នាក់ក្រោម ចាប់ខ្លួនដាក់គុក បណ្តោះអាសន្ន ជាប់ពាក់ព័ន្ធនឹងការ ជួញដូរមនុស្ស និងចាប់ឃុំឃាំង និងប.ង្ខាំង មនុស្សដោយខុសច្បាប់ ដើម្បីជំរិតទារប្រាក់ ប្រព្រឹត្តនៅ អគារជីងឆាយ នៅភូមិ២ សង្កាត់លេខ២ ខេត្តព្រះសីហនុ នៅក្រុមហ៊ុនអូស្កា ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលកាលពី អំឡុង ឆ្នាំ ២០២២។

លោក យូរ ឧត្តរា ជាប្រធានចៅក្រមជំនុំជម្រះនៃ តុលាការកំពូល បានឲ្យដឹងថា ជនជាប់ចោទ ៣នាក់មានឈ្មោះ ៖ ១-ឈ្មោះ YU GONG CHENG ភេទប្រុស អាយុ ៣០ ឆ្នាំ ( កើតឆ្នាំ ១៩៩០ ) ជនជាតិចិន ។ ២- ឈ្មោះ LIU YUAN HUANG ភេទប្រុស អាយុ ៣៦ ឆ្នាំ ( កើតឆ្នាំ ១៩៨៦ ) ។ ៣- ឈ្មោះ YU XUN CAI ភេទប្រុស អាយុ ៣២ ឆ្នាំ កើតឆ្នាំ ( ១៩៩២ ) ជនជាតិចិន ។ នៅក្នុងសំណុំរឿងក្តីនេះ សាលាដំបូងខេត្តព្រះសីហនុ កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០២២ បានបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ពីបទ ‘’ ជួញដូរមនុស្ស និងចាបឃុំឃាំង បង្ខាំ.ង មនុស្សដោយខុសច្បាប់ និងកំហែងយក តាមមាត្រា ១៧ នៃច្បាប់ស្តីពីការបង្រ្កាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និង តាម ២៥៣ មាត្រា ៣៣៦ នៃក្រមព្រហ្មទណ្ឌ ។

ពួកគេបាន ប្តឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍ព្រះសីហនុ បានតម្កល់ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដដែល មិនឲ្យនៅក្រៅឃុំ ។ ជនជាប់ចោទ ក៏បានបន្តប្តឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត។ ជនជាប់ចោទ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០២២ នៅ ខេត្តព្រះសីហនុ។ នាពេលសវនាការ, មេធាវីរបស់ជនជាប់ចោទ បានឆ្លើយថា ជនជាប់ចោទ មិនប្រព្រឹត្តដូចការចោទប្រកាន់ខាងលើនេះឡើយ ។ លោកមេធាវី បានបានសំណូមពរ ដល់ក្រុមប្រឹក្សាចៅក្រមជំនុំជម្រះ នៃតុលាការកំពូល មេត្តាសម្រេចដោះលែងកូនក្តី ឲ្យមានសេរីភាពឡើងវិញ ដើម្បីជួបជុំគ្រួសារ ។ នៅក្នុងសំណុំរឿងនេះ តុលាការកំពូលនឹងប្រកាសដីកា នៅព្រឹកថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២៣ នេះ ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## ឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ពង្រឹងបច្ចេកទេសការងារព្រំដែនដល់កម្លាំងវរៈទាំង៤និង ត្រូវទប់ស្កាត់រាល់បទល្មើសឆ្លងដែន និងទំនិញគេចពន្ធ

https://www.kampucheathmey.com/local-news/459637 ថ្ងៃចន្ទ ៦ កុម្ភៈ ២០២៣ដោយ Kang Tola

បន្ទាយមានជ័យ ៖ លោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ ស្នងការនគរបាលខេត្តបន្ទាយមានជ័យ បានដឹកនាំកិច្ចប្រជុំផ្សព្វផ្សាយផែនការការងារចាំបាច់ ចំពោះមុខ និងពង្រឹងបច្ចេកទេសការងារព្រំដែន ដល់កម្លាំងវរសេនាតូចនគរបាលការពារព្រំដែនគោកទាំង៤ នៅស្នងការដ្ឋាននគរបាលខេត្តកាលពីរសៀលថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០២៣។ កិច្ចប្រជុំនេះមានការចូលរួមពី លោក លោកស្រី ឧត្តមសេនីយ៍ វរសេនីយ៍ ស្នងការរងផែនជំនាញ លោកមេបញ្ជាការវរៈសេនាតូចការពារព្រំដែនគោកទាំង៤ លោកមេប៉ុស្តិ៍នគរបាលការពារព្រំដែនទាំង៣២។ បន្ថែមពីលើការផ្សព្វផ្សាយខាងលើលោកឧត្តមសេនីយ៍ទោ សិទ្ធិ ឡោះ បានជំរុញដល់កងកម្លាំងនគរបាលទាំងអស់ត្រូវគោរពវិន័យ អនុវត្តន៍តួនាទី ភារកិច្ចឲ្យបានល្អ។ -ត្រូវទប់ស្កាត់រាល់បទល្មើសឆ្លងដែន និងទំនិញគេចពន្ធគ្រប់ប្រភេទ -ត្រូវពង្រឹងការងារយាមល្បាតជាប្រចាំ -ត្រៀមកម្លាំងប្រចាំការ២៤ម៉ោង ត្រៀមអន្តរាគមន៍បង្ក្រាបរាល់បទល្មើសផ្សេងៗ និងគ្រោះអគ្គីភ័យក្នុងរដូវប្រាំង តាមមូលដ្ឋាននិងភូមិសាស្ត្រដែលកម្លាំងទាំងអស់ឈរជើងគ្រប់គ្រង៕ *ដោយ ៖ អពៅ*

## ថៅកែថៃបញ្ឈប់ពលករខ្មែរជាច្រើនដោយមិនបញ្ជាក់មូលហេតុ

https://www.rfa.org/khmer/news/human-rights/many-cambodian-workers-in-thailand-have-been-fired-by-their-employers-02072023080736.html ដោយ យ៉ង ចាន់តារា2023.02.07

ពលរដ្ឋខ្មែរធ្វើការក្នុងរោងចក្រវិចខ្ចប់មួយ នៅខេត្តរ៉ាក់យ៉ង (Rayong) ប្រទេសថៃ(Thaland) ជាង២០នាក់ ត្រូវបានថៅកែថៃ បញ្ឈប់ពីការងារ ដោយមិនបញ្ជាក់មូលហេតុ។ មន្ត្រីសង្គមស៊ីវិលធ្វើការងារទាក់ទងពលករលើកឡើងថា ការបញ្ឈប់ការងារនេះ គឺថៅកែថៃរំលោភច្បាប់ការងាររបស់ប្រទេសនេះ។

ថៅកែជនជាតិថៃ ដែលបញ្ឈប់ពលករខ្មែរពីការងារ មិនបានផ្តល់ដំណឹងជូនពលករជាមុនទេ ហើយក៏មិនទាន់ផ្តល់ប្រាក់សំណងឱ្យពលករវិញដែរ។ ពេលនេះក្រុមពលករកំពុងប្រឈមបញ្ហាជីវភាព ក្នុងគ្រាដែលគ្មានការងារធ្វើ។ ពលករខ្មែរធ្វើការងារផ្នែកធ្វើថង់ប្លាស្ទិក លោកស្រី ព្រំ សំណាង ឱ្យវិទ្យុអាស៊ីសេរីដឹងថ្ងៃទី០៧ ខែកុម្ភៈ ថាថៅកែថៃ បានហៅលោកស្រីទៅចុះហត្ថលេខាលើលិខិតបញ្ឈប់ពីការងារកាលពីថ្ងៃទី០៣ ខែកុម្ភៈ ដោយមិនប្រាប់លោកស្រីថា នោះជាលិខិតបញ្ឈប់ពីការងារទេ។ លោកស្រីឱ្យដឹងទៀតថា ពេលនោះលោកស្រី និងពលករផ្សេងទៀត មិនដឹងត្រូវធ្វើបែបណា ក៏យល់ព្រមចុះហត្ថលេខាលើពាក្យលាឈប់នោះ។ លោកស្រីថា ពេលនេះក្រុមពលករដែលត្រូវថៅកែបញ្ឈប់ពីការងារ បានដាក់ពាក្យប្តឹងទៅក្រសួងការងារថៃ និងអង្គការសង្គមស៊ីវិលនៅប្រទេសថៃដើម្បីជួយធ្វើអន្តរាគមន៍។ លោកស្រី ព្រំ សំណាង៖ «គេ(ថៅកែ)ហៅទៅគេឱ្យស៊ីញ៉េ គេថា ស៊ីញ៉េវីសា ដល់ទៅដល់លើគេបង្ខំអ៊ីចឹងគ្រប់គ្នា»។

ពលករម្នាក់ទៀតដែលត្រូវថៅកែបញ្ឈប់ពីការងារដែរនោះ លោកស្រី ជិន ស៊ីឡាត់ ប្រាប់ថា ថៅកែថៃមិនទាន់ផ្តល់ប្រាក់ឈ្នួលចុងក្រោយ និងប្រាក់ជំងឺចិត្តនោះទេ។ លោកស្រីឱ្យដឹងទៀតថា មុនពេលបញ្ឈប់ពីការងារថៅកែថៃ បានកាត់លុយលោកស្រីចំនួន ៤ពាន់ ៥០០បាត(៤.៥០០) ឬប្រមាណ ១៤០ដុល្លារ ដើម្បីរត់ការធ្វើទិដ្ឋាការការងារ(វីសា)។ ប៉ុន្តែពេលថៅកែបញ្ឈប់លោកស្រីពីការងារដូច្នេះ ថៅកែមិនទាន់ផ្តល់ប្រាក់ធ្វើ វីសានោះមកវិញទេ។ លោកស្រី ជិន ស៊ីឡាត់៖ «គ្នាធ្វើការមានអ្នក១០ឆ្នាំ មានអ្នក៥ឆ្នាំទៀត ថា ខ្ញុំទើបបាន១ឆ្នាំអីហ្នឹងឯង បើថា គ្នាឡើងបួនប្រាំឆ្នាំគ្នាមិនបានអីមកវិញផង»។ រោងចក្រថៃដែលបញ្ឈប់ពលករខ្មែរនេះឈ្មោះ ធី ភី ប៊ី អាយ ភុប

ប្លឹក (TPBI PUBLIC CO,LTD) មានទីតាំងនៅខេត្តរ៉ាក់យ៉ង(Rayong) ក្នុងតំបន់ឧស្សាហកម្ម ផាត់តានា ប្រទេសថៃ។ វិទ្យុអាស៊ីសេរីមិនទាន់អាចទាក់ទងថៅកែ ឬតំណាងរោងចក្រ ដើម្បីសាកសួរអំពីរឿងនេះបាននៅឡើយទេ។

ទាក់ទងរឿងនេះដែរ មន្ត្រីផ្នែកការពារសិទ្ធពលករចំណាកស្រុកនៃអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុន ដែលបានចុះអង្កេតបញ្ហានេះយល់ថា ការបញ្ឈប់ការងារនេះ ថៅកែធ្វើដោយរំលោភច្បាប់ការងារប្រទេសថៃ។ លោកថា តាមនីតិវិធី ភាគីថៅកែត្រូវជូនដំណឹងជាមុនក្នុងរយៈពេល៣ខែ និងត្រូវទូទាត់ប្រាក់សំណងជូនពលករ។ លោកបន្ថែមថា ពេលនេះ លោកបានយកករណីនេះដាក់ជូនអាជ្ញាធរថៃ និងអង្គការសង្គមស៊ីវិលនៅប្រទេសនេះដើម្បីជួយដោះស្រាយ។ លោក លឹង សុផុន៖ «បង្ខំឱ្យស៊ីញ៉េហើយបញ្ឆោតថា តប័ណ្ណ តវីសា តឯកសារអ៊ីចឹងណា ក្រដាសហ្នឹងគាត់មិនដឹងថា ក្រដាសអីដែរ ប៉ុន្តែផ្ទុយទៅវិញបន្ទាប់ពីគាត់ស៊ីញ៉េលើក្រដាសហ្នឹងរួចរាល់ហើយគេថា លិខិតបញ្ឈប់ពីការងារ លក្ខណៈរំលោភបំពានច្បាប់ការងារហើយណាមួយទៀតរំលោភសិទ្ធិពលករអ៊ីចឹងធ្វើឱ្យបងប្អូនពលករមួយចំនួនហ្នឹងមានការភ័យខ្លាច»។ លោក លឹង សុផុន ឱ្យដឹងដែរថា លោកបានផ្តល់ដំណឹងនេះទៅមន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ ហើយមន្ត្រីស្ថានទូតក៏បានមកជួបពលករ និងបានសន្យាថា នឹងជួយអន្តរាគមន៍ករណីនេះទៅអាជ្ញាធរថៃ។

ជុំវិញបញ្ហានេះ វិទ្យុអាស៊ីសេរីមិនអាចសុំការបញ្ជាក់បន្ថែមពីមន្ត្រីស្ថានទូតកម្ពុជាធ្វើការងារផ្នែកពលករ បានទេនៅថ្ងៃទី០៧ ខែកុម្ភៈ។ ក្រុមពលករស្នើទៅថៅកែថៃ ឱ្យសងប្រាក់ជំងឺចិត្តចំពោះការបញ្ឈប់ពីការងារនេះ និងទាមទារឱ្យថៅកែសងប្រាក់ថ្លៃធ្វើវីសាការងារឱ្យពួកគេវិញ៕

# ថ្ងៃទី០៩ ខែ កុម្ភៈ ឆ្នាំ២០២៣

## ប្រទេសថៃ មានករណីពពោះជំនួសចំនួន ៦២១ ករណី នៅ ៧ ឆ្នាំចុងក្រោយ

https://www.postkhmer.com/international/2023-02-07-1816-246736.html វណ្ណ ស័ក្តិ | Publication date 07 February 2023 | 18:16 ICT

ប្រទេសថៃ មានករណីពពោះជំនួសចំនួន ៦២១ ករណី នៅ ៧ ឆ្នាំចុងក្រោយកន្លងទៅនេះ។ ករណីពពោះជំនួសទាំងអស់នោះត្រូវបានអនុម័តនៅក្នុងប្រទេសថៃ ចាប់តាំងពីថៃបានបង្កើតច្បាប់ស្តីពីសេវាពពោះជំនួស។ នេះបើយោងតាមលោកវេជ្ជបណ្ឌិត Sura Visetsak អគ្គនាយកនៃនាយកដ្ឋានគាំទ្រសេវាសុខភាពរបស់ក្រសួងសុខាភិបាលថៃ ដែលថ្លែងប្រាប់អ្នកកាសែត។ លោកវេជ្ជបណ្ឌិត Sura Visetsak មានប្រសាសន៍ថា ច្បាប់ការពារកុមារដែលកើតដោយសារជំនួយបច្ចេកវិទ្យាសម្រាប់បន្តពូជត្រូវបានអនុម័ត ដើម្បីអនុញ្ញាតឱ្យគូស្វាមីភរិយាដែលរៀបការស្របច្បាប់ ប៉ុន្តែគ្មានកូនអាចបង្កើតកូន បានមួយវិញទៀតច្បាប់នេះមិនអនុញ្ញាតឱ្យមានការទិញដូរសម្រាប់សេវាពពោះជំនួសនេះឡើយ។

លោកបានពន្យល់ថា តាមច្បាប់ថៃគូស្វាមីភរិយាដែលអាចស្វែងរកសេវាពពោះជំនួសត្រូវតែទទួលបានការយល់ព្រមពីគណៈកម្មាធិការដែលមានភារកិច្ចការពារទារក។ លោកបន្ថែមថា៖ «មានតែគូស្នេហ៍ថៃដែលរៀបការរួចប៉ុណ្ណោះដែលអាចស្វែងរកសេវាពពោះជំនួសនៅប្រទេសថៃបាន។ យ៉ាងហោចណាស់ប្តីប្រពន្ធម្នាក់ត្រូវមានសញ្ជាតិថៃ និងត្រូវតែរៀបការរួចយ៉ាងហោចណាស់បីឆ្នាំ។ ចំពោះអ្នកពពោះជំនួសត្រូវតែមានកូនយ៉ាងតិចម្នាក់។ ប្រសិនបើស្ត្រីរៀបការរួចចង់ពពោះជំនួស នាងត្រូវតែទទួលបានការយល់ព្រមពីប្តីរបស់នាងជាមុនសិន»។ នៅប្រទេសថៃ ច្បាប់ថៃបានហាមឃាត់ការប្រើប្រាស់បច្ចេកវិទ្យាបន្តពូជដើម្បីជួញដូរ។ ម្យ៉ាងទៀតអំពើទិញដូរអូវុល មេជីវិតឈ្មោល និងអំប្រ៊ីយ៉ុង ក៏ត្រូវចាត់ទុកថាជាអំពើខុសច្បាប់។

ទាក់ទងនឹងសេវាសុខភាពបន្តពូជវិញលោកវេជ្ជបណ្ឌិត Sura Visetsak និយាយថា នៅពេលដែលជំងឺ COVID-19 ធូរស្រាលមានគូស្វាមីភរិយាបរទេសមួយចំនួនបានទៅលេងប្រទេសថៃ ដើម្បីទទួលការព្យាបាលលើបញ្ហាដែលពួកគេមិនអាចមានកូនបាន ។ លោកវេជ្ជបណ្ឌិត Sura Visetsak ថា មានមន្ទីរពេទ្យ និងគ្លីនិករដ្ឋ និងឯកជនជាច្រើនដែលផ្តល់សេវា ព្យាបាលបញ្ហាគ្មានកូននេះ ហើយពួកគេអាចរកប្រាក់ចំណូលយ៉ាងច្រើនសម្រាប់កំណើនសេដ្ឋកិច្ចរបស់ថៃ៕

# ថ្ងៃទី១០ ខែ កុម្ភៈ ឆ្នាំ២០២៣

## កម្ពុជាស្នើជប៉ុនជួយបណ្តុះបណ្តាល ធនធានមនុស្ស ដើម្បីបង្កើនចំនួនពលករទៅធ្វើការនៅជប៉ុន

https://www.postkhmer.com/national/2023-02-09-1046-246787.html វណ្ណ សុជាតា | Publication date 09 February 2023 | 10:46 ICT

**ភ្នំពេញ:** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លោក អ៊ិត សំហេង បានស្នើដល់ខាងភាគីជប៉ុនធ្វើការបណ្តុះបណ្តាលធនធានមនុស្សរបស់កម្ពុជា ដើម្បីបង្កើនចំនួនពលករខ្មែរទៅធ្វើការនៅជប៉ុនឱ្យដល់ ៥ ម៉ឺននាក់ ក្នុងពេលដ៏ខ្លីខាងមុខ ខណៈបច្ចុប្បន្ន ប្រជាពលរដ្ឋខ្មែរចំនួនជាង ២ ម៉ឺននាក់កំពុងធ្វើការនៅជប៉ុន។ ការស្នើរបស់រដ្ឋមន្ត្រីក្រសួងការងារនេះត្រូវបានធ្វើឡើងនៅក្នុងជំនួបពិភាក្សាការងារជាមួយលោក Takahashi Fumiaki ប្រធានសមាគមជប៉ុនកម្ពុជា (JCA) និងជាអតីតឯកអគ្គរាជទូតជប៉ុនប្រចាំកម្ពុជា កាលពីថ្ងៃទី ៧ ខែកុម្ភៈ ឆ្នាំ ២០២៣ នៅទីស្តីការក្រសួងការងារ។ លោកបញ្ជាក់ថា៖ «យើងចង់ស្នើដល់ខាងភាគីជប៉ុន ធ្វើការបណ្តុះបណ្តាលធនធានមនុស្សរបស់កម្ពុជាដើម្បីឈានទៅសម្រេចឱ្យបាននូវពលករចំនួន៥ម៉ឺននាក់ទៅធ្វើការនៅជប៉ុន នាពេលដ៏ខ្លីខាងមុខនេះ។ ខ្ញុំកត់សម្គាល់ឃើញថា ក្រុមហ៊ុនរបស់ជប៉ុនដែលមានវត្តមាននៅកម្ពុជា កម្រមានវិវាទការងារណាស់ ក្រុមហ៊ុនអនុវត្តទៅតាមច្បាប់បានល្អរួមនឹងទំនាក់ទំនងរវាងនិយោជកជប៉ុន និងកម្មករនិយោជិតកម្ពុជាមានភាពសុខដុមរមនានឹងគ្នា»។

ឆ្លើយតបទៅនឹងសំណូមពររបស់រដ្ឋមន្ត្រីក្រសួងការងារកម្ពុជានេះ លោក Takahashi Fumiaki និយាយថា លោករួមនឹងសមាជិករបស់សមាគមនឹងប្រឹងប្រែងធ្វើយ៉ាងណាជួយកម្ពុជាលើជំនាញដ៏ចាំបាច់ ដែលកំពុងមានតម្រូវការសម្រាប់ទៅធ្វើការនៅជប៉ុន។ លោកបញ្ជាក់ដូច្នេះថា៖ «ដោយសង្កេតឃើញថា រថយន្តដែលផលិតនៅប្រទេសជប៉ុនបានចរាចរណ៍នៅកម្ពុជាមានចំនួនកាន់តែច្រើន ដែលជាឱកាសមួយសម្រាប់ឱ្យខាងជប៉ុន ផ្តល់ការបណ្តុះបណ្តាលលើជំនាញថែទាំ និងជួសជុលរថយន្តនេះ ទៅដល់យុវជនកម្ពុជាឱ្យកាន់តែមានសមត្ថភាព រួមនឹងផ្តល់ការបណ្តុះបណ្តាលជំនាញកែសម្ផស្ស ដែលជាជំនាញមួយកំពុងតែពេញនិយម ដែលអាចផ្តល់ចំណូលបានប្រសើរ បើយុវជន យុវតីរបស់កម្ពុជាចាប់យកអាជីពខាងកែសម្ផស្សនេះបានស្ទាត់ជំនាញ»។

ជុំវិញបញ្ហានេះលោក ប៉ាវ ស៊ីណា ប្រធានសម្ព័ន្ធសហជីពចលនាកម្មករកម្ពុជា បានថ្លែងថា នេះជារឿងល្អសម្រាប់កម្ពុជា ក្នុងការសហការគ្នាយ៉ាងស្អិតល្មួតជាមួយខាងជប៉ុន ក្នុងការបញ្ជូនសិក្ខាកាម ទៅសិក្សា និងធ្វើការនៅប្រទេសជប៉ុន ដោយពួកគាត់មិនត្រឹមតែទទួលបានចំណូលខ្ពស់ សម្រាប់ផ្គត់ផ្គង់ក្រុមគ្រួសារប៉ុណ្ណោះទេ ថែមទាំងទទួលបានចំណេះជំនាញដែលក្រោយពីត្រឡប់មកពីជប៉ុនវិញ សិក្ខាកាមអាចប្រើប្រាស់ជំនាញទាំងនោះធ្វើការនៅក្រុមហ៊ុនជប៉ុន ដែលមកវិនិយោគនៅកម្ពុជាបាន។ លោកបញ្ជាក់ថា៖ «កន្លងទៅសមាគម មិនដែលបានទទួលព័ត៌មានពីការរំលោភបំពានធ្ងន់ធ្ងរអ្វី ពីបងប្អូនសិក្ខាកាម ឬពលករយើងនៅប្រទេសជប៉ុននោះទេ បើធៀបនឹង

ប្រទេសផ្សេងទៀត ដូចជាម៉ាឡេស៊ីជាដើម។ ប៉ុន្តែយើងស្នើដល់ក្រសួងឱ្យមានការបែងចែកឱ្យបានច្បាស់លាស់រវាងសិក្ខាកាម និងពលករ នៅជប៉ុនដើម្បីកុំឱ្យមានការភាន់ច្រឡំ ព្រោះខ្ញុំទទួលបានការទំនាក់ទំនងពីបណ្តាញពលកររបស់ខ្ញុំនៅជប៉ុន ថា ខ្លួនទៅជប៉ុនក្នុងនាមសិក្ខាកាម តែទៅធ្វើការងារជាពលករទៅវិញ ដែលនេះវាខុសពីនិយមន័យពិតរបស់វា»។

លោក អន ប៊ុនហាក់ ប្រធានសមាគមទីភ្នាក់ងារហត្ថពលកម្មកម្ពុជាបានថ្លែងថា ពលរដ្ឋកម្ពុជា ដែលបានចំណាកស្រុកទៅកាន់ប្រទេសជប៉ុន ភាគច្រើនទៅក្នុងនាមជាសិក្ខាកាម ដែលមានន័យថា ទៅរៀនផង និងធ្វើការផង តែការធ្វើការនៅជប៉ុនមិនមានសល់លុយច្រើនដូចនៅធ្វើការនៅកូរ៉េទេព្រោះពួកគាត់ត្រូវចំណាយពេលរៀនផងដែរ។ លោកបញ្ជាក់ថា៖ «សិក្ខាកាមដែលបញ្ចប់ការសិក្សា ឬការងារ ៣ ទៅ ៥ ឆ្នាំ ហើយត្រឡប់មកពីជប៉ុនវិញ ពួកគាត់តែងតែមានអាទិភាពចូលធ្វើការនៅក្រុមហ៊ុនជប៉ុននៅក្នុងប្រទេសកម្ពុជាដែលអ្នកខ្លះទទួលបានកម្រៃខ្ពស់ជាងអ្នកសិក្សាបរិញ្ញាបត្រនៅកម្ពុជាថែមទៀត។ ម្យ៉ាងវិញទៀត ប្រសិនបើយើងមានធនធានមនុស្សដែលមានជំនាញលើភាសាជប៉ុន និងចេះប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យាជប៉ុនច្រើន ពិតជាអាចទាក់ទាញអ្នកវិនិយោគជប៉ុនមកកាន់កម្ពុជាបន្ថែមទៀត»។

យោងតាមទិន្នន័យពីក្រសួងការងារគិតត្រឹមឆ្នាំ ២០២២ មានទីភ្នាក់ងារជ្រើសរើសឯកជនដែលទទួលបានការអនុញ្ញាត ឱ្យធ្វើការជ្រើសរើសបណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងកម្មសិក្សាការីពលករជំនាញ ទៅធ្វើកម្មសិក្សា និងធ្វើការនៅប្រទេសជប៉ុន មានជំនាន់ ១១៦ ទីភ្នាក់ងារ៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ២ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ០៣នាក់

https://www.freshnewsasia.com/index.php/en/localnews/277204-2023-02-09-11-37-12.html 2023-02-09 06:37pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៧ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេសចំនួន ០៣នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧៣១ករណី មានមនុស្ស ១,៧៧៦នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៦១សំណើ និងបិទសំណុំរឿង ២៤០សំណើ (រកឃើញមនុស្ស ១,០៧៩នាក់, ឃាត់ខ្លួនជនសង្ស័យ ១២២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣០ករណី៕

# ថៅកែថៃយល់ព្រមផ្ដល់សំណងជូនពលករខ្មែរដែលបញ្ឈប់ពីការងារ

https://www.rfa.org/khmer/news/human-rights/thai-authority-promised-to-resolve-labor-dispute-between-cambodian-workers-and-thai-employers-02092023075410.html ដោយ ម៉ៅ សុជានី 2023.02.09

ថៅកែថៃយល់ព្រមផ្ដល់ប្រាក់សំណងជំងឺចិត្ត ជូនពលករខ្មែរជាង ២០នាក់ដែលត្រូវបានថៅកែបញ្ឈប់ពួកគេពីការងារ។ ថៅកែថៃយល់ព្រមផ្ដល់សំណងដល់ពលករខ្មែរដូច្នេះ ក្រោយពេលមន្ត្រីក្រសួងការងារប្រទេសថៃ និងអ្នកពាក់ព័ន្ធចុះសម្របសម្រួលករណីនេះ។ ពលករខ្មែរដែលត្រូវបានថៅកែថៃបញ្ឈប់ពីការងារទទួលបានប្រាក់សំណងទៅតាមអតីតភាពការងាររបស់ពួកគេ។ ក្រៅពីប្រាក់សំណងជំងឺចិត្ត ថៅកែថៃ ក៏យល់ព្រមសងប្រាក់ចំនួន ៤ពាន់ ៥រយបាត(៤.៥០០) ឬប្រមាណ ១៤០ដុល្លារ ដែលថៅកែបានកាត់ពីពលករ ជាប្រាក់រត់ការធ្វើថ្លៃទិដ្ឋាការការងារ (វីសា)។

មន្ត្រីអង្គការសង់ត្រាល់ (CENTRAL) ប្រចាំនៅប្រទេសថៃ លោក លឹង សុផុនដែលបានចុះអង្កេតករណីនេះ ឱ្យវិទ្យុអាស៊ីសេរី ដឹងល្ងាចថ្ងៃទី៩ ខែកុម្ភៈថា ការផ្ដល់ប្រាក់សំណងនេះ សម្រាប់ពលករធ្វើការងារក្រោម ១ឆ្នាំ អាចទទួលបានប្រាក់ជំងឺចិត្តស្មើនឹងប្រាក់ខែមួយរបស់ពួកគេ ចំណែកអ្នកដែលធ្វើការងារចាប់ពីមួយឆ្នាំឡើងទៅ អាចទទួលប្រាក់សំណងជំងឺចិត្ត ស្មើប្រាក់ឈ្នួលរបស់ពួកគេរយៈពេល ២ខែ។ អ្នកការពារសិទ្ធិពលកររូបនេះ យល់ថា ការដែលពលករខ្មែរអាចទទួលប្រាក់សំណងពីថៅកែថៃពេលនេះ ព្រោះពលករមានភាពឆ្លាតវៃក្នុងការរួមគ្នាទាមទារ និងស្វះស្វែងរកអន្តរាគមន៍ពីស្ថាប័នពាក់ព័ន្ធ។ លោក លឹង សុផុន៖ «អ៊ីចឹងយើងយកលុយមួយថ្ងៃគាត់ (ពលករ) ធ្វើបានប៉ុន្មាន ឧទាហរណ៍គាត់បាន ៣៥៧បាតហើយយើងគុណឱ្យ ៣០ថ្ងៃទៅ យើងឃើញលុយហើយ។ នេះជារឿងល្អសម្រាប់បងប្អូនយើងបើតាមខ្ញុំយល់ បើពលករគាត់បញ្ហាអ៊ីចឹងហើយ គាត់ទំនាក់ទំនងអ្នកដោះស្រាយដូចថា ស្ថាប័នពាក់ព័ន្ធ គាត់ចុះមកដោះស្រាយគឺជារឿងល្អប្រសើរសម្រាប់បងប្អូន»។

មន្ត្រីក្រសួងការងារប្រទេសថៃ នៅថ្ងៃទី៩ ខែកុម្ភៈ បានចុះទៅដោះស្រាយជម្លោះនេះដោយអនុញ្ញាតឱ្យតំណាងពលករខ្មែរ តំណាងថៅកែរោងចក្រថៃ មន្ត្រីសង្គមស៊ីវិលការពារសិទ្ធិពលករ និងមន្ត្រីស្ថានទូតកម្ពុជា ប្រចាំប្រទេសថៃចូលរួមដោះស្រាយ។

ជុំវិញបញ្ហានេះវិទ្យុអាស៊ីសេរីមិនអាចសុំការបញ្ជាក់បន្ថែមពីមន្ត្រីស្ថានទូតកម្ពុជាធ្វើការងារផ្នែកពលករ បានទេ នៅថ្ងៃទី៩ ខែកុម្ភៈ។

តំណាងពលករខ្មែរ ដែលថៅកែបញ្ឈប់ពីការងារលោកស្រី ព្រំ សំណាង ឱ្យវិទ្យុអាស៊ីសេរីដឹងថា មន្ត្រីក្រសួងការងារថៃ បានឱ្យក្រុមពលកររៀបរាប់ពីដំណើររឿងដែលថៅកែថៃបញ្ឈប់ពួកគេពីការងារ និងការទាមទារសំណងរបស់ក្រុមពលករ។ លោកស្រីឱ្យដឹងទៀតថា ជំហររបស់ក្រុមពលករ គឺទាមទារឱ្យផ្ដល់សំណងជំងឺចិត្តដែលថៅកែបញ្ឈប់ពួកគេពីការងារ និងប្រាក់ចំនួន ៤ពាន់ ៥រយបាត (៤.៥០០) ឬប្រមាណ១៤០ដុល្លារ ដែលថៅកែបានកាត់ពីពួកគេដើម្បីរត់ការធ្វើថ្លៃទិដ្ឋាការការងារ (វីសា)។ តំណាងពលកររូបនេះ ឱ្យដឹងទៀតថា មុនដំបូង ភាគីថៅកែរោងចក្រ ប្រកាន់ជំហរមិនផ្ដល់សំណងជំងឺចិត្តឱ្យក្រុមពលករទេ ដោយលើកឡើងថា ក្រុមពលករបានយល់ព្រមចុះហត្ថលេខាលិខិតលាឈប់ពីការងារ។ លោកស្រី ព្រំ សំណាង៖ «ខ្ញុំចង់បានថ្លៃគេដកយើងចេញ យើងអត់ដឹងខ្លួនថា គេដកយើងទេបង»។

កាលពីថ្ងៃទី៣ ខែកុម្ភៈ ថៅកែថៃបានបញ្ឈប់ក្រុមពលករខ្មែរជាង ២០នាក់ ដែលធ្វើការងាររោងចក្រមួយឈ្មោះ ធី ភី ប៊ី អាយ ភុបប្លីក (TPBI PUBLIC CO,LTD.)មានទីតាំងនៅខេត្តរ៉ាក់យ៉ង (Rayong) តំបន់ឧស្សាហកម្ម ផាត់តាណា ប្រទេសថៃ។ ក្រុមពលរដ្ឋឱ្យដឹងថា ថៅកែថៃបានប្រើល្បិចឱ្យពួកគេចុះហត្ថលេខាលើពាក្យសុំឈប់

ពីការងារ ដោយមិនឱ្យដឹងថា លិខិតនោះជាពាក្យសុំឈប់ពីការងារទេ។ ក្រោយមានបញ្ហានេះ ក្រុមពលករខ្មែរបាន ស្វែងការអន្តរាគមន៍ពីមន្ត្រីក្រសួងការងារថៃ មន្ត្រីស្ថានទូតកម្ពុជាប្រចាំប្រទេសថៃ មន្ត្រីសង្គមស៊ីវិលការពារសិទ្ធិពលករផងដែរ ទើបពួកគាត់ទទួលបានដំណោះស្រាយនេះ៕

# ថ្ងៃទី១៣ ខែ កុម្ភៈ ឆ្នាំ២០២៣

## អាជ្ញាធរខេត្តព្រះសីហនុ ស្នើឱ្យពលករមកធ្វើការស្របច្បាប់ ដើម្បីកុំឱ្យមានជនខិលខូចឆ្លៀតឱកាសក្នុងការកេងប្រវ័ញ្ចទៅលើកម្លាំងពលកម្ម

https://cen.com.kh/archives/616195.html Posted ByCENFebruary 10, 2023

ព្រះសីហនុ៖ ខេត្តព្រះសីហនុ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកជាតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ហើយរដ្ឋបាលខេត្ត ចង់បានក្រុមហ៊ុនជាច្រើន ចូលមកវិនិយោគលើវិស័យទេសចរណ៍ និងវិស័យមួយចំនួន។ ពាក់ព័ន្ធនិងវិស័យទេសចរណ៍ ថ្មីៗនេះ អាជ្ញាធរកម្ពុជា បានស្នើសុំឱ្យអគ្គកុងស៊ុលវៀតណាមជួយជំរុញជើងហោះហើរត្រង់ ពីរដ្ឋធានីហាណូយប្រទេសវៀតណាម មកកាន់ខេត្តព្រះសីហនុ ព្រោះថាខេត្តព្រះសីហនុ ក៏មានទំនាក់ទំនងទេសចរណ៍តាមផ្លូវទឹករួចមកហើយដែរ។ ទន្ទឹមនិងនោះ បានស្នើសុំជួយសម្របសម្រួល ដើម្បីទៅធ្វើទស្សកិច្ចនៅខេត្តបាក់លីវ ប្រទេសវៀតណាម ដែលជាខេត្តសម្ព័ន្ធមេត្រីភាពជាមួយនឹងខេត្តព្រះសីហនុ។ បច្ចុប្បន្នខេត្តព្រះសីហនុ មានក្រុមហ៊ុនវិនិយោគលើវិស័យទេសចរណ៍ជាង ២០០ ក្រុមហ៊ុន កំពុងធ្វើប្រតិបត្តិការអាជីវកម្មរបស់ខ្លួននៅទីនេះ រួមនិងគម្រោងវិនិយោគផ្សេងៗទៀត។

ស្របពេលដែលខេត្តព្រះសីហនុ មានគម្រោងវិនិយោគធំៗ ដែលផ្តល់ការងារជាច្រើនកន្លែងដល់ពលរដ្ឋក្នុងស្រុក អភិបាលខេត្តព្រះសីហនុ បានស្នើសុំឱ្យពលករ មកធ្វើការនៅខេត្តព្រះសីហនុដោយស្របច្បាប់ ដើម្បីកុំឱ្យមានជនខិលខូច ឆ្លៀតឱកាសកេងប្រវ័ញ្ចទៅលើកម្លាំងពលកម្ម ហើយទាមទារឱ្យមានការចូលរួមទាំងអស់គ្នា ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ទន្ទឹមនោះត្រូវបង្កើតកិច្ចសហប្រតិបត្តិការ និងជួយបញ្ជៀបការយល់ដឹងស្តីអំពីច្បាប់កម្ពុជា ដែលពួកគាត់មកធ្វើការនៅខេត្តព្រះសីហនុ ត្រូវគោរពតាមច្បាប់របស់កម្ពុជា ដើម្បីសុខដុមនីយកម្មទាំងអស់គ្នា។

ឯកឧត្តម គួច ចំរើន អភិបាលខេត្តព្រះសីហនុ បានលើកឡើងថា កម្ពុជាបានសិក្សាអំពីវំហូរជនបរទេសដែលចូលមកកេការងារខេត្តព្រះសីហនុដោយខុសច្បាប់ ហើយរដ្ឋបាលខេត្តអនុវត្តតាមផ្លូវច្បាប់។ គួរបញ្ជាក់ថា បើតាមអភិបាលខេត្ត បានឲ្យដឹងថា ក្នុងនាមកម្ពុជាធ្វើជាម្ចាស់ផ្ទះ កីឡាស៊ីហ្គេម ឆ្នាំ២០២៣ រាជរដ្ឋាភិបាលកម្ពុជាបានជ្រើសរើសខេត្តព្រះសីហនុ ជាកន្លែងប្រកួតកីឡាស៊ីហ្គេម លើវិញ្ញាសាចំនួន៣ ក្នុងនោះ មានដូចជា កីឡាម៉ូតូទឹក កីឡាទូកក្តោង និងកីឡាបាល់ទះលើឆ្នេរខ្សាច់៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៣ទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេស ៣នាក់

http://freshnewsasia.com/index.php/en/localnews/277237-2023-02-10-02-39-47.html 2023-02-10 09:39am

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី០៨ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេសចំនួន ០៣នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់ប

ណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៧៣៣ករណី មានមនុស្ស ១,៧៧៦នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៦៣សំណើ និងបិទសំណុំរឿង ២៤០សំណើ (រកឃើញមនុស្ស ១,០៧៨នាក់, ឃាត់ខ្លួនជនសង្ស័យ ១២២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣០ករណី៕

## អភិបាលខេត្តព្រះសីហនុ ស្នើវៀតណាមជួយសម្របសម្រួលឱ្យពលករមកធ្វើការស្របច្បាប់

https://www.postkhmer.com/national/2023-02-09-1815-246818.html យុទ្ធ វីរៈ | Publication date 09 February 2023 | 18:15 ICT

**ព្រះសីហនុៈ** អភិបាលខេត្តព្រះសីហនុ លោក គួច ចំរើន បានស្នើលោក LAI XUAN CHIEN អគ្គកុងស៊ុលថ្មីនៃស្ថានអគ្គកុងស៊ុលសាធារណរដ្ឋសង្គមនិយមវៀតណាម ប្រចាំខេត្តព្រះសីហនុ ជួយសម្របសម្រួល ឱ្យពលករដែលមកពីប្រទេសវៀតណាមចូលមកធ្វើការដោយស្របច្បាប់ក្នុងខេត្តនេះ ដើម្បីកុំឱ្យមានជនខិលខូចឆ្លៀតឱកាសក្នុងការកេងប្រវ័ញ្ចទៅលើកម្លាំងពលកម្មរបស់ពួកគេ។ ការស្នើរបស់ លោក គួច ចំរើន ដូចនេះធ្វើឡើង កាលពីថ្ងៃ ទី ៨ ខែកុម្ភៈ ក្នុងពេលលោកអនុញ្ញាតឱ្យលោក LAI XUAN CHIEN ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ នៅសាលាខេត្តព្រះសីហនុ។ លោក គួច ចំរើន បានថ្លែងថា៖ «យើងបានសិក្សាអំពីលំហូរជនបរទេស ដែលចូលមករកការងារធ្វើ ក្នុងខេត្តព្រះសីហនុដោយខុសច្បាប់ ហើយរដ្ឋបាលខេត្ត អនុវត្តតាមផ្លូវច្បាប់។ ដូច្នេះទាមទារឱ្យមានការចូលរួមទាំងអស់គ្នា ដើម្បីងាយស្រួលក្នុងការយើងគ្រប់គ្រង ទន្ទឹមនោះត្រូវបង្កើតកិច្ចសហប្រតិបត្តិការ និងជួយបញ្ជ្រាបការយល់ដឹងស្ដីអំពីច្បាប់កម្ពុជា ដែលពួកគាត់មកធ្វើការនៅខេត្តព្រះសីហនុ ត្រូវគោរពតាមច្បាប់របស់កម្ពុជា ដើម្បីសុខដុមនីយកម្មទាំងអស់គ្នា»។

នាជំនួបនោះដែរ លោក LAI XUAN CHIEN ក៏បានឯកភាពចំពោះការលើកឡើងរបស់លោកអភិបាលខេត្តព្រះសីហនុ ដោយឱ្យពលករបរទេសទាំងអស់ ត្រូវអនុវត្តច្បាប់របស់ប្រទេសនីមួយៗ ដើម្បីមានភាពងាយស្រួលក្នុងការគ្រប់គ្រង។ លោកអគ្គកុងស៊ុល ក៏បានថ្លែងអំណរគុណដល់លោក គួច ចំរើន ដែលបានអនុញ្ញាតឱ្យលោកដឹកនាំប្រតិភូចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារ ស្ដីពីការងារសន្តិសុខ សណ្ដាប់ធ្នាប់ និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំង២ឱ្យកាន់តែស៊ីជម្រៅថែមទៀត និងកាត់បន្ថយនៃលំហូរពលករដោយខុសច្បាប់។

ទាក់ទងនឹងសំណើនេះ ប្រធានអង្គការស្រាវជ្រាវជាតិកម្ពុជា (CNRO) ប្រចាំនៅខេត្តព្រះសីហនុ លោក សុខ សុខុម បានសម្ដែងការស្វាគមន៍ ចំពោះការលើកឡើងរបស់លោក គួច ចំរើន ដោយសារជាធម្មតា ប្រជាពលរដ្ឋនៃប្រទេសនីមួយៗ ដែលឆ្លងដែនទៅកាន់ប្រទេសមួយទៀត ត្រូវតែមានការអនុវត្តទៅតាមច្បាប់ទម្លាប់ឱ្យបានត្រឹមត្រូវ ទោះបីទៅសិក្សា បម្រើការងារ ឬក៏មានបេសកកម្មណាមួយក៏ដោយ។ លោកបានប្រាប់ថា៖ «បើសិនជាពលករវៀតណាម ចូលមកបម្រើការងារនៅក្នុងប្រទេសយើង ដោយគ្មានច្បាប់ទម្លាប់ត្រឹមត្រូវ នឹងធ្វើឱ្យមានភាពអនាធិបតេយ្យ អសន្តិសុខ ខូចសណ្ដាប់ធ្នាប់សង្គម ឬក៏ឈានដល់ការកេងប្រវ័ញ្ចពលកម្ម និងការចាប់ជំរិតជាដើម។ ដូច្នេះ ទាំងពលករកម្ពុជា និងវៀតណាម ត្រូវតែគោរពច្បាប់អន្តោប្រវេសន៍ និងច្បាប់ការងារ»៕

## សមត្ថកិច្ចទទួលបានបណ្តឹងសុំជួយសង្គ្រោះ ២ មានខ្មែរ និងចិន ៣ នាក់

https://www.kampucheathmey.com/local-news/461733 ថ្ងៃសុក្រ ១០ កុម្ភៈ ២០២៣ដោយ deth leng

សមត្ថកិច្ចកម្ពុជាទទួលបានពាក្យបណ្តឹងចំនួន ២ ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិខ្មែរ ១ នាក់ និងចិន ២ នាក់ គិតត្រឹមថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០២៣។ លោកនាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃបានឱ្យដឹងថា គិតត្រឹមថ្ងៃទី ៩ ខែកុម្ភៈ ឆ្នាំ ២០២៣ មានសំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម ស ខេង សរុបចំនួន ៧៣១ ករណី ដែលមានមនុស្ស ១ ៧៧៦ នាក់។ ក្នុងនោះ សមត្ថកិច្ចបានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៦១ សំណើ និងបិទសំណុំរឿង ២៤០សំណើ (រកឃើញមនុស្ស ១,០៧៩ នាក់, ឃាត់ខ្លួនជនសង្ស័យ ១២២នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)។ លោកនាយឧត្តមសេនីយ៍ ខៀវ សុភ័គបានបញ្ជាក់ឱ្យដឹងថា បច្ចុប្បន្នសមត្ថកិច្ច កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣០ ករណី៕

## ប្រទេសថៃពន្យារការបន្តប័ណ្ណការងារ ដែលជាការជួយសម្រួលដល់ពលករចំណាកស្រុកខ្មែររាប់ពាន់នាក់

https://www.khmertimeskh.com/501237002// February 11, 2023

គណៈរដ្ឋមន្ត្រីថៃ បានអនុម័តសំណើរបស់ក្រសួងការងារសម្រាប់ពលករចំណាកស្រុកបរទេសដើម្បីពន្យាពេលថ្ងៃផុតកំណត់សម្រាប់ការចុះឈ្មោះបន្តប័ណ្ណការងារដល់ពាក់កណ្តាលខែឧសភា។

អ្នកនាំពាក្យរដ្ឋាភិបាល TraisureeTraisaranakulបាននិយាយកាលពីថ្ងៃពុធថា ពលករចំណាកស្រុកកម្ពុជា មីយ៉ាន់ម៉ា ឡាវ និងវៀតណាម ដែលថៅកែចង់ឱ្យពួកគេធ្វើការនៅក្នុងប្រទេសនោះ នឹងត្រូវបានអនុញ្ញាតឱ្យពន្យារពេល៩០ ថ្ងៃដល់ថ្ងៃទី១៥ខែឧសភា ចាប់ពីថ្ងៃផុតកំណត់មុនថ្ងៃទី១៣ ខែកុម្ភៈ។ អ្នកស្រីបាននិយាយថា រដ្ឋាភិបាលនឹងលើកលែងការផាកពិន័យលើការស្នាក់នៅលើសទិដ្ឋាការសម្រាប់ពលករចំណាកស្រុកក្នុងអំឡុងពេលនេះ ដើម្បីអនុញ្ញាតឱ្យពួកគេរៀបចំឯកសារ ខណៈដែលកម្មករនៅតែមានសិទ្ធិទទួលបានអត្ថប្រយោជន៍សុខុមាលភាពសង្គមរបស់ពួកគេ។ ការបន្តប័ណ្ណការងារនឹងអនុញ្ញាតឱ្យពលករចំណាកស្រុកបរទេសធ្វើការក្នុងប្រទេសរហូតដល់ថ្ងៃទី១៣ខែកុម្ភៈ ឆ្នាំ២០២៤ ឬកាលបរិច្ឆេទដូចគ្នានៅឆ្នាំ២០២៥ តាមប្រភេទលិខិតអនុញ្ញាតការងារដែលពួកគេដាក់ជូន។ PairokChotikasatienអគ្គនាយកនៃនាយកដ្ឋានការងារបាននិយាយថាថៅកែទាំងនោះអាចចុះឈ្មោះការបន្តប័ណ្ណការងាររបស់ពលករពួកគេតាមអ៊ីនធឺណិតនៅលើគេហទំព័ររបស់នាយកដ្ឋានការងារ (alient13fen renewal.doe.gov.th)។ ពួកគេត្រូវបង់ថ្លៃសេវានៅធនាគារក្រុងថៃរហូតដល់ថ្ងៃទី ១៣ ខែកុម្ភៈ។ ពួកគេត្រូវបញ្ជូនឯកសារដែលត្រូវការសម្រាប់ការបន្តប័ណ្ណការងារ រួមទាំងលិខិតឆ្លងដែនរបស់ពលករចំណាកស្រុកបរទេសត្រឹមថ្ងៃទី ១៥ ខែឧសភា។ សម្រាប់និយោជកដែលចង់ដាក់ពាក្យបន្តនៅនឹងកន្លែង លោក Paironបាននិយាយថានាយករដ្ឋានការងារបានបញ្ជាឱ្យគ្រប់ការិយាល័យការងារតាមខេត្ត និងការិយាល័យចំនួន១០នៅក្នុងទីក្រុងបាងកក ឱ្យបើកបម្រើសេវាកម្ម៧ថ្ងៃក្នុងមួយសប្តាហ៍។ Bangkok Post

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្ដឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ៤នាក់

https://freshnewsasia.com/index.php/en/localnews/277439-2023-02-11-13-27-58.html 2023-02-11 08:27pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១០ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាមចំនួន ០៤នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៧៣៤ករណី មានមនុស្ស ១,៧៧៩នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៦៦សំណើ និងបិទសំណុំរឿង ២៤០សំណើ (រកឃើញមនុស្ស ១,០៨៥នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៨ករណី៕

# ថ្ងៃទី១៤ ខែ កុម្ភៈ ឆ្នាំ២០២៣

## លោកជំទាវ ជូ ប៊ុនអេង រំលឹកអំពីហានិភ័យនៃការឆបោកកុមារតាមប្រព័ន្ធអ៊ីនធឺណិត

https://btv.com.kh/article/20116 2023/02/13 12:31:19 pm

ភ្នំពេញ៖ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានរំលឹកឱ្យមានការប្រុងប្រយ័ត្នចំពោះហានិភ័យលើកុមា និងយុវវ័យតាមរយៈប្រព័ន្ធអ៊ីនធឺណិត ជាពិសេសគឺតាមបណ្ដាញសង្គមហ្វេសប៊ុកតែម្ដង ។ ក្នុងយុទ្ធនាការគាំទ្រទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត «តោះ! នាំគ្នានិយាយអំពីការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាពសម្រាប់កុមារ» ដែលត្រូវបានធ្វើឡើងនៅថ្ងៃទី១៣ ខែកុម្ភៈ នេះ លោកជំទាវ ជូ ប៊ុនអេង បានលើកឡើងថា នាពេលបច្ចុប្បន្ននេះ ប្រព័ន្ធបច្ចេកវិទ្យានៅប្រទេសកម្ពុជា បាននឹងកំពុងរីកចម្រើនឥតឈប់ឈរ ដែលផ្ដល់អត្ថប្រយោជន៍ជាច្រើន ក្នុងការជំរុញ និងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម។ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ជនខិលខូច ក៏បានឆ្លៀតឱកាសយកប្រព័ន្ធអ៊ីនធឺណិតនេះសម្រាប់បោកប្រាស់ ដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួនផងដែរ។

លោកជំទាវ បានរំលឹកឱ្យកុមារា កុមារី ត្រូវប្រុងប្រយ័ត្នចំពោះប្រព័ន្ធអ៊ីនធឺណិតនេះ កុំលង់លក់នឹងការឆាតលួងលោមតាមហ្វេសប៊ុក ឬតាមបណ្ដាញផ្សេងៗរបស់បុគ្គលមួយចំនួន។ ករណីខ្លះ គឺជាការឆបោក និងបញ្ឆោតឲ្យប្រព្រឹត្តនូវបទល្មើសផ្សេងៗ ដែលសង្គមស្អប់ខ្ពើម ។ លោកជំទាវ ក៏បានលើកឡើងផងដែរថា នាពេលបច្ចុប្បន្ន ប្រទេសកម្ពុជា ត្រូវបានជនខិលខូចយក ធ្វើជាជម្រក សម្រាប់ធ្វើការជួញដូរមនុស្ស និងឆបោកមនុស្សតាមប្រព័ន្ធអ៊ីនធឺណិតនេះ ប៉ុន្តែជនរងគ្រោះ គឺមិនមែនជាខ្មែរនោះទេ គឺសុទ្ធតែជនបរទេស ដែលត្រូវបានជនបរទេសដូចគ្នាធ្វើការបោកបញ្ឆោត។

លោក សំលៀង សីលា នាយកប្រតិបត្តិ នៃអង្គការសម្ពន្ធភាពដើម្បីកុមារ (APLE) បានលើកឡើង ថា នាពេលបច្ចុប្បន្ន ពិភពលោក មានកុមារជាច្រើន កំពុងត្រូវបានរងគ្រោះ តាមរយៈប្រព័ន្ធអ៊ីនធឺណិត។ នៅក្នុងចន្លោះឆ្នាំ ២០១៧និងឆ្នាំ២០១៩ រូបភាពអាសអាភាសកុមារលើអ៊ីនធឺណិត ត្រូវបានកើនឡើងទ្វេដង ហើយបន្តកើនឡើង

យ៉ាងគំហុកនៅពេលពិភពលោក មានការរីករាលដាលជំងឺកូវីដ-១៩។ លោកបានធ្វើការអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ រួមគ្នាធ្វើឲ្យអ៊ីនធឺណិតកាន់តែប្រសើរ និងមានសុវត្ថិភាព និងត្រូវធានាឲ្យបានថា កុមារគ្រប់រូប ត្រូវបានផ្តល់សិទ្ធិអំណាច និងគោរពនៅលើប្រព័ន្ធអនឡាញ។ ចូលរួមទាំងអស់គ្នាដើម្បីធានាថា «គ្មានកុមារណាម្នាក់ ត្រូវបានទុកចោលពីក្រោយឱកាស ដែលបច្ចេកវិទ្យាឌីជីថលអាចផ្តល់ឲ្យ» នាពេលបច្ចុប្បន្ន និងទៅអនាគត៕ បាន ចក់

## ទូតម៉ាឡេស៊ីៈ ករណីជួញដូរមនុស្សនៅកម្ពុជាមិនអាក្រក់ដូចរបាយការណ៍បរទេសលើកឡើងនោះទេ

https://www.khmertimeskh.com/501237693// តាំង រីនិត្យ / Khmer Times February 13, 2023

ឯកអគ្គរាជទូតម៉ាឡេស៊ីប្រចាំកម្ពុជាកាលពីសប្តាហ៍មុនបានថ្លែងរិះគន់បណ្តាអង្គការ និងបុគ្គល «ចង់បានការចាប់អារម្មណ៍» ដែលបានរាយការណ៍មិនពិតជាក់ស្តែងពីស្ថានភាពជួញដូរមនុស្សនៅកម្ពុជា ដែលអាចនាំឱ្យមានផលប៉ះពាល់មកលើទំនាក់ទំនងកម្ពុជា ម៉ាឡេស៊ី។ លោកបានបញ្ជាក់ថា ស្ថានភាពពិតប្រាកដគឺមិន «អាក្រក់» ដូចអ្វីដែលក្រុមជនទាំងនេះបានលើកឡើងនោះឡើយ។ ថ្លែងនៅក្នុងកិច្ចសម្ភាសន៍ក្នុងកម្មវិធី Cross Talk របស់កាសែតខ្មែរថាមស៍កាលពីថ្ងៃពុធសប្តាហ៍មុន លោកឯកអគ្គរាជទូត Eldeen Husaini Mohd Hashim បានអំពាវនាវឱ្យបុគ្គល និងអង្គការមួយចំនួនបញ្ឈប់ការលើកឡើងដោយគ្មានមូលដ្ឋានរបស់ខ្លួន ដែលបរិយាយខុសពីការពិតអំពីស្ថានភាពឧក្រិដ្ឋកម្មជួញដូរមនុស្សនៅកម្ពុជា ដែលកាលពីឆ្នាំកន្លងទៅ បានទាកទាញចំណាប់អារម្មណ៍របស់ពិភពលោកយ៉ាងខ្លាំង។

លោកថ្លែងថា៖ «អង្គការក្រៅរដ្ឋាភិបាលជាច្រើនកំពុងធ្វើបានយ៉ាងល្អ ក្នុងការកំពុងជួយទៅដល់ការប្រយុទ្ធប្រឆាំងការជួញដូរ ប៉ុន្តែអ្នកខ្លះគ្រាន់តែស្វែងរកការទាក់ទាញអារម្មណ៍តែប៉ុណ្ណោះ ដូច្នេះសូមឈប់ធ្វើវាទៅ។ បើមិនដឹងរឿងអស់ទេ សូមបិទមាត់ឱ្យជិត។ បើអ្នកចង់ក្លាយជាវីរជន ចូរទៅក្លាយជាវីរបុរសពិត»។ លោកបានលើកឡើងយ៉ាងដូច្នេះធ្វើឡើងបន្ទាប់ពីមានអង្គការសិទ្ធិជនចំណាកស្រុកឈ្មោះ North South Initiative ដែលមានមូលដ្ឋាននៅប្រទេសម៉ាឡេស៊ីនៅដើមសប្តាហ៍នេះ បានរិះគន់ប៉ូលីសម៉ាឡេស៊ី ដោយចោទប្រកាន់ថាពួកគេមិនបាននាំយកជនជាតិម៉ាឡេស៊ីចំនួន ៥ នាក់ទៅស្រុកកំណើតវិញ ក្រោយពីពួកគេបានក្លាយជាជនរងគ្រោះនៃអំពើជួញដូរមនុស្សក្រោមរូបភាព «ផ្តល់ការងារធ្វើ»។

នាយកប្រតិបត្តិរបស់អង្គការនេះគឺ Adrian Pereira បាននិយាយថា ជនរងគ្រោះនៃការបោកប្រាស់បញ្ឆោតគឺជាបុគ្គលដែលត្រូវបានជួញដូរ ហើយនៅក្រោមអនុសញ្ញាអន្តរជាតិប្រឆាំងនឹងការជួញដូរ ពួកគេមិនអាចត្រូវបានគេចាប់ខ្លួនក្រោមបទល្មើសអន្តោប្រវេសន៍ឡើយ។ លោកនិយាយថា៖ «ជនរងគ្រោះនៃការជួញដូរក្រោមរូបភាពផ្តល់ការងារអាចត្រូវបានគេជួយសង្គ្រោះបានកាន់តែងាយស្រួល ប្រសិនបើអាជ្ញាធរប្រើប្រាស់ការមិនផ្តន្ទាទោសជនរងគ្រោះនៃការជួញដូរក្រោមក្រុមសម្របសម្រួលអន្តរទីភ្នាក់ងារប្រឆាំងនឹងការជួញដូរមនុស្ស និងច្បាប់អន្តរជាតិមួយចំនួនទៀតដែលការពារសិទ្ធិជនរងគ្រោះ»។

ជាការឆ្លើយតប លោក Eldeen Husaini ដែលបានធ្វើការជាមួយប៉ូលីសម៉ាឡេស៊ីលើករណីនេះ បានលើកឡើងថា ការលើកឡើងខាងលើនេះគឺគ្រាន់តែជា «ការស្រែកដង្ហើយដែលមិនចាំបាច់» ដែលត្រូវបានធ្វើឡើងដើម្បីទាក់ទាញការចាប់អារម្មណ៍តែប៉ុណ្ណោះ»។ លោកបានពន្យល់ថា៖ «មនុស្សទាំងប្រាំនាក់នេះមិនមែនជាជនរងគ្រោះទេ ព្រោះលក្ខណៈរបស់ពួកគេមិនត្រូវនឹងនិយមន័យនៃ«ជនរងគ្រោះ»នោះឡើយ។ «[យ៉ាងហោចណាស់] ពួកគេពីរនាក់បានមកទីនេះដោយខុសច្បាប់បន្ទាប់ពីឆ្លងកាត់ព្រំដែន ដោយគ្មានឯកសារផ្លូវច្បាប់ ហើយពួកគេមិនមានភស្តុតាងបង្ហាញថាខ្លួនជាជនរងគ្រោះទេ»។ លោកបន្តថា៖ «ពួកគេក៏បានធ្វើការរាយការណ៍រឿងរ៉ាវរបស់ពួកគេ

ខុសគ្នាៗ អាស្រ័យលើអ្នកដែលពួកគេនិយាយជាមួយ។ ខ្ញុំខកចិត្តចំពោះបុគ្គលទាំងនេះដែលបានព្យាយាមទាញយកឱកាសដើម្បីទទួលបានប្រជាប្រិយភាព និងការអាណិតអាសូរ នៅពេលពួកគេត្រលប់ប្រទេសម៉ាឡេស៊ីវិញ»។

លោកឯកអគ្គរដ្ឋទូតបានបន្ថែមថា ករណីបែបនេះជាច្រើនត្រូវបានគេរកឃើញនាពេលថ្មីៗនេះ ជាពិសេសបន្ទាប់ពីក្រសួងមហាផ្ទៃដាក់ចេញនូវយុទ្ធនាការទូទាំងប្រទេស ដើម្បីប្រយុទ្ធប្រឆាំងនឹងប្រតិបត្តិការជួញដូរមនុស្ស ដែលតម្រូវឱ្យជនរងគ្រោះដាក់ពាក្យបណ្ដឹងតាមប្រព័ន្ធអ៊ីនធឺណិតផងដែរ។ ពាក្យបណ្ដឹងមួយចំនួនត្រូវបានបញ្ជូនដោយគ្រួសារនៅក្នុងប្រទេសម៉ាឡេស៊ីដែលមាន "ព្រួយបារម្ភ" ទោះបីជាកូនប្រុសស្រីរបស់ពួកគេកំពុងធ្វើការដោយស្របច្បាប់ និងធ្វើបានល្អនៅក្នុងប្រទេសកម្ពុជាក៏ដោយក្ដី។ ឧក្រិដ្ឋកម្មនៃការជួញដូរមនុស្សនៅក្នុងប្រទេសកម្ពុជាបានចាប់ផ្ដើមក្លាយជាប្រធានបទដ៏ក្ដៅគគុកនៅក្នុងឆ្នាំ ២០២១ ជាពិសេសបន្ទាប់ពីខ្មែរថាមស៍ បានចាប់ផ្ដើមស៊ើបអង្កេតក្រុមហ៊ុនចិនមួយចំនួនដែលឃុំខ្លួនកម្មករទុកអគារក្នុងកាលពីខែមីនាឆ្នាំណោះ។ ករណីជាច្រើនទៀតនឹងត្រូវបានលាតត្រដាងដោយឆ្លុះបញ្ចាំងពីប្រទេសកម្ពុជាដែលបានក្លាយជាប្រទេសនាំចូលដ៏ធំមួយនៅក្នុងបទល្មើសនេះ។

ទម្រង់ជាទូទៅ នៃបទល្មើសនេះគឺ ក្រោមរូបភាពនៃការផ្ដល់ការងារ ដោយក្រុមជនល្មើស ដែលស្ទើរតែទាំងអស់ត្រូវបានគ្រប់គ្រងដោយជនបរទេស។ ក្រុមទាំងនេះនឹងទាក់ទាញប្រជាជនមកពីប្រទេសផ្សេងទៀតជាមួយនឹងការផ្ដល់ការងារមានប្រាក់ខែច្រើន និងមានអត្ថប្រយោជន៍ដ៏មិនគួរឱ្យជឿនៅប្រទេសកម្ពុជា ហើយនៅពេលដែលជនល្មើសបានមកដល់ ក្រុមជនល្មើសបានបង្ខំឱ្យពួកគេចូលរួមក្នុងប្រតិបត្តិការឧក្រិដ្ឋកម្មរបស់ពួកគេ ចាប់ពីល្បែងអនឡាញ រហូតដល់ការបោកបញ្ឆោតតាមទូរស័ព្ទទាំងនៅក្នុង និងក្រៅប្រទេស។ ជនរងគ្រោះដែលត្រូវបានជួយសង្គ្រោះភាគច្រើនបានត្អូញត្អែរអំពី «លក្ខខណ្ឌឋាននរក» ដែលពួកគេរស់នៅខណៈពេលដែលត្រូវបានឃុំឃាំងដោយក្រុមជនល្មើសទាំងនោះ រួមទាំងអំពើអមនុស្សធម៌ ដូចជាការធ្វើទារុណកម្ម ការរំលោភបំពានផ្លូវភេទជាដើម។

ការកើនឡើង នៃការជួញដូរមនុស្សជាមួយនឹងវិធីសាស្ត្រប្រតិបត្តិការបែបនេះទំនងជានាំឱ្យមានការទម្លាក់ចំណាត់ថ្នាក់ដ៏ចម្រូងចម្រាសរបស់កម្ពុជានៅក្នុងរបាយការណ៍ស្ដីពីការជួញដូរមនុស្សឆ្នាំ ២០២២ របស់ស្ថានទូតសហរដ្ឋអាមេរិក។ របាយការណ៍នេះបានដាក់កម្ពុជាចូលទៅក្នុងបញ្ជីខ្មៅកម្ពុជាដោយទម្លាក់ពីចំណាត់ថ្នាក់ទី ២ ដល់កម្រិតទី ៣ ដែលធ្វើឱ្យ កម្ពុជាស្ថិតក្នុងហានិភ័យនៃទណ្ឌកម្មដែលចេញដោយសហរដ្ឋអាមេរិក ចំពោះការខកខានរបស់កម្ពុជាក្នុងការបំពេញស្តង់ដារអប្បបរ មាសម្រាប់ការលុបបំបាត់ការជួញដូរមនុស្ស និងមិនមានការរីកចម្រើនច្រើនលើសមត្ថភាពប្រឆាំងការជួញដូរ។ ទោះជាយ៉ាងណាក៏ដោយ ក្នុងបទសម្ភាសន៍ផ្ដាច់មុខជាមួយកាសែតខ្មែរថាមស៍ ឯកអគ្គរដ្ឋទូត Eldeen Husaini បាននិយាយថា អ្នកដែលកំពុងធ្វើការវាយប្រហារមកលើប្រទេសកម្ពុជាគួរតែ «មកទស្សនាប្រទេសកម្ពុជាមុន» មុនពេលធ្វើការសន្និដ្ឋានអំពីបញ្ហានេះ។

លោកបានបន្តថា៖ «របាយការណ៍គឺផ្អែកលើការប៉ាន់ស្មានតែប៉ុណ្ណោះ ហើយប្រសិនបើអ្នកចុះទៅមូលដូចខ្ញុំ នោះអ្នកនឹងដឹងថាស្ថានភាពឥឡូវស្ថិតនៅក្រោមការគ្រប់គ្រងហើយ។ កម្ពុជាបានធ្វើច្រើនណាស់ ដើម្បីកែលម្អស្ថានការណ៍នេះ»។ ទន្ទឹមនឹងទទួលស្គាល់ថា ករណីជួញដូរមនុស្សតាមរបៀបខាងលើពិតជាមានកើតឡើងនៅកម្ពុជាពិតមែន ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីរូបនេះបានអះអាងថា កិច្ចខិតខំប្រឹងប្រែងរបស់អាជ្ញាធរមូលដ្ឋានក្នុងការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មតាំងពីឆ្នាំមុន ត្រូវបានគេឱ្យតម្លៃមិនគ្រប់គ្រាន់ ដោយសារការបង្ក្រាបភាគច្រើនមិនត្រូវបានគេរាយការណ៍ឡើយ ទោះបីជាលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន និង លោក ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ បានចេញបញ្ជាផ្ទាល់ដល់មន្ត្រីរបស់ខ្លួន ដើម្បីពង្រឹងប្រតិបត្តិការប្រឆាំងការជួញដូរមនុស្ស និងការអនុវត្តច្បាប់អន្តោប្រវេសន៍ក៏ដោយក្ដី។ លោក Eldeen Husaini បានលើកឡើងទៀតថា៖ «របាយការណ៍ជាច្រើនមិនបានលើកឡើងពីសមិទ្ធិផលនោះទេ ប៉ុន្តែមានតែចំណុចក្ដៅ ដើម្បីទទួលបានការចាប់អារម្មណ៍ពីអន្តរជាតិ។ ផ្ទុយទៅវិញ ប្រសិនបើអ្នកទៅ

រកចំនួនពិត និងរឿងពិតដែលកម្ពុជារួមជាមួយនឹងស្ថានទូតនានាបានធ្វើ អ្នកនឹងដឹងថាស្ថានភាពមិនអាក្រក់ដូចការរាយការណ៍នោះទេ»។

យោងតាមស្ថានទូតម៉ាឡេស៊ី មានជនរងគ្រោះ ចំនួន២៧៤ នាក់មកពីប្រទេសម៉ាឡេស៊ី ត្រូវបានជួយសង្គ្រោះពីក្រុមឧក្រិដ្ឋកម្មនៅកម្ពុជាចាប់តាំងពីឆ្នាំ ២០១៩។ ឯកអគ្គរដ្ឋទូត Eldeen Husaini បានពន្យល់ថា វិបត្តិសេដ្ឋកិច្ចដែលបណ្តាលមកពីវិបត្តិជំងឺរាតត្បាតកូវីដ-១៩ ដែលបានវាយលុកប្រទេសម៉ាឡេស៊ីបានបណ្តាលឱ្យប្រជាជនទាំងនេះដែលភាគច្រើនគ្មានការងារធ្វើ ធ្លាក់ទៅក្នុងអន្ទាក់នៃការបោកបញ្ឆោតរបស់ក្រុមជនល្មើស។ លោកបានបន្តថា៖ «ក្រុមហ៊ុនប្រើប្រព័ន្ធអ៊ីនធឺណិតដូចជា Facebook ដើម្បីផ្សព្វផ្សាយការផ្តល់ការងារដ៏គួរឲ្យទាក់ទាញដើម្បីទាក់ទាញប្រជាជនម៉ាឡេស៊ីក៏ដូចជាប្រជាជនក្នុងប្រទេសផ្សេងទៀត។ នៅពេលដែលពួកគេនៅទីនេះ ពួកគេបានរកឃើញថាពួកគេត្រូវបានគេបង្ខំឱ្យធ្វើការក្នុងប្រតិបត្តិការខុសច្បាប់ ដូចជាការលេងល្បែងតាមអ៊ីនធឺណិត ឬការបោកប្រាស់តាមទូរស័ព្ទ»។ លោកបន្ថែមថា៖«ដោយទទួលបានជំនួយពីអាជ្ញាធរកម្ពុជា យើងបានជួយសង្គ្រោះពួកគេទាំងអស់គ្នា»។

ឯកអគ្គរដ្ឋទូត Eldeen Husaini បានរំលឹកឡើងវិញថា ក្នុងចំណោមអ្នកដែលត្រូវបានជួយសង្គ្រោះ គ្មាននរណាម្នាក់ក្នុងចំណោមពួកគេត្រូវបានគេរកឃើញថាបានរស់នៅក្នុងស្ថានភាពឃោឃៅនោះទេ។ លោកបានបន្ថែមថា៖ «នៅពេលដែលយើងចុះទៅ វាភាគច្រើនជាការិយាល័យ ឬឃ្លាំងដែលមានកុំព្យូទ័រ កៅអី និងម៉ាស៊ីនត្រជាក់។ មិនមែនមានអ្នកយកកាំភ្លើងទៅក្នុងក្បាល ឬដាក់ច្រវាក់ជើងរបស់ជនរងគ្រោះនោះទេ»។ ថ្លែងទៅកាន់បងប្អូនជនរួមជាតិ និងអ្នកផ្សេងទៀតមកពីជុំវិញពិភពលោក លោកឯកអគ្គរដ្ឋទូត Eldeen Husaini មានប្រសាសន៍ថា ប្រទេសកម្ពុជាគឺជាកន្លែងដ៏ល្អមួយដែលមានឱកាសជាច្រើនក្នុងការធ្វើការ និងធ្វើអាជីវកម្ម ដូចដែលបានបង្ហាញដោយអ្នកជំនួញម៉ាឡេស៊ីជាង ៤០០ នាក់ និងពលរដ្ឋម៉ាឡេស៊ីរាប់ពាន់នាក់ដែលកំពុងតែធ្វើការរកទទួលទាបនៅក្នុងប្រទេសកម្ពុជា។ ជោគជ័យនាពេលថ្មីៗនេះរបស់កម្ពុជាក្នុងការធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាន គឺជាភស្តុតាងមួយទៀតដែលបង្ហាញថាកម្ពុជាជាប្រទេសដែលមានសុវត្ថិភាពពិតប្រាកដ។

លោកបាននិយាយថា៖«ខ្ញុំបានមកទីនេះជិតបួនឆ្នាំហើយ ហើយខ្ញុំស្រឡាញ់ប្រទេសនេះ"។ "សម្រាប់ខ្ញុំ វាជាប្រទេសដែលមានសុវត្ថិភាពបំផុត និងជាទឹកដីនៃឱកាស ដោយសារប្រទេសនេះរីកចម្រើនលឿន។ លក្ខខណ្ឌការងារគឺដូចគ្នានឹងប្រទេសដទៃទៀតដែរ។ ប្រសិនបើអ្នកសួរជនជាតិម៉ាឡេស៊ីណាម្នាក់នៅទីនេះ គាត់នឹងប្រាប់អ្នកថា គាត់ស្រឡាញ់ប្រទេសកម្ពុជា»។ លោកថ្លែងទៀតថា៖ «សម្រាប់បងប្អូនជនរួមជាតិខ្ញុំដែលចង់មកកម្ពុជា សូមអញ្ជើញមកកាន់ទឹកដីនៃឱកាសនេះ។ ប៉ុន្តែសម្រាប់អ្នកដែលគិតចង់ប្រព្រឹត្តបទល្មើសនៅទីនេះ សូមកុំធ្វើ បើមិនចង់ឱ្យយើងចាប់អ្នក»៕

## មន្រ្តីក្រសួងមហាផ្ទៃ
## ក្រើនរំលឹកហានិភ័យ នៃការឆបោកកុមារ និងយុវវ័យ តាមប្រព័ន្ធអ៊ីនធឺណិត

https://dap-news.com/national/2023/02/13/312043/ ByKD102Posted on February 13, 2023

**ភ្នំពេញ៖ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង អំពើជួញដូរមនុស្ស បានក្រើនរំលឹកឲ្យមានការ ប្រុងប្រយ័ត្នចំពោះហានិភ័យលើកុមា និងយុវវ័យ តាមរយៈប្រព័ន្ធអ៊ីនធឺណិត ជាពិសេសតាមបណ្តាញសង្គមហ្វេសប៊ុកតែម្តង។**

ក្នុងយុទ្ធនាការគាំទ្រទិវាអន្តរជាតិ ដើម្បីសុវត្ថិភាពអ៊ីនធឺណិត «តោះ! នាំគ្នានិយាយអំពីការប្រើប្រាស់អ៊ីនធឺណិត ប្រកបដោយសុវត្ថិភាពសម្រាប់កុមារ» នៅថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ លោកស្រី ជូ ប៊ុនអេង បានថ្លែងថា នាពេលបច្ចុប្បន្ន ប្រព័ន្ធបច្ចេកវិទ្យានៅកម្ពុជា បាននិងកំពុងរីកចម្រើនឥតឈប់ឈរ ដែលផ្តល់អត្ថប្រយោជន៍ជា

ច្រើន ក្នុងការជំរុញ និងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប៉ុន្តែទោះជាយ៉ាងនេះក្តី ជនខិលខូច ក៏បានឆ្លៀតឱកាសយកប្រព័ន្ធអ៊ីនធឺណិតនេះ សម្រាប់បោកប្រាស់ ដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួនផងដែរ។ លោកស្រីបញ្ជាក់ថា «សូមរំលឹកឲ្យកុមារា កុមារី ត្រូវប្រុងប្រយ័ត្នចំពោះប្រព័ន្ធអ៊ីនធឺណិតនេះ កុំលង់លក់នឹងការឆោតល្ងង់លោមតាមហ្វេសប៊ុក ឬតាមបណ្តាញផ្សេងៗរបស់បុគ្គលមួយចំនួន។ ករណីខ្លះ គឺជាការឆបោក និងបញ្ឆោតឲ្យប្រព្រឹត្តនូវបទល្មើសផ្សេងៗ ដែលសង្គមស្អប់ខ្ពើម»។ លោកស្រីរដ្ឋលេខាធិការ បានលើកឡើងថា បច្ចុប្បន្ន កម្ពុជា ត្រូវបានជនខិលខូចយកធ្វើជាជម្រក សម្រាប់ធ្វើការជួញដូរមនុស្ស និងឆបោកមនុស្សតាមប្រព័ន្ធអ៊ីនធឺណិតនេះ ប៉ុន្តែជនរងគ្រោះមិនមែនជាខ្មែរនោះទេ គឺសុទ្ធតែជនបរទេសដែលត្រូវ បានជនបរទេសដូចគ្នាធ្វើការបោកបញ្ឆោត។

នាឱកាសនោះ លោក សំលៀង សីលា នាយកប្រតិបត្តិនៃអង្គការសម្មភាពដើម្បីកុមារ (APLE) បានឲ្យដឹងដែរថា នាពេលបច្ចុប្បន្ន ពិភពលោក មានកុមារជាច្រើន កំពុងត្រូវបានរងគ្រោះ តាមរយៈប្រព័ន្ធអ៊ីនធឺណិត។ នៅក្នុងចន្លោះឆ្នាំ២០១៧ និងឆ្នាំ២០១៩ រូបភាពអាសអាភាសកុមារលើអ៊ីនធឺណិត ត្រូវបានកើនឡើងទ្វេដង ហើយបន្តកើនឡើងយ៉ាងគំហុក នៅពេលពិភពលោក មានការរីករាលដាលជំងឺកូវីដ-១៩។ លោកនាយកប្រតិបត្តិ ក៏បានធ្វើអំពាវនាវដល់ភាគីពាក់ព័ន្ធទាំងអស់ រួមគ្នាធ្វើឲ្យអ៊ីនធឺណិតកាន់តែប្រសើរ និងមានសុវត្ថិភាព និងត្រូវធានាឲ្យបានថា កុមារគ្រប់រូប ត្រូវបានផ្តល់សិទ្ធិអំណាច និងគោរពនៅលើប្រព័ន្ធអនឡាញ។ ចូលរួមទាំងអស់គ្នាដើម្បីធានាថា «គ្មានកុមារណាម្នាក់ ត្រូវបានទុកចោលពីក្រោយឱកាស ដែលបច្ចេកវិទ្យាឌីជីថលអាចផ្តល់ឲ្យ» នាពេលបច្ចុប្បន្ន និងទៅអនាគត ៕

## លោក គួច ចំរើន ៖ រដ្ឋបាលខេត្តមិនចង់ធ្វើការផាកពិន័យចំពោះហត្ថពលកម្មបរទេសដែលមកធ្វើការនៅខេត្តព្រះសីហនុ ប៉ុន្តែម្ចាស់សហគ្រាស រោងចក្រ ត្រូវតែសុំសៀវភៅការងារឱ្យបានគ្រប់ៗគ្នា

http://nokorwatnews.com/archives/964605 13/02/2023

ខេត្តព្រះសីហនុ៖ រដ្ឋបាលខេត្តព្រះសីហនុ នៅយប់ថ្ងៃចន្ទទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣នេះ បានឱ្យដឹងថា លោក គួច ចំរើន អភិបាល នៃគណៈអភិបាលខេត្តព្រះសីហនុ អញ្ជើញផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រង និងប្រើប្រាស់ហត្ថពលកម្មបរទេសដល់រោងចក្រ សហគ្រាស គ្រឹះស្ថាន សណ្ឋាគារ កាស៊ីណូ ក្នុងខេត្តព្រះសីហនុ ចំនួន ៣៣៥ ដោយមានការចូលរួមពីលោកអគ្គកុងស៊ុលវៀតណាមប្រចាំខេត្តព្រះសីហនុ និងផ្នែកអគ្គកុងស៊ុលចិនប្រចាំខេត្តព្រះសីហនុ អភិបាលរងខេត្ត អភិបាលក្រុង មន្ទីរ អង្គភាពនៅពិភពមង្គល ស្ថិតនៅសង្កាត់លេខ៣ ក្រុងព្រះសីហនុ កាលពីរសៀលថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣។

លោក យ៉ូវ ខេមរា ប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តព្រះសីហនុ បានធ្វើបទបង្ហាញ ទី១. ទិដ្ឋភាពច្បាប់ពាក់ព័ន្ធបទដ្ឋានគតិយុត្តនានា ២.បែបបទនិតិវិធីនៃការស្នើសុំប័ណ្ណការងារជនបរទេសប្រចាំឆ្នាំ ៣.ការចុះធ្វើអធិការកិច្ចចម្រុះហត្ថពលកម្មបរទេស ៤.ការផាកពិន័យ ៥.ការប្រើប្រាស់សេវាសាធារណរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៦.បញ្ហាប្រឈម ៧.សំណូមពរ។ ការផ្សព្វផ្សាយនេះ វាមានសារសំខាន់ណាស់ ដើម្បីឱ្យម្ចាស់សណ្ឋាគារ កាស៊ីណូបោះទីតាំងក្នុងខេត្តព្រះសីហនុចូលរួមអនុវត្តច្បាប់កម្ពុជាឱ្យមានប្រសិទ្ធិភាព។

លោក គួច ចំរើន អភិបាលខេត្តព្រះសីហនុ មានប្រសាសន៍ថា នេះជាការផ្សព្វផ្សាយលើកទី២ ដល់ម្ចាស់រោងចក្រ សហគ្រាស សណ្ឋាគារ និងកាស៊ីណូ អ្វីដែលរដ្ឋបាលខេត្តចង់បាន គឺការចូលរួមគោរពច្បាប់ទាំងអស់គ្នា ដែលមន្ទីរការងារបានធ្វើការបកស្រាយពន្យល់ បង្ហាញលេខទូរសព្ទទំនាក់ទំនង ដើម្បីមានភាពងាយស្រួលធ្វើការទំនាក់ទំនងជាមួយក្រុមការងាររបស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត។ លោកអភិបាលខេត្ត សង្ឃឹមថា

បងប្អូនអាចយល់ដឹងកាន់តែច្បាស់ ដែលមន្ត្រីរបស់យើងធ្វើការពន្យល់បកស្រាយតាមមាត្រា និងនីតិវិធីក្នុងការស្នើសុំសៀវភៅការងារ។ រដ្ឋបាលខេត្តនៅតែលើកទឹកចិត្តសម្រាប់សហគ្រាស រោងចក្រ ដែលកំពុងដំណើរការនៅក្នុងខេត្តព្រះសីហនុ យើងមិនចង់ធ្វើការផាកពិន័យចំពោះហត្ថពលកម្មបរទេសដែលមកធ្វើការនៅខេត្តព្រះសីហនុ ប៉ុន្តែអស់លោក លោកស្រីត្រូវតែសុំសៀវភៅការងារឱ្យបានគ្រប់ៗគ្នា។ រាជរដ្ឋាភិបាលបាកដាក់ចេញនូវផែនការសកម្មភាពបង្ការ ទប់ស្កាត់នូវរាល់បទល្មើសនៃការជួញដូរកម្លាំងពលកម្ម ជួញដូរមនុស្ស ជួញដូរគ្រឿងញៀន ការប្រើប្រាស់អាវុធខុសច្បាប់ និងល្បែងភ្នាល់ខុសច្បាប់ផ្សេងទៀត ដើម្បីការពារគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈសង្គម ហើយបទល្មើសទាំងអស់នេះ វាបានផ្តើមចេញពីហត្ថពលកម្មបរទេសដែលរស់នៅដោយខុស កើតជាអំពើឆបោក ការបង្ខិតបង្ខំងទាប្រាក់ជាដើម។ ហើយថ្មីៗនេះរាជរដ្ឋាភិបាលបានដឹកនាំការបង្ក្រាបបទល្មើសទ្រង់ទ្រាយធំនៅទូទាំងប្រទេស ពិសេសនៅខេត្តព្រះសីហនុ ហើយបទល្មើសផ្តើមចេញពីអ្នកគេចវេសហត្ថពលកម្មបរទេសខុសច្បាប់នេះ ដើម្បីឈានទៅការគ្រប់គ្រងសន្តិសុខ និងទប់ស្កាត់ការឆបោក គឺត្រូវចូលរួមគោរពច្បាប់ការងាររបស់ព្រះរាជាណាចក្រកម្ពុជា ប្រសិនបើពលកម្មបរទេសដែលមិនមានសៀវភៅការងារពួកគេនឹងងាយរងគ្រោះ នៃការគំរាមកំហែង និងការអូសទាញឆបោក មានន័យថាបើពលករបរទេសរស់នៅស្របច្បាប់ មានសៀវភៅការងារ អំពើល្មើសនិងត្រូវកាត់បន្ថយ។

ស្របពេលការគម្រាមកំហែងដោយកូវីដ-១៩ ប្រទេសនៅលើពីភពលោកបានបើកសេដ្ឋកិច្ច និងបើកទេសចរឡើងវិញ ខេត្តព្រះសីហនុ ក៏ជាខេត្តទេសចរមួយផងដែរ។ តាមការរំពឹងទុកលំហូរភ្ញៀវទេសចរ និងអ្នកវិនិយោគមកកាន់ខេត្តព្រះសីហនុនៅពេលខាងមុខ ទន្ទឹមនោះយើងមានភារកិច្ចការពារសុខសុវត្ថិភាពជូនភ្ញៀវទេសចរ និងអ្នកវិនិយោគដែលមកបំពេញការងារប្រកបដោយសុវត្ថិភាព និងរកប្រាក់ចំណូលប្រកបដោយភាពសុខសាន្ត។ យើងបន្តលើកទឹកចិត្តឱ្យហត្ថពលកម្មបរទេសចូលរួមគោរពច្បាប់ព្រះរាជាណាចក្រកម្ពុជា យើងនឹងមានសុខដុមនីយកម្មទាំងអស់គ្នា ផ្តល់អត្ថប្រយោជន៍ដល់គ្នាទៅវិញទៅមក នេះជាពេលវេលានៃការផ្សព្វផ្សាយ ផ្តល់ឱ្យយើងមានការយល់ដឹងពីច្បាប់ការងារ ដូច្នេះលោក លោកស្រីត្រូវធ្វើការពន្យល់ដល់អ្នកគ្រប់គ្រងរោងចក្រ សហគ្រាស សណ្ឋាគារ កាស៊ីណូ។

លោកអភិបាលខេត្ត ក៏បានស្នើសុំឱ្យអគ្គកុងស៊ុលនៃប្រទេសទាំងពីរជួយបន្តការផ្សព្វផ្សាយដល់សហគ្រាសទាំងអស់ចូលរួមគោរពច្បាប់ទាំងអស់គ្នា ចូលរួមកាត់បន្ថយបទល្មើស និងល្បែងភ្នាល់ខុសច្បាប់ ការជួញដូរមនុស្ស ជួញដូរពលកម្មជាដើម ដើម្បីការពារសន្តិសុខ សណ្តាប់ធ្នាប់សង្គមឱ្យល្អប្រសើរនៅពេលខាងមុខ។ លោកអភិបាលខេត្ត បានថ្លែងអំណរគុណអគ្គកុងសុលវៀតណាម និងផ្នែកអគ្គកុងស៊ុលចិនប្រចាំខេត្តព្រះសីហនុ បានបំពេញការងារនៅខេត្តព្រះសីហនុ ចូលរួមការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការគ្រប់គ្រង និងប្រើប្រាស់ហត្ថពលកម្មបរទេសដែលមកធ្វើការងារនៅលើទឹកដីខេត្តព្រះសីហនុ៕

# ថ្ងៃទី២០ ខែ កុម្ភៈ ឆ្នាំ២០២៣

## តុលាការកំពូល តម្កល់ទោស បុរសជាប់ចោទម្នាក់ ពាក់ព័ន្ធនឹងអំពើ សញ្ចារកម្មមានស្ថានទម្ងន់ទោស ដោយបើកកន្លែងម៉ាស្សាបង្កប់សេវាផ្លូវភេទ

https://cen.com.kh/archives/618355.html Posted ByPen Srey NeatFebruary 14, 2023

ភ្នំពេញ: តុលាការកំពូល កាលពីព្រឹកថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០២៣នេះ បានប្រកាសសាលដីកា តម្កល់ទោស បុរសជនជាប់ចោទម្នាក់ ដែលតុលាការថ្នាក់ក្រោម កាត់ទោសដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងអំពើ សញ្ចារកម្មមានស្ថានទម្ងន់ទោស ដោយបើកកន្លែងម៉ាស្សាបង្កប់សេវាផ្លូវភេទ ប្រព្រឹត្តនៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាបខេត្តសៀមរាប កាលពីអំឡុងឆ្នាំ ២០២១។

លោក និល ណុន ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃតុលាការកំពូល បានថ្លែងឲ្យដឹងថា ជនជាប់ចោទរូបនេះមានឈ្មោះ យិន ង៉ែត ភេទប្រុស កើតឆ្នាំ ១៩៧០ ។ នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ យិន ង៉ែត ត្រូវបានសាលាដំបូងខេត្តសៀមរាប កាលពីថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០២១ ផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៧ ឆ្នាំ និងបង្គាប់ឱ្យសងជំងឺចិត្តដល់ជនរងគ្រោះចំនួនម្នាក់ៗ ២ លានរៀល ក្រោមការចោទប្រកាន់ពីបទ : សញ្ចារកម្មមានស្ថានទម្ងន់ទោសទក់ទងនឹងជនរងគ្រោះ តាមមាត្រា ២៥ និង មាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ ។

ជនជាប់ចោទ បានប្តឹងឧទ្ធរណ៍ ខណៈ សាលាឧទ្ធរណ៍ខេត្តបាត់ដំបង បានតម្កល់ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដែល និង៩ រួចផុតពីបទចោទ ពីបទសញ្ចារកម្មមានស្ថានទម្ងន់ទោសទក់ទងនឹងជនរងគ្រោះ។ ក៏បានបន្តប្តឹងសារទុក្ខ មកកាន់តុលាការកំពូលទៀត។ ជនជាប់ចោទ ត្រូវបានចាប់ឃាត់ខ្លួន កាលពី ថ្ងៃទី ០៤ មករា ឆ្នាំ ២០២០ នៅភូមិជន្លង់ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ។ ក្រោយឃាត់ខ្លួន, សមត្ថកិច្ចជំនាញដកហូតវត្ថុតាងរួមមាន៖ – ទូរស័ព្ទដៃចំនួន ១ គ្រឿង និងក្រដាសសើមសម្រាប់ជូតទឹកកាមចំនួន ១២ ដុំ – ស្រោមអនាម័យ មួយចំនួនទៀត ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## ស្ថាប័នរដ្ឋ និងអង្គការដៃគូ ដាក់ចេញគម្រោង «ស្រួល» ដើម្បីទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទកុមារ

https://www.postkhmer.com/national/2023-02-14-1057-246953.html វ៉ាន់ វើយ | Publication date 14 February 2023 | 10:57 ICT

**ភ្នំពេញៈ** ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ ព្រួយបារម្ភខណៈមានការរីកចម្រើនបច្ចេកវិទ្យា ដែលអាចនាំទៅរកការរំលោភបំពានលើកុមារនិងយុវវ័យកាន់តែកើនឡើងស្របពេលដែលបច្ចេកវិទ្យាកាន់តែរីកចម្រើន និងការប្រើប្រាស់បច្ចេកវិទ្យាបណ្តាញសង្គមកាន់តែកើនឡើង។ អង្គការជាដៃគូជាច្រើនរួមជាមួយក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងមហាផ្ទៃ នៅថ្ងៃទី ១៣ ខែកុម្ភៈឆ្នាំ ២០១៣ បានបើកយុទ្ធនាការផ្សព្វផ្សាយទិវាអន្តរជាតិដើម្បីសុវត្ថិភាពអ៊ីនធឺណិត ក្រោមប្រធានបទ «នាំគ្នានិយាយអំពីការប្រើប្រាស់អ៊ីនធឺណិតប្រកបដោយសុវត្ថិភាពសម្រាប់កុមារ» ហៅកាត់ថា «ស្រួល» រយៈពេល ៣ ឆ្នាំ មានគោលបំណង ជួយទប់ស្កាត់ និងការពារការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ។

ក្នុងពេលបើកយុទ្ធនាការនេះ លោកស្រី ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានលើកឡើងថា នាពេលបច្ចុប្បន្ននេះ ប្រព័ន្ធបច្ចេក

វិទ្យានៅប្រទេសកម្ពុជា បាននិងកំពុងរីកចម្រើនឥតឈប់ឈរ ដែលផ្តល់អត្ថប្រយោជន៍ជាច្រើន ក្នុងការជំរុញ និងពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ហើយទន្ទឹមនឹងនេះ ក៏មានជនខិលខូចឆ្លៀតឱកាសយកប្រព័ន្ធអ៊ីនធឺណិតនេះសម្រាប់បោកប្រាស់ ដើម្បីតែផលប្រយោជន៍ផ្ទាល់ខ្លួនផងដែរ។ លោកស្រី ជូ ប៊ុនអេង បញ្ជាក់ថា៖ «កុមារា កុមារីត្រូវប្រុងប្រយ័ត្នចំពោះប្រព័ន្ធអ៊ីនធឺណិតនេះ និងកុំលង់លក់នឹងការឆាត [Chat] លួងលោមតាមហ្វេសប៊ុក ឬតាមបណ្តាញផ្សេងៗរបស់បុគ្គលមួយចំនួន។ ករណីខ្លះ គឺជាការឆបោក និងបញ្ឆោតឱ្យប្រព្រឹត្តនូវបទល្មើសផ្សេងៗ ដែលសង្គមស្អប់ខ្ពើម»។

បើយោងទៅតាមការសិក្សាស្រាវជ្រាវ គម្រោងបញ្ឈប់គ្រោះថ្នាក់ (Disrupting Harm) ដែលបានចេញផ្សាយនៅក្នុង ឆ្នាំ ២០២២ មានកុមារប្រហែលជា ១៦០ ០០០ នាក់ដែលមានអាយុចន្លោះពី ១២ ដល់ ១៧ ឆ្នាំ ធ្លាប់មានបទពិសោធន៍ជាមួយនឹងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ ដែលរួមមាន៖ ការលួងលោមតាមអនឡាញ និងការបង្ខំឱ្យផលិត និងចែកចាយរូបភាព ព្រមទាំងសម្ភារអាសអាភាស។ លោកស្រីរដ្ឋលេខាធិការ ក៏បានលើកឡើងផងដែរថា នាពេលបច្ចុប្បន្ន នេះប្រទេសកម្ពុជា ត្រូវបានជនខិលខូចយកធ្វើជាជម្រកសម្រាប់ធ្វើការជួញដូរមនុស្ស និងឆបោកមនុស្សតាមប្រព័ន្ធអ៊ីនធឺណិតនេះ ប៉ុន្តែជនរងគ្រោះគឺមិនមែនជាខ្មែរនោះទេ គឺសុទ្ធតែជនបរទេស ដែលត្រូវបានជនបរទេសដូចគ្នាធ្វើការបោកបញ្ឆោត។

លោក សំលៀង សិលា នាយកប្រតិបត្តិអង្គការសកម្មភាពដើម្បីកុមារ (APLE) បានលើកឡើងថា នាពេលបច្ចុប្បន្ន ពិភពលោក មានកុមារជាច្រើន កំពុងត្រូវបានរងគ្រោះ តាមរយៈប្រព័ន្ធអ៊ីនធឺណិត។ នៅក្នុងចន្លោះឆ្នាំ ២០១៧ និងឆ្នាំ ២០១៩ រូបភាពអាសអាភាសកុមារលើអ៊ីនធឺណិត ត្រូវបានកើនឡើងយ៉ាងច្រើន ហើយបន្តកើនឡើងយ៉ាងគំហុកនៅពេលពិភពលោក មានការរីករាលដាលជំងឺកូវីដ ១៩។ លោក សិលា និយាយថា៖ «ការរក្សាសុវត្ថិភាពកុមារតាមប្រព័ន្ធអនឡាញ និងការប្រើប្រាស់អ៊ីនធឺណិតដោយសុវត្ថិភាព ជារឿងសំខាន់បំផុតនៅសម័យឌីជីថលនេះ។ តាងនាមជាអង្គការដៃគូអនុវត្តន៍គម្រោង «ស្រួល» យើងសង្ឃឹមថា គម្រោងនឹងជួយជំរុញបន្ថែមនូវការបង្កើតយន្តការថ្នាក់ជាតិដើម្បីទប់ស្កាត់ការរំលោភបំពានកុមារតាមប្រព័ន្ធអនឡាញ ឱ្យកាន់តែមានប្រសិទ្ធភាព។

លោក គង់ វិឡា ប្រធានគ្រប់គ្រងកម្មវិធី អង្គការដែនដីមនុស្សហូឡង់ដ៍ប្រចាំកម្ពុជាថ្លែងថា៖ «គម្រោងស្រួលមានមហិច្ឆតានាំយកសំឡេងកុមារកម្ពុជាទាំងអស់ឱ្យអ្នកអនុវត្តន៍ច្បាប់នៅថ្នាក់ក្រោមជាតិ ថ្នាក់ជាតិ និងថ្នាក់តំបន់ បានដឹងពីបញ្ហាប្រឈមរបស់កុមារ និងចាត់វិធានការដោះស្រាយដើម្បីបង្កើនសុវត្ថិភាពដល់កុមារតាមប្រព័ន្ធអនឡាញ»។

យោងតាមសេចក្តីប្រកាសរបស់គម្រោង អង្គការដែនដីមនុស្សហូឡង់ដ៍ប្រចាំកម្ពុជា និងអង្គការដៃគូ បានអនុវត្តគម្រោងប្រឆាំង និងទប់ស្កាត់ការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអនឡាញ តាំងពីឆ្នាំ ២០១៧ ប៉ុន្តែបញ្ហានេះ នៅតែបន្តកើតមានដោយការរីកចម្រើននៃបច្ចេកវិទ្យា កាន់តែងាយស្រួល និងតម្លៃថោក សម្រាប់ការប្រើប្រាស់របស់កុមារ នៅក្នុងបរិបទដែលមិនមានការផ្សព្វផ្សាយគ្រប់គ្រាន់ និងការអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹង៕

## ក្រសួងការបរទេសហ្វីលីពីន៖ ជនរងគ្រោះហ្វីលីពីននៃ "ការជួញដូរគ្រីបតូ" កើនដល់១០០ នាក់ ស្ថិតនៅក្នុងប្រទេសកម្ពុជា

https://www.khmertimeskh.com/501239292// February 15, 2023

ក្រសួងការបរទេសហ្វីលីពីន (DFA) បាននិយាយកាលពីថ្ងៃអង្គារថា មានជនជាតិហ្វីលីពីនក្រៅប្រទេស ចំនួនប្រហែល ពី៥០ ទៅ១០០ នាក់ ដែលជាជនរងគ្រោះនៃការជួញដូររូបិយប័ណ្ណគ្រីបតូ នៅក្នុងប្រទេសកម្ពុជា មីយ៉ាន់ម៉ា និងឡាវ។ អនុរដ្ឋលេខាធិការ ក្រសួងការបរទេសហ្វីលីពីន លោក Eduardo Jose De Vega បានថ្លែង ខណៈដែលនាយកដ្ឋានថ្មីៗនេះបានជួយសង្គ្រោះ និងធ្វើមាតុភូមិនិវត្តន៍ជនរងគ្រោះហ្វីលីពីនពីការជួញដូរមនុស្ស ចំនួនប្រាំបីនាក់ពីប្រទេសមីយ៉ាន់ម៉ា ដែលក្នុងនោះ ៤នាក់គឺជាជនរងគ្រោះនៃការជួញដូរគ្រីបតូ។ គាត់បាននិយាយ នៅពេលត្រូវបានសួរនៅក្នុងបទសម្ភាសន៍មួយតាមទូរទស្សន៍ ABS-CBN News Channel ថាតើមានមនុស្សប៉ុន្មាន នាក់ដែលរងគ្រោះក្នុងការជួញដូរគ្រីបតូ ថា មានជនរងគ្រោះពី៥០ ទៅ១០០ នៅក្នុងប្រទេសនីមួយៗ ដូចជា ប្រទេសមីយ៉ាន់ម៉ា ឡាវ កម្ពុជា»។ លោកបាននិយាយថា ជនរងគ្រោះទាំងបួននាក់មកពីប្រទេសមីយ៉ាន់ម៉ាដែល សុទ្ធតែជាបុរសត្រូវបានជ្រើសរើសនៅទីក្រុងឌូបៃតាមអនឡាញ។

លោក De Vega បាននិយាយថា យ៉ាងហោចណាស់មានជនរងគ្រោះពីរនាក់បានស្នាក់នៅលើសទិដ្ឋាការ ការងាររបស់ពួកគេនៅក្នុងទីក្រុងឌូបៃ ហើយ "គ្មានការងារជាក់លាក់"។ លោកបាននិយាយថា "ពួកគេបានឃើញ ការងារទាំងនេះតាមអនឡាញ ដើម្បីធ្វើការជាអ្នកសរសេរកូដកុំព្យូទ័រ ព្រោះនោះជាជំនាញរបស់ពួកគេ។ ពួកគេមិន បានដឹងថាពួកគេនឹងចូលប្រទេសមីយ៉ាន់ម៉ាទេ»។ លោកបាននិយាយថា ពួកគេត្រូវបានគេនាំទៅទីក្រុងបាងកក ប្រទេសថៃ ហើយបន្ទាប់មកក្រុង Mae Sot ហើយពីទីនោះ ពួកគេត្រូវបាននាំទៅប្រទេសមីយ៉ាន់ម៉ា។

មន្ត្រីក្រសួងការបរទេសហ្វីលីពីន បានកត់សម្គាល់ថាអ្នកជ្រើសរើសពលករខុសច្បាប់កំពុងកំណត់គោលដៅ លើជនជាតិហ្វីលីពីនដែលនៅក្រៅប្រទេសតាមប្រព័ន្ធអនឡាញ ដែលជាសញ្ញាបង្ហាញថាព្រំដែនអន្តោប្រវេសន៍ហ្វី លីពីនកំពុងមានវិធានការរឹតបន្តឹង។ លោកបានបន្តថា៖ «យើងសង្ឃឹមថាយើងនឹងទប់ស្កាត់ចំនួននេះ ហើយវានឹង មិនកើនឡើងដល់រាប់រយនាក់នោះទេ»។ លោក De Vega បានធានាដល់សាធារណជនថានឹងមាន "ការធ្វើ មាតុភូមិនិវត្តន៍ស្រដៀងគ្នាបន្ថែមទៀត" ដើម្បីជួយសង្គ្រោះជនរងគ្រោះហ្វីលីពីននៅឯបរទេសពីការជួញដូរមនុស្ស។

## ថៃ ប្រកាស!
## ពលករចំណាកស្រុក រួមទាំងខ្មែរផងដែរ បើលួចការងារប្រជាជនរបស់ខ្លួន នឹងត្រូវពិន័យ

https://www.kampucheathmey.com/global-news/464529 ថ្ងៃពុធ ១៥ កុម្ភៈ ២០២៣ដោយ Sok Sovann

ប្រទេសថៃ នឹងពិន័យតាមច្បាប់លើពលករចំណាកស្រុក ប្រសិនបើរកឃើញថា ពួកគេលួចការងាររបស់ ប្រជាជនថៃ។ លោកនាយករដ្ឋមន្ត្រី ប្រាយុទ្ធ ចាន់អូចា បានបញ្ជាឲ្យនាយកដ្ឋានការងារ អនុវត្តច្បាប់ជាបន្ទាន់ ខណៈមានពលករចំណាកស្រុកកាន់តែច្រើនឡើងៗ កំពុងធ្វើការងារដែលថៃកំណត់ទុកឲ្យពលរដ្ឋរបស់ខ្លួន។ ឆ្លើយ តបនឹងបញ្ហានេះ អាជ្ញាធរបាន ធ្វើការវាយឆ្មក់កន្លែងធ្វើការចំនួន ១៤១០៤កន្លែង នៅទូទាំងប្រទេសចន្លោះខែតុលា ឆ្នាំមុន ដល់ថ្ងៃចន្ទទី១៣ ខែកុម្ភៈ ឆ្នាំ២០២៣ ដែលជាលទ្ធផលរកឃើញថា ពលករចំណាកស្រុកចំនួន៦០០ នាក់ បានបំពានច្បាប់ទាក់ទងនឹងការងារបម្រុង។ នាយកដ្ឋានការងារបានពិនិត្យពលករចំណាកស្រុកចំនួន ១៩៦៤០២នាក់ ដែលក្នុងនោះមានមីយ៉ាន់ម៉ា២៦៤នាក់, កម្ពុជា១២១នាក់, ឡាវ១២១នាក់, វៀតណាម៩៧នាក់,

ឥណ្ឌា៣៩នាក់, និង២៨នាក់មកពីប្រទេសផ្សេងៗ ហើយរកឃើញថា ក្នុងចំណោមពួកគេ មាន៦០០នាក់ បានធ្វើការងារ ដែលបម្រុងទុកសម្រាប់ប្រជាជនថៃ។ នេះបើតាមការចុះផ្សាយរបស់កាសែតបាងកកប៉ុស្តិ៍។

រដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin បានព្រមានថា ពលករចំណាកស្រុកដែលត្រូវបានគេរកឃើញថា ធ្វើការដោយគ្មានប័ណ្ណការងារត្រឹមត្រូវ ឬកំពុងធ្វើការងារមានកម្រិត អាចនឹងត្រូវពិន័យជាប្រាក់រហូតដល់៥០០០០បាត។ រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Suchart Chomklin លើសពីនេះ និយោជកដែលត្រូវគេរកឃើញថា បានជួលកម្មករចំណាកស្រុកបែបនេះ ក៏នឹងត្រូវពិន័យជាប្រាក់ដល់ទៅ ១០០ ០០០បាតផងដែរ សម្រាប់ការបំពានច្បាប់ឆ្នាំ២០១៧។ លោកបញ្ជាក់ថា "ប្រសិនបើពលករចំណាកស្រុកប្រព្រឹត្តល្មើសដដែលៗ និយោជករបស់ពួកគេនឹងប្រឈមមុខនឹងការជាប់ពន្ធនាគាររហូតដល់មួយឆ្នាំ ពិន័យជាប្រាក់រហូតដល់២០០ ០០០បាតឬទាំងពីរ។ ពួកគេក៏នឹងមិនអនុញ្ញាតឲ្យជួលពលករចំណាកស្រុករយៈពេល៣ឆ្នាំផងដែរ"។

យោងតាមអគ្គនាយកនៃអគ្គនាយកដ្ឋានការងារ បានបញ្ជាក់ថា យោងតាមសេចក្តីប្រកាសរបស់ក្រសួងពលករចំណាកស្រុកត្រូវបានហាមឃាត់យ៉ាងច្បាស់លាស់ពីការងារ ដែលត្រូវបានគេបម្រុងទុកកំណត់សម្រាប់តែពលរដ្ឋថៃប៉ុណ្ណោះ។ការងារទាំងនោះរួមមានអ្នកបើកបរដឹកជញ្ជូនសាធារណៈជាងចម្លាក់និងជាងកាត់សក់ជាដើម៕

## លោក វ៉ាង វិនធាន៖
## ឧក្រិដ្ឋជនចិន ដែលពាក់ព័ន្ធនឹងករណីជួញដូរមនុស្សនៅកម្ពុជា បានធ្លាក់ចុះ

http://freshnewsasia.com/index.php/en/localnews/278191-2023-02-15-12-27-07.html 2023-02-15 07:27pm

**(ភ្នំពេញ)៖** លោក វ៉ាង វិនធាន អគ្គរដ្ឋទូតចិនប្រចាំនៅកម្ពុជា នៅថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ បានថ្លែងថា ឧក្រិដ្ឋជនចិន ដែលពាក់ព័ន្ធនឹងករណីជួញដូរមនុស្សនៅកម្ពុជា បានធ្លាក់ចុះ ក្រោយកិច្ចសហប្រតិបត្តិការលើវិស័យអនុវត្តច្បាប់ រវាងប្រទេសចិននិងកម្ពុជា ដាក់ចេញ។ ថ្លែងក្នុងសន្និសីទសារព័ត៌មាន នៅស្ថានទូតចិន លោក វ៉ាង វិនធាន បានបញ្ជាក់យ៉ាងដូច្នេះ «ចាប់ពីធមាសទី២ ឆ្នាំមុន ចិននិងកម្ពុជា បានសហការជាមួយគ្នា ដើម្បីឲ្យអ្នកពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មត្រលប់ទៅវិញ។ យើងអាចនិយាយបានទេ កិច្ចសហប្រតិបត្តិការរវាងចិននិងកម្ពុជា ធ្វើឲ្យឧក្រិដ្ឋកម្មដែលពាក់ព័ន្ធនឹងជនជាតិចិននៅកម្ពុជា ត្រូវបានកាត់បន្ថយ ដែលគួរឲ្យកត់សម្គាល់ ហើយបានផ្តល់អំណោយផលដល់បរិយាកាសសន្តិសុខ និងសុវត្ថិភាព ដល់សហប្រតិបត្តិការសេដ្ឋកិច្ច ទេសចរណ៍ និងពាណិជ្ជកម្ម»។

បើតាមលោកឯកអគ្គរដ្ឋទូត កិច្ចសហប្រតិបត្តិការបង្ក្រាបឧក្រិដ្ឋកម្មជួញដូរមនុស្ស គឺជាកិច្ចសហប្រតិបត្តិការលើវិស័យអនុវត្តច្បាប់ ហើយកិច្ចសហប្រតិបត្តិការនេះ គឺជាផ្នែកសំខាន់សម្រាប់ប្រទេសទាំងពីរ កសាងសហគមន៍រួមវាសនាតែមួយ។ លោករំលឹកថា នៅឆ្នាំ២០១៩ ចិននិងកម្ពុជា បានបើកកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់ ដោយផ្តោតសំខន់លើការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ហើយបានផ្តោតសំខាន់ទៅលើឧក្រិដ្ឋកម្មដូចជា ការលេងល្បែងស៊ីសងតាមអនឡាញជាដើម។ លោក វ៉ាង វិនធាន បានបន្ថែមថា ឥឡូវនេះ ភាគីទាំងពីរសប្បាយរីករាយ ដែលបានឃើញថា កិច្ចសហប្រតិបត្តិការនេះបានទទួលសមិទ្ធផល ដែលគួរឲ្យកត់សម្គាល់។

នាយឧត្តមសេនីយ៍ កែវ វណ្ណថន អគ្គនាយករង និងជាអ្នកនាំពាក្យអគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានប្រាប់មកបណ្តាញព័ត៌មាន Fresh News ឲ្យដឹងថា ក្នុងឆ្នាំ២០២២ អគ្គនាយកដ្ឋានអន្តោប្រវេសន៍ បានធ្វើការបណ្តេញជនជាតិចិន សរុបចំនួន១,៣០៨នាក់ ភាគច្រើនពាក់ព័ន្ធលួចឆ្លងដែនខុសច្បាប់ និងស្នាក់នៅធ្វើការងារខុសច្បាប់។ ដោយឡែក ខែមករា ឆ្នាំ២០២៣នេះ អគ្គនាយកដ្ឋាន ក៏បានធ្វើការបណ្តេញជនជាតិចិន ចំនួន២២១នាក់ផងដែរ៕

# ចិន និងកម្ពុជា ឯកភាពគ្នា បន្តពង្រឹងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន អំពើភេរវកម្ម និងការឆបោកតាមប្រព័ន្ធទូរគមនាគមន៍

https://www.postkhmer.com/national/2023-02-15-1928-247014.html រី សុចាន់ | Publication date 15 February 2023 | 19:28 ICT

**ភ្នំពេញៈ** ចិន និងកម្ពុជា បានឯកភាពគ្នា បន្តពង្រឹងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន អំពើភេរវកម្ម ការឆបោកតាមប្រព័ន្ធទូរគមនាគមន៍ ល្បែងស៊ីសងឆ្លងដែនខុសច្បាប់ និងអំពើជួញដូរមនុស្ស។ ការឯកភាពគ្នានេះ ធ្វើឡើងក្នុងអំឡុងពេលដំណើរបំពេញទស្សនកិច្ចរបស់លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន ទៅកាន់ប្រទេសចិន កាលពីសប្តាហ៍មុន។ ក្នុងដំណើរទស្សនកិច្ចនោះ លោក ហ៊ុន សែន បានជួបជាមួយប្រធានាធិបតីចិន លោក ស៊ី ជីនភីង នាយករដ្ឋមន្ត្រី លោក លី ខឺឈាង និងលោក លី ជានស៊ូ ប្រធានគណៈកម្មាធិការអចិន្ត្រៃយ៍ នៃសភាតំណាងប្រជាជនចិន។

លោក Wang Wentian ឯកអគ្គរដ្ឋទូតចិនប្រចាំកម្ពុជា បានថ្លែងក្នុងសន្និសីទកាសែតនៅឯស្ថានទូតចិននៅទីក្រុងភ្នំពេញ កាលពីថ្ងៃ១៥ ខែកុម្ភៈថា៖ «ភាគីទាំង២ ឯកភាពគ្នាក្នុងការបន្តពង្រឹងកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរនៃការចែករំលែកព័ត៌មានរវាងអង្គភាពអនុវត្តច្បាប់ ដោយផ្តោតការយកចិត្តទុកដាក់ លើការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ហើយការឆបោកតាមប្រព័ន្ធទូរគមនាគមន៍ និងការលេងល្បែងស៊ីសងឆ្លងដែនខុសច្បាប់ និងអំពើជួញដូរមនុស្ស»។ លោកថ្លែងថា កិច្ចសហប្រតិបត្តិការលើការពង្រឹងការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន ដូចជាការជួញដូរមនុស្ស គឺកិច្ចសហប្រតិបត្តិការលើវិស័យអនុវត្តច្បាប់ ដែលជាផ្នែកសំខាន់របស់ប្រទេសទាំង២ ក្នុងការកសាងសហគមន៍វាសនារួមចិន និងកម្ពុជា។ លោកថា នៅក្នុងឆ្នាំ២០១៩ ភាគីចិន និងកម្ពុជា បានពង្រឹងកិច្ចសហប្រតិបត្តិការផ្នែកអនុវត្តច្បាប់រវាងចិន និងកម្ពុជា ដោយផ្តោតសំខាន់ទៅលើការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មឆ្លងដែន និងការលេងល្បែងតាមអនឡាញ។ លោក Wang Wentian ថ្លែងថា៖ «ហើយឥឡូវនេះ យើងសប្បាយរីករាយ ដែលបានឃើញថា កិច្ចសហប្រតិបត្តិការផ្នែកអនុវត្តច្បាប់នេះបានទទួលសមិទ្ធផលគួរឱ្យកត់សម្គាល់»។

សេចក្តីថ្លែងការណ៍រួមស្តីពីការកសាងសហគមន៍វាសនារួមកម្ពុជា-ចិន ក្នុងយុគសម័យថ្មីរវាងកម្ពុជា និងចិន កាលពីសប្តាហ៍មុនបញ្ជាក់ថា ភាគីចិន-កម្ពុជា បានឯកភាពគ្នាបន្តកិច្ចសហប្រតិបត្តិការផ្លាស់ប្តូរ និងចែករំលែកព័ត៌មាន រវាងមន្ត្រីអនុវត្តច្បាប់ ដោយផ្តោតការយកចិត្តទុកដាក់លើការប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែន ការប្រយុទ្ធប្រឆាំងអំពើភេរវកម្ម ការទប់ស្កាត់ «បដិវត្តន៍ពណ៌» ការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មពាក់ព័ន្ធនឹងគ្រឿងញៀន ការឆបោកតាមប្រព័ន្ធទូរគមនាគមន៍ ការលេងល្បែងស៊ីសងឆ្លងដែនខុសច្បាប់ និងអំពើជួញដូរមនុស្ស និងការកសាងសមត្ថភាពមន្ត្រីអនុវត្តច្បាប់។ សេចក្តីថ្លែងការណ៍រួមបញ្ជាក់ថា ភាគីទាំង២ ក៏បានឯកភាពបន្តលើកកម្ពស់ការពង្រឹងការិយាល័យសម្របសម្រួល និងកិច្ចសហប្រតិបត្តិការអនុវត្តច្បាប់កម្ពុជា-ចិន។

លោក យង់ ពៅ អគ្គលេខាធិការនៃរាជបណ្ឌិត្យសភាកម្ពុជា ប្រាប់ភ្នំពេញប៉ុស្តិ៍នាថ្ងៃទី១៥ ខែកុម្ភៈ ថា កិច្ចសហប្រតិបត្តិការនេះ ពិតជាមានសារៈសំខាន់ណាស់ ពីព្រោះកន្លងទៅ កម្ពុជាបានក្លាយទៅជាកន្លែងដែលជនបរទេសមកប្រព្រឹត្តអំពើឧក្រិដ្ឋកម្ម ការឆបោកតាមអនឡាញ និងល្បែងស៊ីសងតាមអនឡាញជាដើម ដែលធ្វើឱ្យកេរ្តិ៍ឈ្មោះកម្ពុជាមិនល្អលើឆាកអន្តរជាតិ និងធ្វើឱ្យអ្នកវិនិយោគទុន ឬភ្ញៀវទេសចរខ្លាចអរកម្ពុជា។ លោកថ្លែងថា៖ «តាមពិតកម្ពុជាយើងមិនបានប្រព្រឹត្តអ៊ីចឹងទេ គ្រាន់តែថា មានជនបរទេសមកប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជាយើង ឆ្លងតាមរយៈប្រទេសកម្ពុជាយើង។ អ៊ីចឹង ប្រសិនបើមានការចែករំលែកព័ត៌មាននេះ ខ្ញុំគិតថា វាល្អ ហើយយើងពង្រឹងការអនុវត្តច្បាប់ទាំងសងខាងទៅលើឧក្រិដ្ឋកម្មឆ្លងដែនហ្នឹង»។

យោងតាមសេចក្តីប្រកាសព័ត៌មានក្រសួងការបរទេសចិន កាលពីសប្តាហ៍មុន បានឱ្យដឹងថា ក្នុងជំនួបជាមួយ លោក ហ៊ុន សែន លោក ស៊ី ជីនភីង បានថ្លែងថា ភាគីទាំង២គួរតែអនុវត្តប្រតិបត្តិការពិសេស ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនជាប្រចាំ៕

## ពលករចំណាកស្រុករួមទាំងពលករខ្មែរ ត្រូវបានហាមឃាត់ចំពោះការដណ្តើមការងារពលរដ្ឋថៃ

https://www.khmertimeskh.com/501240025// Khmer Times February 16, 2023

រដ្ឋមន្ត្រីក្រសួងការងារ លោក Suchart Chomklin បានបញ្ជាឱ្យនាយកដ្ឋានការងារ អនុវត្តច្បាប់ឱ្យបានឆាប់រហ័ស ទប់ទល់នឹងការកើនឡើងនៃចំនួនពលករចំណាកស្រុក ដែលចាប់យកការងារដែលបម្រុងទុកសម្រាប់ពលរដ្ឋថៃ។ ចំណាត់ការនេះធ្វើឡើងតាមការណែនាំរបស់នាយករដ្ឋមន្ត្រី ប្រាយុទ្ធ ចាន់អូចា ដើម្បីគ្រប់គ្រងពលករបរទេសឱ្យបានត្រឹមត្រូវ។ ចាប់ពីខែតុលាឆ្នាំមុន រហូតដល់ថ្ងៃច័ន្ទ អាជ្ញាធរបានធ្មក់ចូលកន្លែងធ្វើការចំនួន ១៤,១០៤ នៅទូទាំងប្រទេស ហើយបានរកឃើញថា ពលករចំណាកស្រុកចំនួន ៦០០នាក់ ដែលបានបំពានច្បាប់ការងារបម្រុង។

ក្រសួងបានចុះពិនិត្យលើពលករចំណាកស្រុកចំនួន ១៩៦,៤០២នាក់។ ក្នុងចំណោមកម្មករចំនួន ៦០០នាក់ ដែលបានចាប់យកការងារដែលហាមឃាត់ មានកម្មករចំនួន ២៦៤នាក់ មកពីប្រទេសមីយ៉ាន់ម៉ា ១២១នាក់មកពីកម្ពុជា៩៧នាក់មកពីឡាវ៣៩នាក់មកពីវៀតណាម ៥១នាក់មកពីឥណ្ឌា និង២៨នាក់មកពីប្រទេសផ្សេងៗ ។ លោក Suchart បានព្រមានថា ពលករចំណាកស្រុកនឹងត្រូវប្រឈមនឹងការផាកពិន័យរហូតដល់ ៥០,០០០បាត ចំពោះការធ្វើការដោយគ្មានលិខិតអនុញ្ញាតការងារត្រឹមត្រូវ ឬពាក់ព័ន្ធក្នុងការងារដែលត្រូវបានហាមឃាត់។ និយោជកក៏នឹងត្រូវពិន័យជាប្រាក់ដល់ទៅ ១០០,០០០បាត សម្រាប់ការជួលពលករចំណាកស្រុកម្នាក់ ចំពោះការបំពានច្បាប់គ្រប់គ្រងពលករបរទេសឆ្នាំ២០១៧។ ប្រសិនបើពលករចំណាកស្រុកប្រព្រឹត្តល្មើសម្តងទៀត និយោជករបស់ពួកគេនឹងប្រឈមមុខនឹងការជាប់ពន្ធនាគាររហូតដល់មួយឆ្នាំ និងពិន័យជាប្រាក់រហូតដល់ ២០០,០០០បាត សម្រាប់ពលករចំណាកស្រុកម្នាក់ ឬរងទទួលទោសទាំងពីរករណី។ លោក Suchart បាននិយាយថា ពួកគេក៏នឹងត្រូវរងការព្យួររយៈពេលបីឆ្នាំពីការផ្តល់ការងារដល់ពលករចំណាកស្រុកផងដែរ។

អគ្គនាយកនៃអគ្គនាយកដ្ឋានការងារលោក Pairoj Chotikasathien បាននិយាយថា សេចក្តីប្រកាសរបស់ក្រសួងបានចែងយ៉ាងច្បាស់ថា ពលករចំណាកស្រុកត្រូវបានហាមឃាត់មិនឱ្យធ្វើការក្នុងបញ្ជីការងារជាច្រើនដែលបានបម្រុងទុកសម្រាប់ពលរដ្ឋថៃ ដូចជាអ្នកបើកបរដឹកជញ្ជូនសាធារណៈ ជាងចម្លាក់ឈើ ឬជាងកាត់សក់ជាដើម។ នៅក្រោមអនុស្សរណៈនៃការយោគយល់គ្នាទាក់ទងនឹងការងារ ជនចំណាកស្រុកត្រូវបានកំណត់ត្រឹមតែការងារពីរប្រភេទប៉ុណ្ណោះ គឺការងារមិនមែនជំនាញ និងការងារលក់ទំនិញតាមហាង ដើម្បីធានាថាមិនមានការខ្វះខាតការងារសម្រាប់ជនជាតិថៃ។ លោកបានបន្តថា ការងារដែលត្រូវបានហាមឃាត់ភាគច្រើន ដែលធ្វើដោយពលករចំណាកស្រុកគឺការលក់ដូរតាមផ្លូវ ការងារធ្វើសក់ ការងារដឹកជញ្ជូនសាធារណៈ និងការម៉ាស្សាបែបបុរាណ។

ប្រភពពីនាយកដ្ឋានទី១ នៃការិយាល័យអន្តោប្រវេសន៍បាននិយាយថា កាលពីសប្តាហ៍មុន នគរបាលអន្តោប្រវេសន៍បានចាប់ខ្លួនមនុស្ស ១១នាក់ មកពីប្រទេសមីយ៉ាន់ម៉ាពីបទលក់នំរ៉ូទី និងនំ kebabs ដោយខុសច្បាប់នៅលើផ្លូវ Khao San ដ៏ពេញនិយម។ *Bangkok Post*

# ថ្ងៃទី២១ ខែ កុម្ភៈ ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ២នាក់

http://freshnewsasia.com/index.php/en/localnews/278246-2023-02-16-05-06-07.html 2023-02-16 12:06pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៣ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិនចំនួន ០២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៧៣៩ករណី មានមនុស្ស ១,៧៨៧នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៤៧០សំណើ និងបិទសំណុំរឿង ២៤១សំណើ (រកឃើញមនុស្ស ១,០៩២នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៨ករណី៕

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ២នាក់

http://freshnewsasia.com/index.php/en/localnews/278329-2023-02-16-13-14-31.html 2023-02-16 08:14pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៤ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាមចំនួន ០២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្ដេចក្រឡាហោម សរុប ៧៤០ករណី មានមនុស្ស ១,៧៨៩នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧១១សំណើ និងបិទសំណុំរឿង ២៤១សំណើ (រកឃើញមនុស្ស ១,០៩២នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៩ករណី៕

# កម្ពុជា ស្នើថៃ បន្តការយកចិត្តទុកដាក់ ដល់ពលករខ្មែរ

https://dap-news.com/national/2023/02/17/313011/ BySKK106Posted on February 17, 2023

**ភ្នំពេញ៖ លោក ប្រាក់ សុខុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា បានស្នើឲ្យរដ្ឋាភិបាលថៃ បន្តផ្តល់ការ យកចិត្តទុកដាក់ ចំពោះពលករខ្មែរ និងបន្តផ្តល់អាហារូបករណ៍ ជូនដល់និស្សិតកម្ពុជា ផងដែរ។** ការស្នើរបស់លោក ប្រាក់ សុខុន បែបនេះធ្វើឡើងក្នុងឱកាសអនុញ្ញាតឲ្យលោក ឆឺតកៀត អាត់ថាកន (Cherdkiat Atthakor) ឯកអគ្គរាជទូតថ្មីថៃ ប្រចាំកម្ពុជា ចូលជួបសម្តែងការគួរសម នៅថ្ងៃ១៦ កុម្ភៈ ។ ការស្នើរបស់មន្ត្រីជាន់ខ្ពស់កម្ពុជានេះ ស្របពេលកាលពីចុងឆ្នាំ២០២២ មានពលករខ្មែរមួយចំនួនកំពុងធ្វើការនៅថៃ ព្រួយបារម្ភ ក្រោយអាជ្ញាធរថៃ បានរឹតបន្តឹងច្បាប់ការងារ ដោយសារក្រុមហ៊ុនខ្លះ បានបញ្ជូនពលករទៅធ្វើការនៅថៃ មិនមានឯកសារត្រឹមត្រូវ។

បើតាមមន្ត្រីម្នាក់ផ្នែកអន្តោប្រវេសន៍ប្រចាំប្រទេសថៃ នៃអង្គការសង់ត្រាល់គឺថាច្បាប់ការងារនៅថៃ ប្រសិនបើពលករខ្មែរ ចូលមកធ្វើការនៅប្រទេសនេះ តាមរយៈប្រព័ន្ធ MoU និងប្រព័ន្ធច្បាប់ការងារត្រឹមត្រូវ ពលករទាំងនោះមិនមានការ ព្រួយបារម្ភឡើយ ប៉ុន្តែពលករខ្មែរមួយចំនួនមកប្រទេសថៃដោយមិនមានឯកសារគ្រប់គ្រាន់ ដោយសារចំណាយលើការ ធ្វើឯកសារវាមានតម្លៃថ្លៃនោះគឺមានការបារម្ភហើយ ។

សូមបញ្ជាក់ថា យោងតាមរបាយការណ៍របស់ក្រសួងការងារ គឺមានពលករកម្ពុជាកំពុងធ្វើការនៅបរទេស ជាង១លាន ៣សែននាក់។ ក្នុងនោះជាង១លាន២សែននាក់ ធ្វើការនៅថៃ , ជាង៤ម៉ឺន៥ពាន់នាក់ នៅកូរ៉េខាងត្បូង , ២ម៉ឺន៣ពាន់នាក់ នៅម៉ាឡេស៊ី , ១ម៉ឺន១ពាន់នាក់នៅជប៉ុន , ជាង៨០០នាក់នៅសិង្ហបុរី , ២០០នាក់នៅហុងកុង និង៤៣នាក់ នៅអារ៉ាប៊ីសាអ៊ូឌីត៕

# ពលករខ្មែរចំនួន១២១នាក់ នៅប្រទេសថៃ ត្រូវបានចោទប្រកាន់ថាចាប់យកការងាររបស់ពលរដ្ឋថៃ

https://www.khmertimeskh.com/501241290// February 19, 2023

រដ្ឋមន្ត្រីក្រសួងការងារថៃ លោក Suchart Chomklin បានណែនាំឱ្យនាយកដ្ឋានការងារ អនុវត្តច្បាប់ឱ្យបានធាប់រហ័ស ចំពោះការកើនឡើងនៃចំនួនពលករចំណាកស្រុក ដែលចាប់យកការងារ ដែលបម្រុងទុកសម្រាប់តែពលរដ្ឋថៃ។ ចំណាត់ការនេះធ្វើឡើងតាមការណែនាំរបស់នាយករដ្ឋមន្ត្រីថៃ ប្រាយុទ្ធ ចាន់អូចា ដើម្បីគ្រប់គ្រងពលករបរទេសឱ្យបានហ្មត់ចត់។ ចាប់ពីខែតុលា ឆ្នាំ២០២២ ដល់ថ្ងៃច័ន្ទ ទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ អាជ្ញាធរបានឆ្មក់ចូលកន្លែងធ្វើការចំនួន ១៤,១០៤កន្លែង នៅទូទាំងប្រទេស ហើយបានរកឃើញថាពលករចំនួន៦០០នាក់បានបំពានច្បាប់ការងារបម្រុង។ ក្រសួងបានចុះត្រួតពិនិត្យពលករចំណាកស្រុកចំនួន ១៩៦,៤០២នាក់។ ក្នុងចំណោមពលករចំនួន ៦០០នាក់ ដែលបានចាប់យកការងារបំរុង មានខ្មែរ ១២១នាក់ មីយ៉ាន់ម៉ា២៦៤នាក់ ឡាវ៩៧នាក់ វៀតណាម៣៩នាក់ ឥណ្ឌា៥១នាក់ និងមកពីប្រទេសផ្សេងចំនួន២៨នាក់។

លោក Suchart បានព្រមានថា ពលករចំណាកស្រុកនឹងត្រូវទទួលទោសពិន័យជាប្រាក់ចំនួន ៥០,០០០បាត ចំពោះការធ្វើការដោយគ្មានលិខិតអនុញ្ញាតការងារត្រឹមត្រូវ ឬចូលរួមក្នុងការងារដែលត្រូវបានហាមឃាត់។ និយោជកក៏នឹងត្រូវពិន័យជាប្រាក់ដល់ទៅ ១០០,០០០បាត សម្រាប់ពលករចំណាកស្រុក ក្នុងម្នាក់ ដែលពួកគេជួលផងដែរ ក្នុងការអនុញ្ញាតឱ្យពួកគេបំពានច្បាប់ឆ្នាំ២០១៧ ស្តីពីការគ្រប់គ្រងពលករបរទេស។ ប្រសិនបើពលករចំណាកស្រុកប្រព្រឹត្តល្មើសម្តងទៀត និយោជករបស់ពួកគេប្រឈមមុខនឹងការជាប់ពន្ធនាគារមួយឆ្នាំ ពិន័យជាប្រាក់រហូតដល់ ២០០,០០០ បាតក្នុងពលករម្នាក់ ឬទទួលរងទាំងពីរបទល្មើស។ ពួកគេក៏នឹងទទួលរងការព្យួរការងាររយៈពេល ៣ឆ្នាំ ពីបទជួលពលករចំណាកស្រុកផងដែរ។ Bangkok post

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាម ៣នាក់

http://freshnewsasia.com/index.php/en/localnews/278590-2023-02-19-12-18-32.html 2023-02-19 07:18pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៧ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០២ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិវៀតណាមចំនួន ០៣នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧៤៨ករណី មានមនុស្ស ១,៨០២នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧១៦សំណើ និងបិទសំណុំរឿង ២៤៤សំណើ (រកឃើញមនុស្ស ១,០៩៦នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣២ករណី៕

## លោក ស ខេង គ្រើនរំឭក
## ជាថ្មីឱ្យអាជ្ញាធរយកចិត្តទុកដាក់អនុវត្តគោលនយោបាយ ភូមិ ឃុំ មានសុវត្ថិភាព

https://www.postkhmer.com/national/2023-02-19-1835-247151.html ឡាយ សាមាន | Publication date 19 February 2023 | 18:35 ICT

**ព្រៃវែង៖** រដ្ឋមន្ត្រីក្រសួងមហាផ្ទៃលោក ស ខេង គ្រើនរំឭកជាថ្មីទៀតឱ្យអាជ្ញាធរមូលដ្ឋាន ត្រូវរួមសហការគ្នាជាមួយ ប្រជាពលរដ្ឋ ដើម្បីជំរុញការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងការដោះស្រាយបញ្ហាប្រឈម និងសំណូមពរនានារបស់ប្រជាពលរដ្ឋឱ្យទាន់ពេលវេលា និងមានប្រសិទ្ធភាព។

ការលើកឡើងជាថ្មី ធ្វើឡើងក្នុងឱកាសអញ្ជើញជាអធិបតីក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមាព្រះវិហារ និងឆ្លងសមិទ្ធផលនានា នៅវត្តមុនីរស្មីព្រៃត្បែង ស្ថិតនៅភូមិព្រៃត្បែង ឃុំត្របែក ស្រុកកំចាយមារ ខេត្តព្រៃវែង នៅថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ ២០២៣។ ក្នុងនាមក្រុមការងាររាជរដ្ឋាភិបាល និងក្រុមការងារគណបក្សប្រជាជនកម្ពុជាខេត្តព្រៃវែង លោក ស ខេង បានថ្លែងកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋបាលស្រុកកំចាយមារ និងរដ្ឋបាលឃុំ ព្រមទាំងអាជ្ញាធរភូមិ និងប្រជាពលរដ្ឋដែលបានខិតខំរួមគ្នាការពារសុខសន្តិភាព សុខសុវត្ថិភាព រួមគ្នាអភិវឌ្ឍមូលដ្ឋានរបស់ខ្លួនទទួលបានលទ្ធផលគួរជាទីមោទនៈ។ សមិទ្ធផលនានានៅក្នុងវត្តនេះរួមទាំងសាលាបឋមសិក្សា ដែលបានថវិកាពីព្រះចៅអធិការ អាចារ្យគណៈកម្មការវត្ត ពុទ្ធបរិស័ទចំណុះជើងវត្ត និងសប្បុរសជន ពិតជារួមចំណែកយ៉ាងសំខាន់សម្រាប់ការកសាងសង្គមជាតិ ក្នុងឱកាសដែលកម្ពុជាកំពុងមានសុខសន្តិភាពទាំងស្រុង មានស្ថិរភាព និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច សង្គមឱ្យកាន់តែរីកចម្រើន។

ទន្ទឹមនោះដែរលោក ស ខេង បានណែនាំឱ្យអាជ្ញាធរមូលដ្ឋាន ត្រូវសហការរួមគ្នាជាមួយប្រជាពលរដ្ឋក្នុងកាអនុវត្តគោលនយោបាយភូមិ ឃុំ មានសុវត្ថិភាព ប្រកបដោយជោគជ័យ ដើម្បីឆ្លើយតបចង្អុលវិស័យរបស់រដ្ឋាភិបាលក្នុងការកសាងប្រទេសជាតិឱ្យមានការរីចកម្រើន និងមានសន្តិភាព។ លោកណែនាំថា៖« អាជ្ញាធរមូលដ្ឋាន រួមសហការគ្នាជាមួយប្រជាពលរដ្ឋ ដើម្បីជំរុញការអនុវត្តគោលនយោបាយ ភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព និងការដោះស្រាយបញ្ហាប្រឈម សំណូមពរនានារបស់ប្រជាពលរដ្ឋ»។ លោកស ខេង បានទាញការកត់សម្គាល់ថា សុខសន្តិ

ភាព និងស្ថិរភាពជាតិ ជាសមិទ្ធផលស្នូល ដែលនាំឱ្យកើតមានវឌ្ឍនភាពនូវសមិទ្ធផលសំខាន់ៗផ្សេងទៀតរបស់ជាតិ រួមទាំងសមិទ្ធផលដែលបានប្រារព្ធពិធីសម្ពោធនាថ្ងៃនេះ។

នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការលីកាដូ លោក អំ សំអាត សង្កេតឃើញថា សម្រាប់គោលនយោបាយភូមិ ឃុំ សង្កាត់មានសុវត្ថិភាព របស់រាជរដ្ឋាភិបាល គឺជាគោលនយោបាយល្អ ក្នុងគោលបំណងធ្វើឱ្យប្រជាពលរដ្ឋក្នុងមូលដ្ឋានអាចរស់នៅប្រកបដោយភាពសុខដុមរមនា មានសន្តិសុខ សុវត្ថិភាព និងវិស្ថានល្អ។ ប៉ុន្តែលោកលើកឡើងថា ការអនុវត្តជាក់ស្តែងរបស់មន្ត្រីអាជ្ញាធរមូលដ្ឋានមួយចំនួន មិនទាន់ឆ្លើយតបទៅតាមគោលនយោបាយនេះនៅឡើយទេ ខណៈប្រជាពលរដ្ឋខ្លះ នៅតែលើកឡើងពីបញ្ហាមួយចំនួន ដូចជាករណីគ្រឿងញៀនដែលបច្ចុប្បន្នគឺរាលដាលដល់ជនបទ ល្បែងស៊ីសង និងចោរកម្មមួយចំនួន នៅតែកើតមានឡើង។ លោកថា៖« ដូច្នេះដើម្បីឱ្យគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព មានប្រសិទ្ធភាព ទាល់តែមន្ត្រីមូលដ្ឋានត្រូវចូលរួមអនុវត្តឱ្យបានពេញលេញ និងមានការចូលរួមពីប្រជាពលរដ្ឋ និងមានទំនុកចិត្តពីពលរដ្ឋ»។

សូមជម្រាបថា រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចកែលម្អលក្ខណសម្បត្តិគោលនយោបាយ «ភូមិ-ឃុំ-សង្កាត់មានសុវត្ថិភាព» ឡើងវិញ ដែលមាន៧ចំណុច និងបានដាក់ចេញឱ្យអនុវត្តកាលពីខែមករា ឆ្នាំ ២០២១ ដែលមានក្រសួងមហាផ្ទៃជាសេនាធិការ។ គោលនយោបាយនេះ ត្រូវបានយកទៅផ្សព្វផ្សាយយ៉ាងទូលំទូលាយទាំងក្នុងវិស័យសាធារណៈទាំងក្នុងវិស័យឯកជន ដើម្បីធ្វើឱ្យភូមិ ឃុំ សង្កាត់មានសន្តិសុខ មានសុវត្ថិភាពនិងបរិស្ថានល្អ៕

# ថ្ងៃទី២២ ខែ កុម្ភៈ ឆ្នាំ២០២៣

## ជនរងគ្រោះនៃការជួញដូរមនុស្សបានបោកបញ្ឆោត និងលក់មិត្តជិតស្និទ្ធខ្លួនមកកម្ពុជា

https://www.khmertimeskh.com/501241899// Khmer Times February 20, 2023

បុរសម្នាក់នៅខេត្ត Binh Dinh បានបោកបញ្ឆោតមិត្តជិតស្និទ្ធរបស់ខ្លួនឱ្យក្លាយជាកម្មករខុសច្បាប់នៅកម្ពុជា ដើម្បីការពារខ្លួនពីការវាយដំពីថៅកែ។ Huynh Thanh Nhon មកពីក្រុង Quy Nhon ត្រូវបាននគរបាលខេត្ត Binh Dinh ឃាត់ខ្លួនអស់រយៈពេល៤ ខែខណៈដែលជននេះកំពុងស្ថិតនៅក្រោមការស៊ើបអង្កេតពីបទជួញដូរមនុស្ស។ នគរបាលបាននិយាយថា Nhon បានសហការជាមួយមនុស្សជាច្រើននាក់ក្នុងការចរាចរមនុស្សចូលមកកម្ពុជាដើម្បីធ្វើការផ្ទុយពីឆន្ទៈរបស់ពួកគេ។ ជនរងគ្រោះមិនត្រូវបានគេអនុញ្ញាតឱ្យចាកចេញពីកន្លែងធ្វើការ ក៏ដូចជាត្រូវបានគេវាយដំ និងបង្អត់អាហារជាច្រើនម៉ោង។ ពួកគេត្រូវបង្ខំឱ្យបង់ប្រាក់ប្រសិនបើពួកគេចង់ត្រឡប់ទៅប្រទេសវៀតណាមវិញ។ Nhon បាននិយាយថាខ្លួនគាត់ផ្ទាល់គឺជាជនរងគ្រោះនៃការជួញដូរមនុស្សដែលត្រូវបានបោកបញ្ឆោតឱ្យទៅប្រទេសកម្ពុជាដោយធ្វើការក្នុងស្ថានភាពគ្រោះថ្នាក់ ហើយមិនអាចត្រឡប់ទៅប្រទេសវៀតណាមបានទេដោយសារតែខ្លួនត្រូវបានគេបង្ខាំង។

គាត់បាននិយាយថា គាត់ត្រូវបានគេណែនាំឱ្យធ្វើការងារដោយបុរសមិនបញ្ចេញឈ្មោះតាមអ៊ីនធឺណិតក្នុងខែកុម្ភៈឆ្នាំមុន។ បុរសនោះបានអះអាងថា ប្រាក់ខែការងារគឺពី ៧០០ ទៅ ១០០០ ដុល្លារក្នុងមួយខែ។ បន្ទាប់មក Nhon បានធ្វើដំណើរទៅទីក្រុងហូជីមិញ ជាកន្លែងដែលខ្លួនបានធ្វើដំណើរតាមឡាន។ បន្ទាប់មក មនុស្សដែលនៅទីនោះបានណែនាំគាត់ឱ្យបង្កើតគណនីអនឡាញជាច្រើន ដើម្បីបញ្ឆោតអ្នកដទៃឱ្យចូលរួមជាមួយក្រុមខ្លួន។ Nhon បានបន្តថា៖ «បន្ទាប់ពីជិតពីរសប្តាហ៍ខ្ញុំបានដឹងថាខ្ញុំនៅក្នុងប្រទេសកម្ពុជាមិនមែនប្រទេសវៀតណាមទេព្រោះខ្ញុំមិនត្រូវបានគេអនុញ្ញាតឱ្យចេញក្រៅ»។ គាត់បាននិយាយទៀតថា៖ «ជារៀងរាល់ថ្ងៃ ខ្ញុំត្រូវធ្វើការ ១៦ ម៉ោង ហើយអាចសម្រាកបានតែពេលយប់។ «ប្រសិនបើខ្ញុំធ្វើការមិនបានល្អ ខ្ញុំនឹងត្រូវគេវាយដំ បង្អត់អត់អាហារ ឬលក់ទៅ

កន្លែងផ្សេង»។ ប៉ុន្មានខែបន្ទាប់ពីគាត់បានទៅដល់ទីនោះជាលើកដំបូង Nhon ត្រូវបានលក់ទៅឱ្យក្រុមហ៊ុនមួយផ្សេងទៀតដែលជាកម្មសិទ្ធិរបស់ជនជាតិចិន ហើយត្រូវបានបង្ខំឱ្យធ្វើការងារដូចគ្នា។ គាត់និយាយថា គាត់ត្រូវបានគេបង្ខំអោយធ្វើការតាមប្រព័ន្ធអ៊ីនធឺណេត ដើម្បីល្បួងអោយអ្នកផ្សេងទៀតបង់ប្រាក់អោយក្រុមហ៊ុនពី៨,៣៩៦-១២,៥៩៤ ដុល្លារក្នុងមួយខែ និងត្រូវបានបង្ខំឱ្យធ្វើការថែមម៉ោង ប៉ុន្តែប្រាក់ខែរបស់គាត់ត្រូវបានកាត់បន្ថយ។

Nhon បាននិយាយថាគាត់ក៏ត្រូវបោកបញ្ឆោតមនុស្សឱ្យចូលរួមជាមួយក្រុមហ៊ុននេះផងដែរដោយគាត់ត្រូវបានគេសន្យាថា គាត់នឹងបាន១០០ ដុល្លារសម្រាប់មនុស្សម្នាក់ដែលគាត់ជ្រើសរើសបាន។ Nhonបាននិយាយថា «ដើម្បីបានលុយខ្លះ និងមិនអត់ឃ្លាន ការពារកុំអោយគេវាយធ្វើបាប ខ្ញុំបានបោកបញ្ឆោតមិត្តខ្ញុំបីនាក់ឲ្យមកទីនេះ»។ «តែខ្ញុំមិនបានទទួលលុយអីនោះទេ»។ នៅខែមីនា ឆ្នាំ២០២២ Nhon បានប្រាប់មិត្តមួយចំនួនតាមរយៈប្រព័ន្ធផ្សព្វផ្សាយសង្គមថា គាត់កំពុង "ធ្វើការពាក់ព័ន្ធនឹងកម្មវិធីហ្គេមលើកុំព្យូទ័រក្នុងខេត្ត Tay Ninh (ជាប់ព្រំដែនកម្ពុជា)" ជាការងារស្រាល និងមិនពិបាក ដោយទទួលបានប្រាក់ខែពី១៧ ទៅ២៤ លានដុង។ បន្ទាប់មកគាត់បានបញ្ចុះបញ្ចូលមិត្តរបស់គាត់ឱ្យចូលរួមជាមួយគាត់។ បុរសអាយុ១៨ឆ្នាំម្នាក់ជាមិត្តជិតស្និទ្ធរបស់ឈ្មោះ Nhon បានធ្លាក់ចូលក្នុងអន្ទាក់។

មិត្តភក្តិរូបនេះបាននិយាយថា៖ «ពេលខ្ញុំដឹងថាខ្ញុំត្រូវគេបោកឱ្យទៅស្រុកខ្មែរ ខ្ញុំបានទូរស័ព្ទទៅNhon ហើយគាត់និយាយថា មិនអីទេ មុនពេលដែលគាត់បានផ្តាច់ការទាក់ទងតាមទូរស័ព្ទ និងបណ្តាញសង្គម។ គាត់បាននិយាយថាគាត់ត្រូវធ្វើការពី១៦-១៧ ម៉ោងក្នុងមួយថ្ងៃនៅក្នុងកន្លែងបិទជិត។ មានមនុស្សប្រដាប់ដោយរំពាត់អគ្គិសនីបានឈរយាមគាត់។ ពួកគេវាយដំកម្មករ ហើយទុកឱ្យពួកគេអត់ឃ្លានដោយមិនញញើតប្រសិនបើជនរងគ្រោះធ្វើការមិនបានល្អ ឬមិនបានបោកបញ្ឆោតអ្នកដទៃឱ្យបង់ប្រាក់អោយពួកគេ។ ក្នុងរយៈពេល៨ខែចាប់តាំងពីគាត់ត្រូវបានលក់មកប្រទេសកម្ពុជាយុវជនអាយុ១៨ ឆ្នាំរូបនេះត្រូវបានលក់ទៅឱ្យក្រុមហ៊ុនចំនួនបីផ្សេងគ្នា។ នៅខែកញ្ញា ឆ្នាំ២០២២ គាត់ត្រូវបានលោះដោយគ្រួសាររបស់គាត់ក្នុងតម្លៃ៨០ លានដុង។ ក្រុមគ្រួសាររបស់ Nhon ក៏បានបង់ប្រាក់លោះគាត់កាលពីឆ្នាំមុនមុនពេលត្រូវបាននគរបាលចាប់ខ្លួន។

លោក Truong Van Phung អនុប្រធានផ្នែកស៊ើបអង្កេតនៃនាយកដ្ឋាននគរបាលខេត្ត Binh Dinh បាននិយាយថា ក្រុមជួញដូរមនុស្សតែងតែកំណត់គោលដៅលើយុវជនដែលបោះបង់ការសិក្សា និងអ្នកដែលញៀនហ្គេមអនឡាញ។ វៀតណាមត្រូវបានគេជួញដូរមកកម្ពុជាជាកម្មករខុសច្បាប់អស់ជាច្រើនឆ្នាំមកហើយ។ ស្ថានទូតវៀតណាមនៅទីនោះបាននិយាយថា មកទល់ពេលនេះ ខ្លួនបានធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋវៀតណាមចំនួន ៨០០ នាក់ត្រឡប់ពីប្រទេសកម្ពុជាវិញ៕ *VnExpress*

## តុលាការកំពូល សម្រេចដោះលែង បុរសចិនជាប់ចោទ៣នាក់ នៅក្រៅឃុំ បណ្តោះអាសន្ន ជាប់ពាក់ព័ន្ធនឹង បទល្មើសជួញដូរមនុស្ស និងចាប់បង្ខាំងមនុស្សដើម្បីជំរិតទារប្រាក់

https://cen.com.kh/archives/621054.html Posted ByPen Srey NeatFebruary 20, 2023

ភ្នំពេញ: តុលាការកំពូលកាលពីព្រឹក ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២៣ នេះ បាន ប្រកាសសាលដីកា និងបានសម្រេចដោះលែង ជនជាប់ចោទ ជនជាតិ ចំនួន ៣នាក់ ឱ្យនៅក្រៅឃុំបណ្តោះអាសន្ន ជាប់ពាក់ព័ន្ធនឹងការជួញដូរមនុស្ស និងចាប់ឃុំឃាំង និងបង្ខាំង មនុស្សដោយខុសច្បាប់ ដើម្បីជំរិតទារប្រាក់ ប្រព្រឹត្តនៅ អគារជើងឆាយ នៅភូមិ២ សង្កាត់លេខ២ ខេត្តព្រះសីហនុ នៅក្រុមហ៊ុនអូស្កា ភូមិ១ សង្កាត់លេខ៣ ក្រុងព្រះសីហនុ ភូមិគគីរ ឃុំបិតត្រាំង ស្រុកព្រៃនប់ ខេត្តព្រះសីហនុ កាលកាលពី អំឡុងឆ្នាំ ២០២២។

លោក យូរ ឧត្តរា ជាប្រធានចៅក្រមជំនុំជម្រះនៃ តុលាការកំពូល បានឱ្យដឹងថា ជនជាប់ចោទ ៣នាក់មានឈ្មោះ ៖ ១-ឈ្មោះ YU GONG CHENG ភេទប្រុស អាយុ ៣០ ឆ្នាំ ( កើតឆ្នាំ ១៩៩០ ) ជនជាតិចិន ។ ២- ឈ្មោះ

LIU YUAN HUANG ភេទប្រុស អាយុ ៣៦ ឆ្នាំ ( កើតឆ្នាំ ១៩៨៦ ) ។ ៣- ឈ្មោះ YU XUN CAI ភេទប្រុស អាយុ ៣២ ឆ្នាំ កើតឆ្នាំ ( ១៩៩២ ) ជនជាតិចិន ។ នៅក្នុងសំណុំរឿងក្តីនេះ សាលាដំបូងខេត្តព្រះសីហនុ កាលពីថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០២២ បានបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្ន ពួកគេទាំង៣នាក់ ពីបទ “ ជួញដូរមនុស្ស និងចាប ឃុំឃាំង បង្ខាំងមនុស្សដោយខុសច្បាប់ និងកំហែងយក តាមមាត្រា ១៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរ មនុស្ស និង អំពើធ្វើអាជីវកម្មផ្លូវភេទ និង តាម ២៥៣ មាត្រា ៣៣៦ នៃក្រមព្រហ្មទណ្ឌ ។ ពួកគេបាន ប្តឹងឧទ្ធរណ៍ តែសាលាឧទ្ធរណ៍ព្រះសីហនុ បានតម្កល់ សេចក្តីសម្រេចរបស់តុលាការខេត្តព្រះសីហនុ ដដែល។ ជនជាប់ចោទ ក៏ បានបន្តប្តឹងសាទុក្ខ មកកាន់តុលាការកំពូលទៀត។ ពួកគេ ត្រូវបានចាប់ឃាត់ខ្លួន កាលពីថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០២២ នៅ ខេត្តព្រះសីហនុ។ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## តុលាការកំពូល តម្កល់ទោស ស្ត្រីជនជាតិវៀតណាមម្នាក់ ជាប់គុក៥ ឆ្នាំ ពាក់ព័ន្ធនឹងការ បើកកន្លែងម៉ាស្សាបង្កប់សេវាផ្លូវភេទ

https://cen.com.kh/archives/621316.html Posted ByPen Srey NeatFebruary 20, 2023

ភ្នំពេញ: តុលាការកំពូល កាលពីព្រឹកថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០២៣ នេះ បានប្រកាសសាលដីកា តម្កល់ ទោស ស្ត្រីជាប់ចោទ ជនជាតិវៀតណាមម្នាក់ ជាប់ពន្ធនាគារកំណត់ ០៥ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការបើកកន្លែងម៉ាស្សា បង្កប់សេវាផ្លូវភេទ ប្រព្រឹត្តនៅចំណុចហាង King Sora Vip Massage ផ្ទះលេខ៩១ ផ្លូវលេខ៣៥០ ភូមិ៤ សង្កាត់ បឹងកេងកង៣ ខណ្ឌ បឹងកេងកង រាជធានីភ្នំពេញ កាលពីអំឡុងឆ្នាំ ២០២០។លោក យូរ ឧត្តរា ជាប្រធានចៅក្រម ប្រឹក្សាជំនុំជម្រះ នៃ តុលាការកំពូល បានថ្លែងឲ្យដឹងថា ជនជាប់ចោទរូបនេះ មានឈ្មោះ ហ្វាម ធីមិនធូ ភេទស្រី អាយុ ៣៣ ឆ្នាំ មុខរបរ អ្នកធ្វើការក្នុងហាងម៉ាស្សា ។

នៅក្នុងសំណុំរឿងនេះ ជនជាប់ចោទ ហ្វាម ធីមិន ត្រូវបានសាលាដំបូងរាជធានីភ្នំពេញ កាលពីថ្ងៃទី ៦ ខែ កក្កដា ឆ្នាំ ២០២១ ផ្តន្ទាទោស ដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ ក្រោមការចោទប្រកាន់ពីបទ : សញ្ញារកម្មមានស្ថាន ទម្ងន់ទោសទក់ទងនឹងជនរងគ្រោះ តាមមាត្រា ២៥ និង មាត្រា ២៧ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ ។ ជនជាប់ចោទ បានប្តឹងឧទ្ធរណ៍ ខណៈ សាលាឧទ្ធរណ៍រាជធានីភ្នំពេញ បានតម្កល់ ទណ្ឌកម្មរបស់គាត់រក្សាទុកជាបានការដែល ហើយគាត់ ក៏បានបន្តប្តឹងសារទុក្ខ មកកាន់តុលាការកំពូលទៀត។

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិ ៣៦នាក់

http://freshnewsasia.com/index.php/en/localnews/278649-2023-02-20-07-00-56.html 2023-02-20 02:00pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី១៨ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៥ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេសចំនួន ៣៦នា ក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់ប ណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧៥១ករណី មានមនុស្ស ១,៨៣៤នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧១៦សំណើ និងបិទសំណុំរឿង ២៤៤សំណើ (រកឃើញមនុស្ស ១,០៩៦នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣៥ករណី៕

## កូរ៉េ សន្យាផ្តល់កូតា សម្រាប់ពលករកម្ពុជា ឱ្យបានលើស ១ម៉ឺននាក់ ក្នុងឆ្នាំ២០២៣ នេះ

https://kohsantepheapdaily.com.kh/article/1688097.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ២០ ខែ កុម្ភៈ ឆ្នាំ ២០២៣ ម៉ោង ១៩:២៨

ភ្នំពេញ៖ កូរ៉េ បានសន្យាថា នឹងបង្កើនកូតាពលករកម្ពុជា ឱ្យបានលើស ១ម៉ឺននាក់ ក្នុងឆ្នាំ២០២៣ នេះ និងកាន់តែច្រើន នៅឆ្នាំបន្តបន្ទាប់ទៅមុខទៀត។ ខណៈពេល ក្នុងឆ្នាំ២០២២ កម្ពុជាទទួលបានចំណាត់ថ្នាក់ល្អ ក្នុងវិស័យបញ្ជូនពលករទៅធ្វើការ នៅសាធារណរដ្ឋកូរ៉េ ហើយតាមរយៈការវាយតម្លៃពីខាងភាគីកូរ៉េ ឃើញថា ពលករកម្ពុជា មានភាពស្មោះត្រង់ ឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់នឹងការងារ ធ្វើឱ្យនិយោជកកូរ៉េ ស្រលាញ់ពេញចិត្តជាខ្លាំង។ នេះបើតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

លទ្ធផលនៃកិច្ចពិភាក្សានេះ ធ្វើឡើងរវាងលោកបណ្ឌិត UH SOOBONG ប្រធានអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ ជាមួយលោកបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ នារសៀលថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ នេះ នៅទីស្តីការក្រសួងការងារ ដើម្បីពិភាក្សាអំពីវិធីសាស្រ្តក្នុងការជ្រើសរើស ទទួលពលករឱ្យបានឆាប់រហ័ស និងស្វែងយល់អំពីគម្រោងធ្វើសមាហរណកម្មពលករកម្ពុជាក្រោយពេលត្រឡប់មកមាតុភូមិវិញ។

នៅក្នុងជំនួបនោះ លោកបណ្ឌិត អ៊ិត សំហេង លើកឡើងថា សាធារណរដ្ឋកូរ៉េជាមិត្តដ៏ល្អ ដែលបានចូលរួមអភិវឌ្ឍប្រទេសកម្ពុជា ជាពិសេសវិស័យការទូត និងកិច្ចសហប្រតិបត្តិការរបស់ប្រទេសយើងទាំងពីរ បានក្លាយជាដៃគូយុទ្ធសាស្រ្តគ្រប់ជ្រុងជ្រោយ។ លោករដ្ឋមន្ត្រី គូសបញ្ជាក់ដែរថា បើទោះស្ថិតក្នុងដំណាក់កាលកូវីដ-១៩ ក្តី សាធារណរដ្ឋកូរ៉េ នៅតែបន្តជ្រើសរើសពលករកម្ពុជាទៅបម្រើការងារនៅទីនោះ ព្រមទាំងមើលថែទាំ និងគាំពារពលករកម្ពុជាបានយ៉ាងល្អទៀតផង។ ជាមួយការដែលពលករកម្ពុជា បានវិលត្រឡប់ពីបម្រើការងារនៅសាធារណរដ្ឋកូរ៉េវិញ ឯកឧត្តមបណ្ឌិត សង្កេតឃើញថា ពួកគាត់មានវឌ្ឍនភាព និងមានការប្រែប្រួលសេដ្ឋកិច្ចជីវភាពយ៉ាងខ្លាំង ដោយអ្នកខ្លះប្រែក្លាយជាសហគ្រិនភាព និងជាអ្នកវិនិយោគដ៏ល្បីល្បាញ។

ទន្ទឹមនឹងនេះ លោកបណ្ឌិត អ៊ិត សំហេង បានថ្លែងអំណរគុណដល់ ក្រសួងមុខរបរ និងការងារ នៃសាធារណរដ្ឋកូរ៉េ ដែលបានយកចិត្តទុកដាក់ផ្តល់សេវាការងារជូនដល់ពលករកម្ពុជា បានយ៉ាងល្អ ដោយនៅក្នុងឆ្នាំ ២០២៣នេះ ភាគីកូរ៉េសន្យា ផ្តល់កូតាជូនពលករកម្ពុជា ជាងមួយម៉ឺននាក់ទៀតនោះ តាមរយៈគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស (MTOSB) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលនឹងធ្វើការជ្រើសរើសពលករកម្ពុជា ដែលមានសមត្ថភាព និងឧស្សាហ៍ព្យាយាមក្នុងការបំពេញការងារជូនដល់និយោជកកូរ៉េ ឱ្យកាន់តែមានផលិតភាពខ្ពស់។

ប្រធានអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ បានបញ្ជាក់ជូនលោករដ្ឋមន្ត្រីថា ភាគីកូរ៉េនឹងរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញដល់ពលករបរទេស ដែលចប់អាណត្តិការងារនៅកូរ៉េ ដោយក្នុងនោះកម្ពុជាអាចនឹងក្លាយជាប្រទេសអាទិភាព ដែលទទួលបានពីគម្រោងថ្មីនេះ ដោយគម្រោងនេះមានគោលដៅផ្តល់ប្រាក់កម្ចីជួយដល់ពលករ ដើម្បីអាចបើកអាជីវកម្មមួយបានសមរម្យ និងមានប្រាក់ចំណូលបានយ៉ាងប្រសើរ។

លោកបណ្ឌិត អ៊ិត សំហេង ពិតជារីករាយចំពោះគម្រោង ដែលភាគីកូរ៉េជួយបណ្តុះបណ្តាលជំនាញដល់ពលករបរទេសដែលចប់អណត្តិការងារនៅកូរ៉េ ទទួលបានការបណ្តុះបណ្តាលជំនាញដ៏ជាក់លាក់មួយ ដើម្បីមានលទ្ធភាពគ្រប់គ្រាន់ក្នុងការបង្កើតអាជីវកម្មផ្ទាល់ខ្លួន។ លោករដ្ឋមន្ត្រី ចង់ឱ្យពលករកម្ពុជា ស្ថិតក្នុងអាទិភាពខ្ពស់មួយ ក្នុងចំណោមប្រទេសដទៃទៀត ដែលកូរ៉េគិតថា នឹងធ្វើការជ្រើសរើស៕

# ថ្ងៃទី២៣ ខែ កុម្ភៈ ឆ្នាំ២០២៣

## FATF **សម្រេចដកកម្ពុជាចេញពីបញ្ជីប្រផេះខាងលាងលុយកខ្វក់**

https://kohsantepheapdaily.com.kh/article/1689611.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ ២២ ខែ កុម្ភៈ ឆ្នាំ ២០២៣ ម៉ោង ១៦:៥៧

រាជធានីភ្នំពេញ ៖ សម្តេច ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានប្រកាសឲ្យដឹងថា អង្គការហ្វាត (FATF) បានសម្រេចដកប្រទេសកម្ពុជាចេញពីបញ្ជីប្រផេះហើយ។ សម្តេច ស ខេង លើកឡើងបែបនេះ នាឱកាសអញ្ជើញបើកសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ របស់ក្រសួងមហាផ្ទៃ នាថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ នៅសណ្ឋាគារសុខាភ្នំពេញ។ សម្តេចក្រឡាហោម ស ខេង បានលើកឡើងថា «តាមរបាយការណ៍របស់ ឯកឧត្តម កើត រិទ្ធ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បានឲ្យដឹងថា មហាសន្និបាតនៃអង្គការ FATF កាលពីថ្ងៃទី២១ ដែលកិច្ចប្រជុំត្រៀមបំរុង សម្រាប់ថ្ងៃទី២៤ នោះ គឺបានសម្រេចដកកម្ពុជាចេញពីបញ្ជីប្រផេះ។ ប៉ុន្តែប្រកាសជាផ្លូវការតាមព័ត៌មាន គេនឹងធ្វើម៉ោង១០ (ម៉ោងនៅកម្ពុជា) នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ យើងរងចាំព័ត៌មាននេះទាំងអស់គ្នា»។

សម្តេចលើកឡើងថា ដំណឹងនេះពិតជាល្អសម្រាប់កម្ពុជាហើយ ប៉ុន្តែស្របពេលជាមួយនឹងអ្វីដែលទទួលនេះក៏មិនត្រូវភ្លេចខ្លួនផងដែរក្នុងការបន្តការពារកម្ពុជាក្នុងកិច្ចសហការជាមួយអង្គការ FATF ។ សម្តេចក្រឡាហោម បានបន្តថា «បន្ទាប់មកទៀត គឺមិនត្រូវភ្លេចខ្លួន ក្នុងការកិច្ចសហប្រតិបត្តិការនានានោះទេ ផ្ទុយទៅវិញ គឺខិតខំប្រឹងប្រែងបន្ថែមទៀត ព្រមទាំងរួមសាមគ្គីគ្នាទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីបន្តការពារឲ្យបានដាច់ខាតនូវលទ្ធផលដែលខិតខំជាមួយអង្គការ FATFនេះ» ។

សូមរំលឹកថា អង្គការ FATFដែលមានមូលដ្ឋាននៅទីក្រុងប៉ារីស ប្រទេសបារាំង កាលពីថ្ងៃទី៤ ខែមីនា ឆ្នាំ២០២២ បានសម្រេចបន្តដាក់កម្ពុជាស្ថិតក្នុង «បញ្ជីប្រផេះ» នៃក្រុមប្រទេសមានហានិភ័យខាងអំពើលាងលុយកខ្វក់ដែលពិភពលោកត្រូវបង្កើនការតាមដាន៕

## សាធារណរដ្ឋកូរ៉េ បើកទូលាយទីផ្សារការងារដល់ពលករកម្ពុជាបន្ថែមទៀតក្នុងឆ្នាំ២០២៣ ជាការសម្រួលប្រាក់ចំណូលផ្ទាល់ខ្លួន និងសេដ្ឋកិច្ច

https://cen.com.kh/archives/621565.html Posted ByPen Srey NeatFebruary 21, 2023

តាមរយៈជំនួបពិភាក្សារវាង ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈជាមួយ លោក យូ ស៊ូបុង (UH SOOBONG) ប្រធានអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ នារសៀលថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ នៅទីស្តីការក្រសួងការងារ, ភាគីកូរ៉េ សន្យានឹងផ្តល់ការងារដល់ពលករកម្ពុជាឱ្យលើសពី១ម៉ឺននាក់ក្នុងឆ្នាំ ២០២៣នេះ ដែលនេះបង្ហាញឲ្យឃើញថា និយោជិត និងពលករកម្ពុជាមានឱកាសទូលាយបន្ថែមទៀតហើយសម្រាប់ទីផ្សារការងារ ក៏ដូចជាការបន្ថែមប្រាក់ចំណូលមកផ្គត់ផ្គង់ក្រុមគ្រួសារនៅឯស្រុកកំណើត និងជាការចូលរួមសម្រួលសេដ្ឋកិច្ចនៅកម្ពុជា។

ឯកឧត្តមរដ្ឋមន្ត្រី អ៊ិត សំហេង បានថ្លែងអំណរគុណដល់ក្រសួងមុខរបរ និងការងារនៃសាធារណរដ្ឋកូរ៉េ ដែលបានយកចិត្តទុកដាក់ផ្តល់សេវាការងារជូនដល់និយោជិត-ពលករកម្ពុជាយ៉ាងល្អ។ ហើយក្នុងឆ្នាំ២០២៣នេះ តាមរយៈគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស (MTOSB) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃកម្ពុជា ធ្វើការទំនាក់ទំនងជាមួយសាធារណរដ្ឋកូរ៉េ, ធ្វើឱ្យភាគីកូរ៉េ សន្យាផ្តល់កូតាជូនពលករកម្ពុជាជាង ១ម៉ឺននាក់ទៀត ដែលនឹងធ្វើការជ្រើសរើសអ្នកមានសមត្ថភាព និងឧស្សាហ៍ព្យាយាមក្នុងការបំពេញការងារជូនដល់និយោជកកូរ៉េឱ្យកាន់តែមានផលិតភាពខ្ពស់ឆាប់ៗនេះ។

លោក យូ ស៊ូបុង ប្រធានអង្គភាពអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ បានបញ្ជាក់ជូនលោករដ្ឋមន្ត្រីថា ភាគីកូរ៉េនឹងរៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញដល់ពលករបរទេស ដែលចប់អាណត្តិការងារនៅកូរ៉េ ដោយក្នុងនោះកម្ពុជាអាចនឹងក្លាយជាប្រទេសអាទិភាពដែលទទួលបានពីគម្រោងថ្មីនេះ ដោយគម្រោងនេះមានគោលដៅផ្តល់ប្រាក់កម្ចីជួយដល់ពលករ ដើម្បីអាចបើកអាជីវកម្មមួយបានសមរម្យ និងមានប្រាក់ចំណូលបានយ៉ាងប្រសើរ។

គួរបញ្ជាក់ផងដែរថា ក្នុងឆ្នាំ២០២២កន្លងមកថ្មីៗនេះ កម្ពុជាទទួលបានចំណាត់ថ្នាក់ល្អក្នុងវិស័យបញ្ជូនពលករទៅធ្វើការនៅកូរ៉េ ហើយតាមរយៈការវាយតម្លៃពីខាងភាគីកូរ៉េ ឃើញថាពលករកម្ពុជាមានភាពស្មោះត្រង់ ឧស្សាហ៍ព្យាយាម យកចិត្តទុកដាក់នឹងការងារ ធ្វើឱ្យនិយោជកកូរ៉េស្រលាញ់ពេញចិត្តជាខ្លាំង។ ជាក់ស្តែង គេសង្កេតឃើញថា នៅពេលពលករកម្ពុជាវិលត្រឡប់ពីបម្រើការនៅសាធារណរដ្ឋកូរ៉េវិញ ពួកគាត់មានវឌ្ឍនភាព និងមានការប្រែប្រួលសេដ្ឋកិច្ចជីវភាពយ៉ាងខ្លាំង ដោយអ្នកខ្លះប្រែក្លាយជាសហគ្រិនភាព និងជាអ្នកវិនិយោគដ៏ល្បីល្បាញ៕ រក្សាសិទ្ធិដោយ ៖ ពិសិដ្ឋ CEN

## ម៉ាឡេស៊ីស្នើសុំអោយមានច្បាប់តឹងរ៉ឹងជាងនេះ ដើម្បីការពារពលរដ្ឋពីការឆបោកការងារនៅកម្ពុជា និងនៅប្រទេសផ្សេងទៀត

https://www.khmertimeskh.com/501244072// Khmer Times February 23, 2023

គិតត្រឹមថ្ងៃទី២០ ខែកុម្ភៈ ក្រសួងការបរទេសបានទទួលរបាយការណ៍ចំនួន៥៧២ករណីពាក់ព័ន្ធនឹងជនជាតិម៉ាឡេស៊ីដែលជាជនរងគ្រោះនៃ "ការឆបោកការងារ" ។ អនុរដ្ឋមន្ត្រីការបរទេស លោក Datuk Mohamad Alamin បាននិយាយថា របាយការណ៍នេះត្រូវបានទទួលតាមរយៈស្ថានទូតម៉ាឡេស៊ីនៅទីក្រុងបាងកក ភ្នំពេញ វៀងចន្ទន៍ និងយ៉ាំងហ្គោន ។ "ក្នុងចំណោមចំនួននេះ ជនរងគ្រោះចំនួន៤០៣ នាក់ត្រូវបានជួយសង្គ្រោះដោយជោគជ័យ ជាមួយនឹងមនុស្ស៣៨២ នាក់ត្រូវបានត្រឡប់ទៅផ្ទះវិញ រួមទាំងមនុស្ស៥ នាក់ដែលបានត្រលប់មកវិញកាលពីថ្ងៃអាទិត្យមុន។ លោកបានបន្តថា៖ «មនុស្ស ២១ នាក់ដែលនៅសេសសល់កំពុងត្រូវបានឃុំខ្លួននៅមន្ទីរឃុំឃាំងរង់ចាំដំណើរការដូចគ្នា ខណៈ ១៦៩ នាក់ផ្សេងទៀតកំពុងត្រូវបានគេតាមដាន»។

នាយករដ្ឋមន្ត្រី Anwar Ibrahim បាននិយាយថា រដ្ឋាភិបាលនឹងពិចារណាលើការរឹតបន្តឹងច្បាប់ដើម្បីការពារប្រជាជនម៉ាឡេស៊ីពីការចាញ់បោកដោយសន្យាផ្តល់ការងារក្លែងក្លាយនៅបរទេស។ លោកបានបន្តថា មានមនុស្សជាច្រើនដែលបានក្លាយជាជនរងគ្រោះ ខណៈក្រុមជនពាលនានាកំពុងលាក់ខ្លួននៅបរទេស រួមមាននៅកម្ពុជា និងមីយ៉ាន់ម៉ា។ "យើងបានប្រកាន់ជំហរតឹងតែង។ យើងក៏សូមដាស់តឿនប្រជាជនម៉ាឡេស៊ីឱ្យមានការប្រុងប្រយ័ត្នខ្ពស់ ដើម្បីកុំអោយចាញ់បោកគេ។ លោកបានប្រាប់អ្នកសារព័ត៌មានម៉ាឡេស៊ីបន្ទាប់ពីបញ្ចប់ដំណើរទស្សនកិច្ចការងាររយៈពេលពីរថ្ងៃរបស់លោកនៅប្រទេសថៃកាលពីពេលថ្មីៗនេះថា "ក្រសួងទំនាក់ទំនង និងឌីជីថល និងនគរបាលកំពុងចាត់វិធានការចាំបាច់ រួមទាំងការរឹតបន្តឹងច្បាប់" ។

ភាគច្រើននៃក្រុមជនពាលទាំងនេះបានទាក់ទាញជនរងគ្រោះដោយប្រើការផ្សាយពាណិជ្ជកម្មការងារនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម រួមទាំង Facebook ដោយសន្យាផ្តល់ការងារជាអ្នកបម្រើសេវាអតិថិជននៅបរទេសជាមួយនឹងប្រាក់ខែច្រើន។ នៅពេលមកដល់ លិខិតឆ្លងដែន និងឯកសារធ្វើដំណើររបស់ពួកគេត្រូវបានបំផ្លាញ ហើយជនរងគ្រោះនឹងត្រូវបង្ខំឱ្យធ្វើការជាអ្នកបោកប្រាស់ ឬនៅក្នុងប្រតិបត្តិការល្បែងអនឡាញ។ លោក Mohamad បាននិយាយថា សកម្មភាពដែលធ្វើឡើងដោយស្ថានទូតក្នុងប្រទេសថៃ កម្ពុជា ឡាវ និងមីយ៉ាន់ម៉ា រួមមានការជួបជាមួយអាជ្ញាធរនៃប្រទេសដែលពាក់ព័ន្ធដើម្បីកំណត់ទីតាំង និងជួយសង្គ្រោះជនរងគ្រោះម៉ាឡេស៊ី ក៏ដូចជាការផ្តល់ជំនួយកុងស៊ុល បន្ទាប់ពីពួកគេត្រូវបានជួយសង្គ្រោះ ដើម្បីឱ្យពួកគេអាចត្រឡប់ទៅផ្ទះវិញ។

ឆ្លើយតបទៅនឹងសំណួរបន្ថែមរបស់ Aminolhuda លើការចំណាយដែលក្រសួងការបរទេសចេញដើម្បីនាំយកជនរងគ្រោះ មកផ្ទះវិញ ហើយថាតើក្រសួងពាក់ព័ន្ធក្នុងការបង់ប្រាក់លោះឬអត់នោះ លោកបាននិយាយថា វាជាបន្ទុករបស់គ្រួសារជនរងគ្រោះ និងសាច់ញាតិ។ "រាល់ការចំណាយលើការធ្វើមាតុភូមិនិវត្តន៍ គឺពិតជាមិនស្ថិតនៅក្រោមការទទួលខុសត្រូវរបស់ក្រសួងនោះនេះជាទំនួលខុសត្រូវទាំងស្រុងរបស់គ្រួសារ និងញាតិមិត្ត។ លោកបន្តថា ៖ «ទីពីរ បញ្ហាសងប្រាក់វិញមិនស្ថិតនៅក្រោមក្រសួង ឬរដ្ឋាភិបាលទេ។ វាក៏ជាការទទួលខុសត្រូវរបស់ក្រុមគ្រួសារ និងញាតិសន្តានរបស់ជនរងគ្រោះផងដែរ»។ *Bernama*

## ផ្តន្ទាទោសស្រី-ប្រុស ២នាក់ ជាប់គុក ក្នុងម្នាក់ៗ ០៧ ឆ្នាំ ជាប់ពាក់ព័ន្ធនឹងការបើកកន្លែងម៉ាស្សាបង្កប់សេវាផ្លូវភេទ !!

https://cen.com.kh/archives/622764.html Posted ByPen Srey NeatFebruary 23, 2023

ភ្នំពេញ: តុលាការរាជធានីភ្នំពេញ កាលពីព្រឹកថ្ងៃទី ២២ខែ កុម្ភៈ ឆ្នាំ ២០២៣ បានប្រកាសសាលដីកា ផ្តន្ទាទោស ស្ត្រីនិងបុរសជាប់ចោទ ចំនួន២នាក់ ដែលត្រូវជាគូកននឹងគ្នា ដាក់ពន្ធនាគារកំណត់ ០៧ ឆ្នាំ ក្នុងម្នាក់ៗ ជាប់ពាក់ព័ន្ធនឹងការបើកកន្លែងម៉ាស្សាបង្កប់សេវាផ្លូវភេទ ប្រព្រឹត្តនៅចំណុចហាងម៉ាស្សាកោសជប់មួយកន្លែង ដែលទីតាំង ស្ថិតនៅ សង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ កាលពី ឆ្នាំ ២០២២។

លោកវ៉ែ្ន ស៊ីថា ជាប្រធានចៅក្រមប្រឹក្សាជំនុំជម្រះ នៃ សាលាដំបូងរាជធានីភ្នំពេញ បានថ្លែងឲ្យដឹងថា ជនជាប់ចោទ មានឈ្មោះ នន់ ស្រីលក្ខណ៍ ហៅ វីន ភេទស្រី អាយុ ៤៣ ឆ្នាំ និង ឈ្មោះ ដែន សោភ័ណ្ឌ ភេទប្រុស អាយុ ៤១ ឆ្នាំ។ អ្នកមានប្រកបរបរម៉ាស្សា និងជាថៅកែហាងម៉ាស្សា។ ពួកគេទាំង០២នាក់ ត្រូវបានតំណាងអយ្យការចោទប្រកាន់ពីបទ: សញ្ញារកម្មមានស្ថានទម្ងន់ទោសទក់ទងនឹងជនរងគ្រោះ តាមមាត្រា ២៨ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើអាជីវកម្មផ្លូវភេទ។ ពួកគេ ត្រូវបានចាប់ឃាត់ខ្លួន កាលពី ថ្ងៃទី ១១ ខែ តុលា ឆ្នាំ២០២២ បន្ទាប់ពី សមត្ថកិច្ចនគរបាលប្រឆាំងការជួញដូរមនុស្ស បានចុះបង្ក្រាប ទីតាំងហាងម៉ាស្សា របស់ពួកគេ ដែលមានទីតាំង នៅក្នុងសង្កាត់ក្រាំងធ្នង់ ខណ្ឌសែនសុខ រាជធានីភ្នំពេញ។

ក្រោយឃាត់ខ្លួន, សមត្ថកិច្ចនគរបាល ឃាត់ខ្លួនស្ត្រីម៉ាស្សា ចំនួន ០៩ នាក់ ក្នុងនោះមាន២នាក់ ជាអនីតិជន។ សមត្ថកិច្ចនគរបាល ក៏បានដកហូតវត្ថុតាងរួមមាន៖ ស្រោមអនាម័យ ដែលប្រើរួច ក្រដាសសើមសម្រាប់ជូតទឹកកាមចំនួន និង ស្រោមអនាម័យ ដែលមិនទាន់ប្រើមួយចំនួនទៀត នៅក្នុងបន្ទប់ម៉ាស្សា៕ រក្សាសិទ្ធិដោយ : ចន្ទា ភា

# ថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ២០២៣

## លោក ស ខេង
## ជំរុញឱ្យអាជ្ញាធរពាក់ព័ន្ធទប់ស្កាត់ឧក្រិដ្ឋកម្មឆ្លងដែន និងបង្ក្រាបការជួញដូរមនុស្ស

https://www.postkhmer.com/national/2023-02-23-1801-247300.html Publication date 23 February 2023 | 18:01 ICT

**ភ្នំពេញៈ** លោកឧបនាយករដ្ឋមន្ត្រី ស ខេង រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានជំរុញដល់កម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធ រួមគ្នាទប់ស្កាត់អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ សកម្មភាពជួញដូរមនុស្សគ្រប់ទម្រង់ និងត្រូវទប់ស្កាត់ការលបលួចចេញចូលប្រទេសតាមច្រករបៀងខុសច្បាប់នានា និងតាមច្រកសមុទ្រជាដើម។ ការជំរុញនេះធ្វើនេះឡើងក្នុងពេលលោកធ្វើជាអធិបតីបូកសរុបលទ្ធផលនៃអង្គសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ២០២២ និងផ្តល់អនុសាសន៍លើកទិសដៅការងារឆ្នាំ២០២៣របស់ក្រសួងមហាផ្ទៃ ដែលអង្គសន្និបាតនេះ បានពិភាក្សាអំពីសមិទ្ធផល បញ្ហាប្រឈម ជាមួយនឹងការផ្តួចផ្តើមដំណោះស្រាយនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ ២០២៣ ។ ពិធីនេះ មានការចូលរួមពីមន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងនោះក្រុមប្រឹក្សា អភិបាលរាជធានី-ខេត្ត ស្នងការនគរបាលរាជធានី-ខេត្ត និងមន្ត្រីពាក់ព័ន្ធសរុបប្រមាណ ៧៥០ នាក់។

នាពិធីនោះ លោក ស ខេង បានណែនាំដល់កងកម្លាំងនគរបាលជាតិ មន្ត្រីរដ្ឋបាលស៊ីវិល មន្ត្រីពន្ធនាគារនៃក្រសួងមហាផ្ទៃ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីលើកកម្ពស់ស្មារតីទទួលខុសត្រូវក្នុងការអនុវត្តតួនាទីភារកិច្ច ដូចជា ត្រូវបន្តខិតខំរួមគ្នាថែរក្សាពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ និងការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដីដើម្បីបន្តអភិវឌ្ឍប្រទេសជាតិឱ្យមានការរីកចម្រើនលើគ្រប់វិស័យជាបន្តទៀត។ លោកបញ្ជាក់ថា៖«ពិសេសត្រូវបង្កើនការថែរក្សាពង្រឹងសន្តិសុខជាតិ ដោយត្រូវបង្កើនកិច្ចសហការជាមួយកម្លាំងអនុវត្តច្បាប់ ទាំងក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ ដើរទន្ទឹមនឹងការពង្រឹងសមត្ថភាពជំនាញរបស់កម្លាំងអនុវត្តច្បាប់និងលើកកម្ពស់កិច្ចសហការឱ្យបានល្អជាមួយអាជ្ញាធរកងកម្លាំងមានសមត្ថកិច្ចពាក់ព័ន្ធទាំងអស់ដើម្បីរួមគ្នាទប់ស្កាត់អំពើភេរវកម្ម ឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ បទល្មើសបច្ចេកវិទ្យា សកម្មភាពជួញដូរមនុស្សគ្រប់ទម្រង់និងបទល្មើសនានាឆ្លងកាត់ព្រំដែនគ្រប់ប្រភេទ»។

លោកស ខេង បន្ថែមថា មួយទៀតនោះសមត្ថកិច្ចពាក់ព័ន្ធត្រូវបង្កើនការគ្រប់គ្រងការចេញចូលប្រទេស គ្រប់គ្រងមុខសញ្ញាតាមវិធានការជំនាញ និងគ្រប់គ្រងការស្នាក់នៅរបស់ជនបរទេស និងជនអន្តោប្រវេសន៍ឱ្យបានម៉ឺងម៉ាត់ព្រមទាំងខិតខំទប់ស្កាត់ការលបលួចចេញចូលប្រទេសតាមច្រករបៀងខុសច្បាប់នានានិងតាមច្រកសមុទ្រ។ លោកថា៖«ព្រមទាំងបន្តអនុវត្តឱ្យបានជាប់ជាប្រចាំនូវយុទ្ធនាការប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សគ្រប់ទម្រង់ ប្រតិបត្តិការបង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ការចុះធ្វើអធិការកិច្ចហត្ថពលកម្មបរទេស និងបន្តខិតខំស្រាវជ្រាវករណីលាងសម្អាតប្រាក់ ដើម្បីពង្រឹងសន្តិសុខជាតិ និងសណ្តាប់ធ្នាប់សាធារណៈក្នុងសង្គម»។

នាយកទទួលបន្ទុកកិច្ចការទូទៅនៃអង្គការសិទ្ធិមនុស្សលីកាដូលោក អំ សំអាត គាំទ្រចំពោះការជំរុញរបស់ថ្នាក់ដឹកនាំក្រសួងមហាផ្ទៃដើម្បីបង្កើនវិធានការក្នុងការទប់ស្កាត់ ការបង្ក្រាបការជួញដូរមនុស្ស បញ្ហាគ្រឿងញៀន និងបញ្ហាលាងលុយកង្វក់ជាដើមនៅកម្ពុជា ដើម្បីធ្វើម៉េចឱ្យកម្ពុជាមានស្ថានភាពល្អប្រសើរ ហើយទទួលស្គាល់ពីសហគមន៍អន្តរជាតិ។ លោកបានថ្លែងថា៖«ដូច្នេះកម្ពុជាត្រូវតែមានវិធានការចាំបាច់ ទី១ត្រូវពង្រឹងកិច្ចសហការរវាងមន្ត្រីទាំងអស់នៅក្នុងប្រទេសឱ្យមានកិច្ចសហការគ្នាល្អ ទី២ពង្រឹងបន្ថែមនូវជំនាញរបស់មន្ត្រីអនុវត្តទាំងអស់ ទី៣ មន្ត្រីទាំងអស់ត្រូវនៅឱ្យឆ្ងាយពីការជួញដូរមនុស្ស គ្រឿងញៀន និងបទល្មើសផ្សេងៗ ហើយទី៤ត្រូវធ្វើកិច្ចសហការជាមួយបណ្តាប្រទេសជិតខាងក្នុងតំបន់ និងអន្តរជាតិ»។

ពាក់ព័ន្ធអង្គសន្និបាតវិញលោក ស ខេង ថ្លែងថា ក្នុងនាមថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ និងរូបលោកសូមវាយតម្លៃខ្ពស់ចំពោះមន្ត្រីពាក់ព័ន្ធទាំងអស់ដែលបានចូលរួមអនុវត្តយ៉ាងសកម្មនូវរបៀបវារៈ និងកម្មវិធីនានានៃសន្និបាតប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃដែលបានផ្តល់ធាតុចូលដ៏មានតម្លៃ ដើម្បីចូលរួមជំរុញនិងលើកកម្ពស់ប្រសិទ្ធភាពការងារ នៅតាមអគ្គនាយកដ្ឋាន អង្គភាពនានាចំណុះក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ៕ **សុខ រក្សា**

## ការអនុវត្តគោលនយោបាយភូមិ-ឃុំ-សង្កាត់ មានសុវត្ថិភាពក្នុងឆ្នាំ ២០២២ ធ្វើឱ្យបទល្មើសថយចុះ ៩%

https://www.postkhmer.com/national/2023-02-23-0933-247275.html ឡុង គីមម៉ារីតា | Publication date 23 February 2023 | 09:33 ICT

**ភ្នំពេញៈ** លោក ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានថ្លែងថា នៅឆ្នាំ ២០២២ ការអនុវត្តនូវគោលនយោបាយភូមិឃុំ សង្កាត់ មានសុវត្ថិភាពធ្វើឱ្យបទល្មើសមានការថយចុះ ៩ ភាគរយ ខណៈលទ្ធផលបង្ក្រាបបទល្មើសនៅទូទាំងប្រទេស មានកម្រិតខ្ពស់រហូតដល់ ៩២ ភាគរយ។ លោកបានថ្លែងបែបនេះ នៅថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ ២០២៣ ក្នុងពិធីបើកសន្និបាតត្រួតពិនិត្យលទ្ធផលការងារឆ្នាំ ២០២២ និងលើកទិសដៅការងារឆ្នាំ ២០២៣ របស់ក្រសួងមហាផ្ទៃ នៅសណ្ឋាគារសុខាភ្នំពេញដែលមានមន្ត្រីក្រោមឱវាទគ្រប់ផ្នែកទូទាំងប្រទេសជាង ៧០០ នាក់ចូលរួម។ ក្នុងឱកាសនោះ លោក ស ខេង បានថ្លែងថា៖ «កម្លាំងនគរបាលជាតិ និងរដ្ឋបាលគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ បានបន្តបង្កើនកិច្ចសហការក្នុងការថែរក្សាសណ្តាប់ធ្នាប់ និងសុវត្ថិភាពក្នុងសង្គម តាមរយៈការលើកកម្ពស់វិធានការជំនាញ ដើរទន្ទឹមនឹងការខិតខំជំរុញឱ្យមានការចូលរួមពីសំណាក់ប្រជាពលរដ្ឋនៅក្នុងការអនុវត្តគោលនយោបាយ ភូមិឃុំសង្កាត់ មានសុវត្ថិភាព ដែលធ្វើឱ្យបទល្មើសមានការថយចុះ ៩ ភាគរយ ជាមួយនឹងលទ្ធផលបង្ក្រាបបទល្មើសមានកម្រិតខ្ពស់ រហូតដល់ ៩២ ភាគរយ»។

លោកបានបញ្ជាក់ថា ក្នុងឆ្នាំ ២០២២ រាជរដ្ឋាភិបាលបានដាក់ចេញ និងអនុវត្តនូវយុទ្ធនាការប្រតិបត្តិការព្រមៗគ្នា ដើម្បីបង្កើនការប្រយុទ្ធប្រឆាំងគ្រប់ទម្រង់ នៃអំពើជួញដូរមនុស្ស ជួញដូរពលកម្ម និងអាជីវកម្មផ្លូវភេទ ប្រតិបត្តិការ បង្ក្រាបល្បែងស៊ីសងខុសច្បាប់គ្រប់ប្រភេទ ប្រតិបត្តិការចុះធ្វើអធិការកិច្ច ហត្ថពលកម្មបរទេស ប្រតិបត្តិការប្រយុទ្ធប្រឆាំងសកម្មភាពលាងសម្អាតប្រាក់ ការបន្តអនុវត្តយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ ក្រុមក្មេងទំនើងតាមសហគមន៍ រួមទាំងបទល្មើសផ្សេងៗទៀតក៏ត្រូវបានចាត់តាំង អនុវត្តយ៉ាងសកម្មផុលផុសសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ផងដែរ។ បន្ថែមពីនេះ លោក ស ខេង ជំរុញឱ្យមន្ត្រីក្រោមឱវាទគ្រប់ផ្នែក បន្តពង្រឹងសកម្មភាពរៀងៗខ្លួន ដើម្បីកាត់បន្ថយផលប៉ះពាល់មកលើសុខភាពសាធារណៈ ជាពិសេសចូលរួមបម្រើផលប្រយោជន៍ពលរដ្ឋ បើទោះជាការងារដែលសម្រេចបានមានលទ្ធផលល្អយ៉ាងណាក៏ដោយ។

លោកបញ្ជាក់ថា៖ «បញ្ហាប្រឈមមកលើសភាពការណ៍ នយោបាយ សេដ្ឋកិច្ច សង្គម និងសន្តិសុខជាសកល បង្កឱ្យមានការព្រួយបារម្ភអំពីការកើនឡើងនូវអំពើភេរវកម្ម និងឧក្រិដ្ឋកម្មឆ្លងដែនគ្រប់ប្រភេទ ការរីករាលដាលនៃបទល្មើសបច្ចេកវិទ្យា គួបផ្សំនឹងការបន្តកើតឡើងនូវបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ជាពិសេស បទល្មើសដែលធ្វើឱ្យប៉ះពាល់ដល់ចិត្តសាស្ត្រសង្គម បទល្មើសគ្រឿងញៀន អំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទ គ្រោះថ្នាក់ចរាចរណ៍»។ លោកបញ្ជាក់បន្តថា៖ «ការងារនេះ ទាមទារឱ្យអាជ្ញាធរ និងកងកម្លាំងមានសមត្ថកិច្ចនានា ត្រូវបង្កើនការតាមដានការវិវឌ្ឍប្រែប្រួលនៃសភាពការណ៍ តំបន់ និងអន្តរជាតិ ព្រមជាមួយការពង្រឹងការគ្រប់គ្រងសភាពការណ៍នៅក្នុងផ្ទៃក្នុងប្រទេស សំដៅដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ និងវិធានការនានាប្រកបដោយប្រសិទ្ធភាពខ្ពស់ក្នុងការរក្សាសន្តិសុខជាតិ សណ្តាប់ធ្នាប់ សាធារណៈ សុវត្ថិភាពសង្គម ឱ្យបានល្អប្រសើរ និងការបង្កបរិយាកាសអំណោយផលដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាបន្តទៀត»។

តាមការប្រកាសរបស់លោក ស ខេង គិតត្រឹមឆ្នាំ ២០២២ តាមរយៈកំណែទម្រង់របស់រដ្ឋាភិបាល មានមុខងារជិត ៦០ ត្រូវបានផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងមុខងារផ្តល់សេវារដ្ឋបាលប្រមាណជាង ៨០០ ប្រភេទ ត្រូវបានប្រគល់ និងធ្វើប្រតិភូកម្មជូនរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋតាមយន្តការច្រកចេញចូលតែ ១ ។ ក្នុងរយៈពេល ៥ ឆ្នាំ (២០១៨-២០២២) ចុងក្រោយនេះ ការផ្ទេរថវិកាជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ មានកំណើនប្រមាណ ២,៧ ដង គឺកើនឡើងពី ៤១៦ លានដុល្លារក្នុងឆ្នាំ ២០១៨ ដល់ ១ ១១៦ លានដុល្លារក្នុងឆ្នាំ ២០២២។

លោក ប៉ោ ភក្តិ អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ ដែលបានធ្វើសេចក្តីរាយការណ៍សង្ខេបស្តីពីលទ្ធផលការងារឆ្នាំ ២០២២ បានឱ្យដឹងថា នៅក្នុងឆ្នាំ ២០២២ កន្លងទៅមានបទល្មើសព្រហ្មទណ្ឌជារួម បានកើតឡើងចំនួន ២ ៧៧០ លើក ថយចុះចំនួន ២៨៥ លើក ស្មើ ៩% ធៀបនឹងឆ្នាំ ២០២១។ បើតាមរបាយការណ៍ក្នុងសន្និបាតក្រសួងមហាផ្ទៃ ក្នុងចំណោមបទល្មើសដែលបានកើតឡើងនោះ មានបទឧក្រិដ្ឋ ៦០៨ កើន ១៩ លើកស្មើ ៣% និងបទមជ្ឈិម ២ ១៦២ លើកថយ ៣០៤ លើកស្មើ ១២%។ លោកបញ្ជាក់ថា៖ «នាអំឡុងពេល ១ ឆ្នាំនេះ បើទោះបីស្ថានការណ៍សន្តិសុខក្នុងតំបន់ និងសកលលោក បន្តមានការវិវឌ្ឍប្រែប្រួលពិបាកប៉ាន់ស្មាន និងមានហានិភ័យខ្ពស់យ៉ាងណាក្តី ក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល បានពុះពារឆ្លងកាត់ដោយជោគជ័យនូវវិបត្តិ និងបញ្ហាប្រឈមទាំងនោះ ដោយបាននាំមកនូវសមិទ្ធផលធំធេងជូនប្រជាជាតិខ្មែរបន្ថែមទៀតផងដែរ»។

តាមរបាយការណ៍របស់លោក ប៉ោ ភក្តិ បានឱ្យដឹងថា ក្នុងឆ្នាំ ២០២២ អង្គភាពច្រកចេញចូលតែ ១ នៃរាជធានីខេត្ត បានផ្តល់សេវារដ្ឋបាលបានចំនួន ៦៩៥ ២០៥ សេវា និងទទួលបានចំណូលសរុបចំនួន ២៨ ២១២ ៤៩២ ដុល្លារ។ ចំណែកការិយាល័យច្រកចេញចូលតែ១ក្រុង ស្រុក ខណ្ឌ ផ្តល់សេវារដ្ឋបាលបានចំនួន ១ ៥៦១ ៧០៤ សេវា និងទទួលបានចំណូលសរុបចំនួន សមមូល ២ ៧៥២ ២៦៦ ដុល្លារ។ លោកបានបញ្ជាក់ថា៖ «ការិយាល័យប្រជាពលរដ្ឋនៅរាជធានីខេត្ត ទទួលបានបណ្តឹង និងព័ត៌មានផ្សេងៗចំនួន ១ ២៦៧ ករណី ក្នុងនោះ បណ្តឹងក្នុងសមត្ថកិច្ច ៧៦៧ ករណី (បញ្ចប់ការដោះស្រាយបាន ៧១២ ករណី) បណ្តឹងក្រៅសមត្ថកិច្ច ២០២ ករណី និងព័ត៌មានផ្សេងៗ ២៩៨ ករណី»៕

## មកដល់ពេលនេះ មានពលករកម្ពុជា ធ្វើការនៅក្រៅប្រទេស សរុបជាង ១លាន ៣២ម៉ឺននាក់ នៅថៃច្រើនជាងគេ

https://kohsantepheapdaily.com.kh/article/1690483.html?utm_source=telegram&utm_medium=click&utm_campaign=channeltelgram ភ្នំពេញ២៣ ខែ កុម្ភៈ ឆ្នាំ ២០២៣ ម៉ោង ២០:០៤

ភ្នំពេញ៖ រហូតមកដល់បច្ចុប្បន្ន មានពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេស សរុបមានចំនួន ១ ៣២១ ៥០៦នាក់។ នេះបើតាមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

របាយការណ៍ ដែលបានប្រកាសក្នុងសន្និបាតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បង្ហាញថា រហូតមកដល់បច្ចុប្បន្ន បានផ្តល់ឱកាសការងារជូនពលករកម្ពុជា ដែលកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេស សរុបមានចំនួន ១ ៣២១ ៥០៦នាក់។ ក្នុងនោះ ប្រទេសថៃ មានចំនួន ១ ២៣១ ៥០៨នាក់។ កូរ៉េ ៤៩ ៧៣៨នាក់។ ជប៉ុន ១៦ ៥៦២នាក់។ ម៉ាឡេស៊ី ២២ ៦២១នាក់។ សឹង្ហបុរី ៨៥១នាក់។ តំបន់រដ្ឋបាលពិសេសហុងកុង ២១៥ នាក់ និងអារ៉ាប់ប៊ីសាអូឌីត ១១នាក់។ ក្រសួងការងារ ក៏បានប្រកាសថា ជាមធ្យម ពលករកម្ពុជា ដែលធ្វើការនៅ

ក្រៅប្រទេស បានបញ្ជូនប្រាក់បញ្ញើមកក្នុងប្រទេសវិញ ក្នុងមួយឆ្នាំៗ សរុបប្រមាណ ២,៧ប៊ីលានដុល្លារអាម៉េរិក ( ២៧០០លានដុល្លារអាម៉េរិក )៕

## ឃាត់ខ្លួននាយករងវិទ្យាល័យម្នាក់ ក្រោយពីដាក់ថ្នាំចាប់រំលោភកូន សិស្សខ្លួនបាន សម្រេចច្រើនដងនិងថតរូបវីដេអូកំពុងទុកគំរាម

https://www.kampucheathmey.com/security/469598 ថ្ងៃព្រហស្បតិ៍ ២៣ កុម្ភៈ ២០២៣ដោយ Kang Tola

កំពង់ធ្នាំង ៖ លោកនាយករងវិទ្យាល័យម្នាក់នៅក្នុងខេត្តកំពង់ឆ្នាំង ត្រូវបានសមត្ថកិច្ចនៃស្នងការដ្ឋាននគរបាលខេត្តកំពង់ឆ្នាំងចាប់ខ្លួនកសាងសំណុំរឿងបញ្ជូនមកអយ្យការ នៃសាលាដំបូងខេត្តកំពង់ឆ្នាំងនៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ ដោយជាប់ចោទពីបទចាប់រំលោភសេពសន្ថវៈ និង ផលិត ចែកចាយរូបភាពអាសអាភាសលើកុមារីជាសិស្សសាលារបស់ខ្លួន និងករណីហិង្សាដោយ ចេតនា។

សមត្ថកិច្ចជំនាញនៃស្នងការនគរបាលខេត្តកំពង់ឆ្នាំងបានឲ្យដឹងថា កាលពីថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ច បានធ្វើការឃាត់ខ្លួន លោក ង៉ែត សុខខេង អាយុ ៤១ឆ្នាំ ជនជាតិខ្មែរ សញ្ជាតិខ្មែរ មុខរបរ នាយករងសាលាផ្នែកវិន័យ និងបរិស្ថាន នៅវិទ្យាល័យមួយ(ក្នុងស្រុកកំពង់ ត្រឡាច) ពីករណី រំលោភសេពសន្ថវៈ និង ផលិតចែកចាយរូបភាពអាសអាភាសលើកុមារីជាសិស្សវិទ្យាល័យ និងករណី ហិង្សាដោយចេតនា។ ករណីចាប់ខ្លួនជនសង្ស័យខាងលើនេះ ធ្វើឡើងតាមបញ្ជា លោក ស្នងការនគរបាលខេត្តកំពង់ឆ្នាំង ដោយមានការសម្របសម្រួលពីស្ថាប័នអយ្យការខេត្តកំពង់ឆ្នាំង។

សមត្ថកិច្ចបានឲ្យដឹងទៀតថា យោងតាមពាក្យបណ្តឹង របស់អាណា ព្យាបាលរបស់កុមារី ជាសិស្សវិទ្យា ល័យអាយុ ១៥ ឆ្នាំ ជាជនរងគ្រោះនៃអំពើខាងលើ បានរៀបរាប់ទាំងក្តុកក្តួលថា ជនសង្ស័យឈ្មោះ ង៉ែត សុខខេង នាយករងសាលាផ្នែកវិន័យ និងបរិស្ថានបានលួងលោមកុមារីជាកូនគាត់ថា ទៅរៀនបើក រថយន្តជាមួយលោកគ្រូឈ្មោះ ង៉ែត សុខខេង រួចបែរជាលួចដាក់ថ្នាំចូល ក្នុងទឹកឱ្យកូនគាត់ផឹក លុះពេលកូនគាត់សន្លប់បាត់ បាននាំកូនគាត់ទៅរំលោភរហូតបានសម្រេច ជាច្រើនដង និងបានថតរូប និងវីដេអូកំពុងចាប់រំ លោភជនរងគ្រោះនោះ ដើម្បីទុកគំរាមកុមារីរងគ្រោះសម្រាប់បំពេញតណ្ហារបស់ខ្លួនលើកក្រោយទៀត។

ករណីខាងលើនេះ គឺជាសារដាស់តឿនសម្រាប់ជនល្មោភតណ្ហាទាំងឡាយគួរតែជៀសវាងឲ្យឆ្ងាយកុំឱ្យមានរឿងអាស្រូវនាំឲ្យអាប់អោនកិត្តិយស និង អាប់អោនដល់មន្ត្រីក្នុងអង្គភាព ក្នុងស្រុកក្នុងខេត្តដែលគេជាមនុស្សល្អ។ ទន្ទឹមគ្នានេះដែរ អាណាព្យាបាលនិងមាតាបិតាទាំងឡាយរបស់សិស្សក៏គួរតែប្រុងប្រយ័ត្នចំពោះកូនជានារីភេទផងដែរ ដោយកុំបណ្តែតបណ្តោយដូចករណីខាងលើនេះ៕ *ដោយ ៖ ឈៀងថារិទ្ធ*

## សមត្ថកិច្ចកម្ពុជា

## បន្តទទួលបានបណ្តឹង ៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិ ៣២នាក់

https://freshnewsasia.com/index.php/en/localnews/279253-2023-02-23-11-55-32.html 2023-02-23 06:55pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២១ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០៣ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិបរទេសចំនួន ៣២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

១៖ សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧៥៩ករណី មានមនុស្ស ១,៨៩០នាក់

២៖ បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧២៩សំណើ និងបិទសំណុំរឿង ២៥០សំណើ (រកឃើញមនុស្ស ១,១០៥នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

៣៖ កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ៣០ករណី៕

## អ្នកជំនាញ បារម្ភករណី

## កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ខណៈសន្ទុះកុមារតូចៗ ប្រើអ៊ីនធឺណេតកើនឡើង

https://dap-news.com/national/2023/02/24/314777/ ByPH104Posted on February 24, 2023

**ភ្នំពេញ ៖ បច្ចុប្បន្ននេះ ដោយសារតែការរីកចម្រើនខ្លាំង នៃបច្ចេកវិទ្យា បានធ្វើឲ្យអ្នកប្រើប្រាស់អ៊ីនធឺណេតកើនឡើងយ៉ាងលឿនគួរឲ្យកត់សម្គាល់ ដោយក្នុងចំណោមអ្នកប្រើប្រាស់៣នាក់ មានម្នាក់ទៅហើយ ជាកុមារបានប្រើប្រាស់ប្រព័ន្ធទំនើបមួយ ដែលពិតជាផ្តល់ហានិភ័យ និងបង្កគ្រោះថ្នាក់យ៉ាងខ្លាំង ដល់កុមារ ដោយខ្លះ អាចនឹងក្លាយទៅជាជនល្មើស ឬអ្នកប្រព្រឹត្តបទល្មើសថែមទៀតផង។**

នេះបើតាមលោក រឿង សេរីតារា អនុប្រធានមន្ទីរសង្គមកិច្ច អតីតយុទ្ធជននិង យុវនីតិសម្បទា រាជធានីភ្នំពេញ ក្នុងបទបង្ហាញស្តីពីការពង្រឹង យន្តការរាយការណ៍ និងឆ្លើយតបករណី នៃការកេងប្រវ័ញ្ចផ្លូវភេទ លើកុមារតាមប្រព័ន្ធអនឡាញ ក្នុងកិច្ចប្រជុំប្រចាំឆ្នាំឆ្លុះបញ្ចាំង លទ្ធផលអនុវត្តការងារឆ្នាំ២០២២ របស់គណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ នៃក្រុមប្រឹក្សារាជធានីភ្នំពេញ អាណត្តិទី៣ នៅថ្ងៃ២៤ កុម្ភៈ។ ឆ្នាំ២០២៣ នេះ នៅសាលារាជធានីភ្នំពេញ ក្រោមអធិបតីភាពលោក ម៉ប់ សារិន ប្រធានក្រុមប្រឹក្សារាជធានីភ្នំពេញ និងលោកស្រី កែវ សុខពិសី អភិបាលរងរាជធានីភ្នំពេញ តំណាងឲ្យលោក ឃួង ស្រេង អភិបាលរាជធានីភ្នំពេញ។

ក្នុងបទបង្ហាញនេះ បានលើកឡើងថា ទន្ទឹមនឹងការរីកចម្រើន នៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ននេះ អ្នកប្រើប្រាស់អ៊ីនធឺណេត ជាកុមារ កំពុងតែមានការកើនឡើងយ៉ាងលឿនគួរឲ្យកត់សម្គាល់ ក្នុងចំណោមអ្នកប្រើប្រាស់៣នាក់ មាន១នាក់គឺជាកុមារ។ ប្រព័ន្ធអ៊ីនធឺណេត មិនត្រឹមតែជាទីកន្លែងដែលកុមារ អាចស្វែងរកព័ត៌មាន រឿងរ៉ាវរៀនសូត្រ ចំណេះដឹង លេងកម្សាន្ត និងភ្ជាប់ទំនាក់ទំនងជាមួយមិត្តភ័ក្ត និងមនុស្សដទៃទៀតប៉ុណ្ណោះទេ ប៉ុន្តែជាទីកន្លែងផ្តល់នូវហានិភ័យ និងបង្កគ្រោះថ្នាក់យ៉ាងខ្លាំង ដល់កុមារ និងអ្នកប្រើប្រាស់ជាច្រើនផងដែរ ។ នេះដោយសារតែពួកគេមិនទាន់បានយល់ដឹងពីគុណសម្បត្តិ និងគុណវិបត្តិ ឬមិនទាន់ចេះប្រើប្រាស់បានត្រឹមត្រូវ។ កុមារខ្លះ ខ

ណៈគ្មានឪពុកម្តាយ អាណាព្យាបាល ឬ អ្នកថែរក្សានៅតាមមើល ឬគ្មានមនុស្សពេញវ័យនៅក្បែរ កុមារហ៊ាន ប្រព្រឹត្តដោយប្រថុយប្រថាន តាមអនឡាញ។

ឧទាហរណ៍កុមារហ៊ានផ្ញើសាររូបភាពមាតិកាពាក់ព័ន្ធនឹងផ្លូវភេទ វិដេអូរួមភេទទៅឲ្យមិត្តភក្តិ ឬនរណាម្នាក់។ ពេលខ្លះរូបភាព ឬវិដេអូទាំងនោះ ត្រូវបានគេចែកចាយបន្តទៀតច្រើនដង ដែលត្រូវបានគេប្រើប្រាស់ ឬបកស្រាយខុសពីគោលបំណងដើម ជាហេតុបង្កនូវការលំបាកដល់កុមារ។ ពេលខ្លះកុមារអាចក្លាយទៅជាជនល្មើស ឬអ្នកប្រព្រឹត្តបទល្មើសដែលអាចប្រឈមមុខចំពោះមុខច្បាប់ទៀតផង។ ក្នុងបទបង្ហាញនោះ ក៏បានពិភាក្សាស្វែងយល់អំពី ឥរិយាបថកុមារនៅលើប្រព័ន្ធអ៊ីនធឺណេត យល់ដឹងពីហានិភ័យនៃការរំលោភបំពាន និងកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអនឡាញ ការរុកគួនឆាឆៅតាមអនឡាញ និងមធ្យោបាយនានា ដើម្បីស្វែងរកជំនួយ និងការគាំទ្រនៅពេលកូនៗរបស់អ្នកកំពុងប្រឈមមុខនឹងកង្វល់ នៅតាមប្រព័ន្ធអ៊ីនធឺណេត។

លោកស្រី កែវ សុខពិសី បានលើកឡើងថា ឆ្នាំ២០២២ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៃក្រុមប្រឹក្សារាជធានីភ្នំពេញ សម្រេចបានសមិទ្ធផលការងារ យ៉ាងល្អ ។ លោកស្រី គាំទ្រចំពោះផែនការសកម្មភាពការងារទិសដៅ សម្រាប់ការងារឆ្នាំ២០២៣ របស់គណៈកម្មាធិការនេះ ដោយលោកស្រីបញ្ជាក់ថា គណៈកម្មាធិការពិគ្រោះយោបល់ កិច្ចការស្ត្រី និងកុមារ នៃក្រុមប្រឹក្សារាជធានីភ្នំពេញ បានរួមចំណែកជាច្រើន ជាមួយរាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដោយ ធ្វើយ៉ាងណាឲ្យកម្ពុជា សម្រេចបាននូវចក្ខុវិស័យរបស់ខ្លួន ក្នុងប្រែក្លាយប្រទេស ដែលមានចំណូលមធ្យមកំរិតខ្ពស់ នៅឆ្នាំ២០៣០ និងចំណូលខ្ពស់នៅឆ្នាំ ២០៥០ ខាងមុខ។

ក្នុងនោះដែរ លោក ម៉ប់ សារិន បានលើកឡើងថា សម្រាប់ឆ្នាំ២០២២កន្លងមកនេះ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៃក្រុមប្រឹក្សារាជធានីភ្នំពេញ សម្រេចបានសមិទ្ធផលការងារ ល្អប្រសើរ ហើយអ្វីដែលត្រូវបន្តការងារនេះ គឺយើងត្រូវនាំគ្នាពិនិត្យ វាយតម្លៃ ប្រមូលទិន្នន័យរួម ដើម្បីដាក់ទិសដៅការងារ ក្នុងឆ្នាំ២០២៣ អោយកាន់តែល្អប្រសើរថែមទៀត ពិសេសការពង្រឹងតួនាទីស្ត្រី ព្រោះស្ត្រីជាឆ្អឹងខ្នងរបស់សង្គមជាតិ ។ ត្រូវបណ្តុះបណ្តាលស្ត្រី ដែលក្រីក្រនិងងាយរងគ្រោះ ដើម្បីអោយពួកគាត់រកចំណូលចិញ្ចឹមជីវិតបាន កាត់បន្ថយបាននូវភាពក្រីក្រ ទៅតាមគោលនយោបាយ របស់រាជរដ្ឋាភិបាល៕

## ជនសង្ស័យឆបោកការងារនៅកម្ពុជាជាប់ចោទពីបទជួញដូរមនុស្ស

https://www.khmertimeskh.com/501244903// Khmer Times February 24, 2023

នគរបាលក្រុង Taichung បាននិយាយកាលពីថ្ងៃព្រហស្បតិ៍ថា ស្ត្រីអាយុ២៦ ឆ្នាំម្នាក់ដែលត្រូវបានចាប់ខ្លួនកាលពីឆ្នាំមុនដោយសង្ស័យថាបានល្បួងជនជាតិតៃវ៉ាន់មកកម្ពុជា ហើយបង្ខំពួកគេឱ្យចូលរួមក្នុងប្រតិបត្តិការឆបោកត្រូវបានចោទប្រកាន់កាលពីខែមករាពីបទជួញដូរមនុស្ស។ នៅក្នុងសន្និសីទសារព័ត៌មានមួយ អង្គភាពស៊ើបអង្កេតឧក្រិដ្ឋកម្មនៃនាយកដ្ឋាននគរបាលក្រុង Taichung បាននិយាយថា បន្ទាប់ពីការស៊ើបអង្កេតមួយ ខ្លួនបានចាប់ខ្លួនជនសង្ស័យដែលមាននាមត្រកូល Wu កាលពីខែកញ្ញាឆ្នាំមុន នៅអាកាសយានដ្ឋានអន្តរជាតិ Taoyuan នៅពេលដែលជននេះត្រឡប់មកពីប្រទេសកម្ពុជាវិញ។ នៅពេលនោះ សំណើរបស់ព្រះរាជអាជ្ញាដើម្បីឃុំខ្លួន Wu រយៈពេល៤ខែត្រូវបានអនុម័តដោយតុលាការក្រុង Taichung ។

នគរបាលក្រុង Taichung បានចោទប្រកាន់ថា Wu បានសហការជាមួយអង្គការឧក្រិដ្ឋជននៅកម្ពុជា ក្រោមប្រតិបត្តិការក្លែងបន្លំ និងពេស្យាចារជាច្រើន។ ពួកគេបាននិយាយថា Wu បានបង្ហោះការផ្សាយពាណិជ្ជកម្មនៅលើ Facebook និង Instagram ដែលសន្យាផ្តល់ប្រាក់បៀវត្សរ៍ខ្ពស់ដល់ស្ត្រីនៅតៃវ៉ាន់ ដើម្បីធ្វើការនៅក្នុងក្លឹប

កម្សាន្តនៅកម្ពុជា។ នៅពេលដែលស្ត្រីទាំងនោះបានមកដល់ប្រទេសកម្ពុជា លិខិតឆ្លងដែនរបស់ពួកគេត្រូវបានដកហូតដោយយកលេសថាដើម្បីស្នើសុំទិដ្ឋាការ ហើយពួកគេត្រូវបានស្នើសុំឱ្យចុះហត្ថលេខាលើកិច្ចសន្យាការងារដែលកេងប្រវ័ញ្ច។

នាយកដ្ឋាននគរបាលបាននិយាយថា ដាដំបូង ជនរងគ្រោះត្រូវបានគេដាក់ឱ្យធ្វើការនៅក្នុងក្លឹបកម្សាន្ត ប្រសិនបើពួកគេណាម្នាក់បង្ហាញថាចង់ឈប់ពីការងារ ពួកគេនឹងត្រូវបាន "លក់" ទៅសណ្ឋាគារក្នុងតំបន់ និងបង្ខំឱ្យធ្វើការរកស៊ីផ្លូវភេទ។ នាយកដ្ឋានបានបន្តថា Wu ក៏បានល្បួងជនជាតិតៃវ៉ាន់មកកម្ពុជាដោយការផ្សព្វផ្សាយគម្រោង "ការធ្វើដំណើរដោយបង់ប្រាក់" ក្លែងក្លាយ។ នគរបាលបានបន្ថែមថា ពេលមកដល់ប្រទេស លិខិតឆ្លងដែន និងទូរស័ព្ទរបស់ជនរងគ្រោះត្រូវបានរឹបអូសដោយសមាជិកនៃក្រុមឧក្រិដ្ឋជន ហើយពួកគេត្រូវបានបង្ខំឱ្យធ្វើការនៅក្នុងមជ្ឈមណ្ឌលហៅទូរស័ព្ទឆបោក។ នៅក្នុងសន្និសីទសារព័ត៌មាន នគរបាលបាននិយាយថា ពួកគេក៏ទទួលបានវីដេអូក្នុងទូរស័ព្ទដៃ ដែល Wu និងអ្នកផ្សេងទៀត បានឈ្លោះគ្នាជាមួយសមាជិកម្នាក់ទៀតនៃក្រុមឧក្រិដ្ឋជន ដោយបានបង្ខំគាត់ឱ្យស្លៀកខោក្នុងស្ត្រី មុនពេលដែលត្រូវបានគេវាយដំ។ យោងតាមនាយកដ្ឋាន Wu ត្រូវបានចោទប្រកាន់កាលពីខែមករា ពីបទសង្ស័យថាបានរំលោភលើច្បាប់ការពារការជួញដូរមនុស្ស និងបទល្មើសប្រឆាំងនឹងសេរីភាពក្រោមក្រមព្រហ្មទណ្ឌ។ *Focus Taiwan*

# ថ្ងៃទី២៧ ខែ កុម្ភៈ ឆ្នាំ២០២៣

## ឃុំខ្លួននាយករងវិទ្យាល័យខេត្តកំពង់ឆ្នាំងម្នាក់ ពាក់ព័ន្ធនឹងការ ចាប់រំលោភទៅលើកូនសិស្សខ្លួនឯង អាយុ ១៥ ឆ្នាំ បានសម្រេចជាច្រើនដង រួចថតវីដេអូ ដើម្បីទុកគំរាម

https://cen.com.kh/archives/623560.html Posted ByPen Srey NeatFebruary 24, 2023

ខេត្តកំពង់ឆ្នាំង៖ ចៅក្រមស៊ើបសួរ សាលាដំបូងខេត្តកំពង់ឆ្នាំង កាលពីថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០២៣ នេះ បានបង្គាប់ឲ្យឃុំខ្លួន នាយករងវិទ្យាល័យមួយនៅ ខេត្តកំពង់ឆ្នាំងម្នាក់និង បញ្ជូនគាត់ទៅឃុំខ្លួនគាត់ នៅក្នុងពន្ធនាគារ ជាបណ្ដោះអាសន្ន ដើម្បីរង់ចាំចាត់ការតាមផ្លូវច្បាប់ ជាប់ពាក់ព័ន្ធនឹងអំពើ រំលោភសេពសន្ថវៈ និង ផលិតចែកចាយរូបភាពអាសអាភៀសលើកុមារ និងករណី ហិង្សាដោយចេតនា ដោយធ្វើសកម្មភាព ដាក់ថ្នាំសន្លប់ រួចចាប់រំលោភទៅលើជនរងគ្រោះ ត្រូវជាកូនសិស្ស បានសម្រេចជាច្រើនដង រួចថតរូប និងវីដេអូកំពុងរួមភេទ ទុកគំរាមប្រព្រឹត្ត នៅភូមិ សាលាលេខប្រាំ ឃុំ អូរឬស្សី ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង កាលពីអំឡុងឆ្នាំ ២០២២ ដល់ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០២៣ ។

យោងតាមដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នរបស់ លោក នូ ដារ៉ា បានឲ្យដឹងថា ជនត្រូវចោទមានឈ្មោះ ង៉ែត សុខខេង អាយុ ៤១ឆ្នាំ ជា នាយករងសាលាផ្នែកវិន័យ និងបរិស្ថាន នៅវិទ្យាល័យមួយកន្លែង នៅខេត្តកំពង់ឆ្នាំង ។ បើយោងតាមពាក្យបណ្ដឹងរបស់អាណាព្យាបាលរបស់កុមារីរងគ្រោះមាន អាយុ ១៥ ឆ្នាំ បានរៀបរាប់ឲ្យដឹងថា ជនសង្ស័យ បានល្បួងលួងលោមកុមារីជាកូនរបស់គាត់ថា ទៅរៀនបើករថយន្តជាមួយ រួចបែរជាលួចដាក់ថ្នាំចូលក្នុងទឹកឱ្យកូនគាត់ផឹក លុះពេលកូនគាត់សន្លប់បាត់ បាននាំកូនគាត់ទៅរំលោភរហូតបានសម្រេច ជាច្រើនដង និងបានថតរូប និងវីដេអូកំពុងចាប់រំលោភកុមារីរងគ្រោះនោះ ដើម្បីទុកគំរាមកុមារីរងគ្រោះសម្រាប់បំពេញ សេចក្ដីសុខរបស់ខ្លួននៅលើកក្រោយៗទៀត។

ជនត្រូវចោទ ត្រូវតំណាងអយ្យការចោទប្រកាន់ពីបទ " រំលោភសេពសន្ថវៈ និង ផលិត ចែកចាយរូបភាពអាសអាភាសលើកុមារ តាមមាត្រា ៤១ នៃច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើជួញដូរផ្លូវភេទ និងបទហិង្សាដោយចេតនា តាមមាត្រា ២១៧ នៃក្រមព្រហ្មទណ្ឌ ។ ជនត្រូវចោទ ត្រូវបានកម្លាំងសមត្ថកិច្ចនគបាលខេត្ត

កំពង់ឆ្នាំង ចាប់ខ្លួនកាលពីថ្ងៃទី ២១ ខែ កុម្ភៈ ឆ្នាំ ២០២៣ តាមពាក្យបណ្ដឹងអាណាព្យាបាលរបស់ជនរងគ្រោះម្នាក់ ពីបទ រំ.លោភសេព.សន្ថវៈ និង ផលិត ចែកចាយរូបភាពអាសអាភាសលើកុមារ និងករណី ហិង្សាដោយចេតនា ។ បច្ចុប្បន្ននេះ ជនត្រូវចោទ លោក ង៉ែត សុខខេង ត្រូវបានបញ្ជូនទៅឃុំខ្លួននៅពន្ធនាគារ ខេត្តកំពង់ឆ្នាំង ជាបណ្ដោះអាសន្ន ៕ រក្សាសិទ្ធិដោយ ៖ ចន្ទា ភា

## ក្នុងមួយឆ្នាំៗពលករកម្ពុជានៅក្រៅប្រទេសបានផ្ញើប្រាក់មកផ្ទះ ចំនួន ២,៧ប៊ីលានដុល្លារ

https://btv.com.kh/article/20538 2023/02/24 01:19:04 pm

ភ្នំពេញ៖ ឯកឧត្តមបណ្ឌិត អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មានប្រសាសន៍ថា រហូតមកដល់បច្ចុប្បន្ន បានផ្តល់ឱកាសការងារជូនពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសសរុប មានចំនួន ១,៣លាននាក់ ហើយជាមធ្យម ពលករទាំងនោះបានបញ្ជូនប្រាក់បញ្ញើមកក្នុងប្រទេសវិញក្នុងមួយឆ្នាំៗសរុបប្រមាណ ២,៧ប៊ីលានដុល្លារអាម៉េរិក។

ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារ ឆ្នាំ២០២២ និងលើកទិសដៅការងារឆ្នាំ២០២៣ នៃការអនុវត្តផែនយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឆ្នាំ២០១៩-២០២៣ កាលពីរសៀលថ្ងៃទី២៣ ខែកុម្ភៈកន្លងទៅ ឯកឧត្តមរដ្ឋមន្ត្រី បានរៀបរាប់ថា ពលករកម្ពុជាដែលកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសប្រមាណ ១ ,៣លាននាក់នេះ ក្នុងនោះ ប្រទេសថៃ មានចំនួន ១,២លាននាក់, កូរ៉េ ជិត ៥ម៉ឺន, ជប៉ុន ជាង ១ម៉ឺន ៦ពាន់នាក់, ម៉ាឡេស៊ី ជាង ២ម៉ឺន ២ពាន់នាក់, សិង្ហបុរី ៨៥១នាក់, តំបន់រដ្ឋបាលពិសេសហុងកុង ២១៥នាក់ និងអារ៉ាប់ប៊ីសាអូឌីត ១១នាក់។ ឯកឧត្តមរដ្ឋមន្ត្រី ចាត់ទុកថា នេះជាការរួមចំណែកមួយរបស់បងប្អូនពលករនៅប្រទេស ពិតមែនតែពួកគាត់ទៅធ្វើការដើម្បីរកប្រាក់ចំណូលផ្ទាល់ខ្លួន ហើយផ្គត់ផ្គង់ក្នុងគ្រួសារ ប៉ុន្តែបានរួមចំណែកនៅក្នុងការបន្ថែមធនធានមកឲ្យប្រទេស តាមរយៈការផ្ញើរមកឲ្យគ្រួសារ។ ឯកឧត្តម បន្ថែមថា ក្រសួងបានបន្តជំរុញការអនុវត្តគោលនយោបាយស្តីពីទេសន្តរប្រវេសន៍ការងារ សម្រាប់ប្រទេសកម្ពុជាឆ្នាំ២០១៩-២០២៣ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធក្នុងការការពារ និងការលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍បងប្អូនពលករទាំងការទទួលបានកិច្ចគាំពារសង្គមក្នុងពេលបម្រើការងារ និងពេលត្រឡប់មកស្រុកកំណើតវិញ។

ពាក់ព័ន្ធការរស់នៅ និងបំពេញការងាររបស់ពលករកម្ពុជា នៅក្រៅប្រទេសនេះ រដ្ឋាភិបាលកម្ពុជា បានកំពុងបន្តពង្រឹងកិច្ចសហការជាមួយប្រទេសជាដៃគូ រួមមាន ថៃ ម៉ាឡេស៊ី កូរ៉េ ជប៉ុន ហុងកុង សិង្ហបុរី និងប្រទេសមួយចំនួនទៀត ដើម្បីផ្តល់ឱកាសការងារជូនពលករ ក៏ដូចជាការការពារសិទ្ធិ និងផលប្រយោជន៍ពលករដែលកំពុងបម្រើការងារនៅប្រទេសទាំងនោះ បង្កលក្ខណៈសម្បត្តិឱ្យពលករ ឲ្យទទួលបានរបបគាំពារសង្គមទាំងបច្ចុប្បន្ន និងពេលដែលវិលត្រឡប់មកវិញ។ បន្ថែមពីនេះទៀត រដ្ឋាភិបាលកម្ពុជា បាននឹងកំពុងសហការជាមួយបណ្តាប្រទេសអាស៊ានក្នុងការអនុវត្តរបបសោធន ដោយពលករអាចផ្ទេរសមាជិកភាព អតីតភាពការងារ និងការបង់ភាគទានបេឡាសន្តិសុខសង្គមពីប្រទេសមួយទៅប្រទេសមួយ បន្ទាប់ពីចប់កិច្ចសន្យាការងារដើម្បីធ្វើជាមូលដ្ឋានក្នុងការគិតប្រាក់សោធននិវត្តន៍ផងដែរ៕ អត្ថបទ៖ ឈិត ប៉ូរ៉ាវី

## សមត្ថកិច្ចកម្ពុជា
## បន្តទទួលបានបណ្តឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ០១នាក់

https://freshnewsasia.com/index.php/en/localnews/279340-2023-02-24-09-52-24.html 2023-02-24 04:52pm

**(ភ្នំពេញ)៖** គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២២ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិនចំនួន ០១នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្តាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧៦០ករណី មានមនុស្ស ១,៨៩១នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៣១សំណើ និងបិទសំណុំរឿង ២៥០សំណើ (រកឃើញមនុស្ស ១,១២៣នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២៩ករណី៕

## កម្លាំងសមត្ថកិច្ចឆ្មក់បង្ក្រាបទីតាំងម៉ាស្សា កោសជប់មួយកន្លែងលួចបើកបម្រើសេវាកម្មផ្លូវភេទ ឃាត់ខ្លួនមនុស្ស៥នាក់ និងដកហូតវត្ថុតាងមួយចំនួន

https://cen.com.kh/archives/623691.html Posted ByPen Srey NeatFebruary 25, 2023

ភ្នំពេញ ៖ ទីតាំងម៉ាស្សា និងកោសជប់មួយកន្លែងឃីហោ456 ដែលលួចបើកបម្រើសេវាកម្មផ្លូវភេទ ត្រូវបានកម្លាំងនគរបាលជំនាញ ប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន នៃអគ្គស្នងការនគរបាលជាតិ ធ្វើការឆ្មក់បង្ក្រាបដោយនៅក្នុងនោះឃាត់មនុស្សបាន០៥នាក់ រួមទាំងដកហូតវត្ថុតាងពាក់ព័ន្ធមួយចំនួន ។

ក្នុងប្រតិបត្តិការបង្ក្រាបខាងលើនេះដែរ បានធ្វើឡើងកាលពីវេលាម៉ោង ៨យប់ ថ្ងៃសុក្រ ទី ២៤ ខែកុម្ភៈ ឆ្នាំ ២០២៣ ស្ថិតនៅក្បែរស្តុបក្បាលថ្នល់ ស្ថិតនៅតាមបណ្តោយផ្លូវ ២៧១ ក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។ បើយោងតាមប្រភពពីសមត្ថកិច្ចជំនាញដែលចុះឆ្មក់បង្ក្រាបទីតាំងម៉ាស្សា កោសជប់ ឃីហោ ៤៥៦ខាងលើនេះបានឱ្យដឹងថា ទីតាំងនេះត្រូវបានកម្លាំងនគរបាលជំនាញបើកការស្រាវជ្រាវ ជាច្រើនថ្ងៃមកហើយ ទើបដឹងច្បាស់ថា នៅក្នុងនោះមានលួចទទួលបំរើសេវាកម្មផ្លូវភេទ បន្ទាប់មកក៏រាយការណ៍ទៅថ្នាក់លើសុំគោលការណ៍ ដាក់កម្លាំងដើម្បីចុះបង្ក្រាបតែម្តង ដោយនៅក្នុងនោះឃាត់មនុស្សស្រីបានចំនួន០៥នាក់ និងមានមេការម្នាក់ ហើយដកហូតវត្ថុតាងដែលពាក់ព័ន្ធបានមួយចំនួនផងដែរ ។

ក្រោយពីបញ្ចប់ប្រតិបត្តិការណ៍បង្ក្រាបទីតាំងខាងលើនេះរួច ត្រូវបានបិតហាងជាបណ្តោះអាសន្នសិន ។ រីឯមនុស្សស្រីចំនួន០៥នាក់ រួមនឹងវត្ថុតាង ត្រូវបានកម្លាំងនគរបាលជំនាញ ដឹកបញ្ជូនទៅកាន់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន នៃអគ្គស្នងការនគរបាលជាតិ ដើម្បីរង់ចាំអនុវត្តបន្តតាមនីតិវិធី ៕ រក្សាសិទ្ធិដោយ ៖ សា មេត

## កម្ពុជា-ថៃ ផ្សព្វផ្សាយការបង្ក្រាបមជ្ឈមណ្ឌលឆបោក និងការបើកសម្ពោធស្ពានមិត្តភាព

https://www.khmertimeskh.com/501245333//?p=1245333 Khmer Times February 25, 2023

ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេសកម្ពុជា លោក ប្រាក់ សុខុន បានទៅបំពេញទស្សនកិច្ចផ្លូវការនៅប្រទេសថៃ តបតាមការអញ្ជើញរបស់ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងការបរទេស លោក ដន ប្រាមុតវិណៃ (Don Pramudwinai) ពីថ្ងៃទី២៣-២៤ ខែកុម្ភៈ។ ឧបនាយករដ្ឋមន្ត្រីកម្ពុជា បានជួបពិភាក្សាទ្វេភាគីជាមួយសមភាគីថៃ និងចូលជួបសម្តែងការគួរសមជាមួយនាយករដ្ឋមន្ត្រីថៃ ឧត្តមសេនីយ៍ ប្រាយុទ្ធ ចាន់អូចា នៅវិមានរដ្ឋាភិបាល។

ភាគីទាំងពីរបានឯកភាពគ្នាក្នុងការបង្កើនពាណិជ្ជកម្ម និងវិនិយោគទ្វេភាគី ជំរុញការតភ្ជាប់កាន់តែធំ ពង្រឹងកិច្ចសហប្រតិបត្តិការសន្តិសុខ ដើម្បីរក្សាសន្តិភាព និងលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនដែលរស់នៅតាមតំបន់ព្រំដែន។ ភាគីទាំងពីរនឹងបង្កើនកិច្ចសហប្រតិបត្តិការដើម្បីដោះស្រាយឧក្រិដ្ឋកម្មឆ្លងដែន ជាពិសេសបណ្តាញបោកប្រាស់ដែលហៅថា "មជ្ឈមណ្ឌលហៅទូរស័ព្ទ" ហើយសំខាន់បំផុតគឺលើកកម្ពស់មិត្តភាព និងការយោគយល់គ្នាទៅវិញទៅមកនៅកម្រិតប្រជាជនទៅប្រជាជន។

បន្ទាប់ពីបញ្ចប់កិច្ចពិភាក្សា ឧបនាយករដ្ឋមន្ត្រីកម្ពុជា និងថៃ បានអញ្ជើញជាអធិបតីក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់នូវស្ពានមិត្តភាពកម្ពុជា-ថៃ (បានណងអៀន-ស្ទឹងបត់) តភ្ជាប់ខេត្តស្រះកែវ និងខេត្តបន្ទាយមានជ័យ ដើម្បីជំរុញសកម្មភាពពាណិជ្ជកម្ម និងសេដ្ឋកិច្ចនៅតំបន់ព្រំដែន។

ភាគីថៃស្នើឲ្យប្រទេសទាំងពីរបង្កើតគណៈកម្មាធិការមួយដើម្បីបង្ក្រាបការឆបោកមជ្ឈមណ្ឌលហៅទូរស័ព្ទ និងការជួញដូរមនុស្ស។

ប្រទេសទាំងពីរនឹងពន្លឿនការបោសសម្អាតមីនមនុស្សធម៌ នៅក្នុងតំបន់សាកល្បងចំនួនដប់នៅតាមព្រំដែនតាមការព្រមព្រៀងដោយមេដឹកនាំនៃប្រទេសទាំងពីរ។ ការសាងសង់ស្ពានប្រវែង៦២០ម៉ែត្រ ត្រូវបានបញ្ចប់ក្នុងឆ្នាំ ២០១៩ ហើយគ្រឿងបរិក្ខារពាក់ព័ន្ធទាំងអស់នឹងត្រូវបញ្ចប់នៅឆ្នាំ២០២៤។ ប្រហែល ៦០ ភាគរយនៃពាណិជ្ជកម្មថៃ-កម្ពុជា ពឹងផ្អែកលើច្រកព្រំដែនអចិន្ត្រៃយ៍បានក្លងលឹក-ប៉ោយប៉ែតតែមួយ។ ការបើកសម្ពោធស្ពានមិត្តភាពកម្ពុជា-ថៃ នឹងជំរុញឱកាសអាជីវកម្ម និងសេដ្ឋកិច្ចក្នុងតំបន់។ តម្លៃពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសថៃ និងកម្ពុជាមានកំណើនជិត ២៣ ភាគរយ។ ប្រទេសទាំងពីរកំណត់គោលដៅពាណិជ្ជកម្មទ្វេភាគីឱ្យឈានដល់ ១៥ ពាន់លានដុល្លារនៅឆ្នាំ ២០២៥។ TNA

## ជនជាតិហ្វីលីពីន ៨នាក់ផ្សេងទៀត ត្រូវបានជួយសង្គ្រោះពីករណីឆបោកការងារតាមអ៊ីនធឺណិតនៅកម្ពុជា

https://www.khmertimeskh.com/501245462//?p=1245462 Khmer Times February 26, 2023

ជនជាតិហ្វីលីពីន ៨នាក់ ដែលធ្លាក់ខ្លួនជាជនរងគ្រោះដោយសារក្រុមឆបោកការងារតាមអ៊ីនធឺណិតនៅកម្ពុជា ត្រូវបានជួយសង្គ្រោះ និងត្រឡប់ទៅហ្វីលីពីនវិញដោយសុវត្ថិភាពកាលពីថ្ងៃសៅរ៍។ យោងតាមសេចក្តីរាយការណ៍ផ្ទាល់របស់ Jonathan Andal នៃ GTV News Live បានឱ្យដឹងថា ជនរងគ្រោះម្នាក់បាននិយាយថា ពួកគេត្រូវបានផ្តល់ការងារជាភ្នាក់ងារលក់ ឬជំនួយការជដែក។ ទោះបីជាយ៉ាងណាក៏ដោយ ពេលពួកគេមកដល់ស្រុកខ្មែរ ពួកគេត្រូវបង្ខំចិត្តចូលរួមក្នុងរឿងឆបោកស្នេហា។ ប្រសិនបើពួកគេបដិសេធក្នុងការធ្វើការឆបោកជនរងគ្រោះ ប្រាក់

ឈ្នួលរបស់ពួកគេត្រូវបានកាត់បន្ថយ ហើយពួកគេត្រូវបានគំរាមកំហែងដោយប្រើអំពើហិង្សា។ យោងតាមក្រសួងការបរទេស (DFA) នៅមានជនជាតិហ្វីលីពីនចំនួន ៣០នាក់ ដែលត្រូវការការជួយសង្គ្រោះ ពីអាជ្ញាធរកម្ពុជា។

លោក Eduardo Jose De Vega អនុរដ្ឋលេខាធិការក្រសួងការបរទេស បានមានប្រសាសន៍នៅពាក់កណ្ដាលខែកុម្ភៈនៅពេលត្រូវបានសួរនៅក្នុងបទសម្ភាសន៍តាមទូរទស្សន៍ ABS-CBN News Channel ថាតើមានជនរងគ្រោះប៉ុន្មាននាក់ បានធ្លាក់ចូលក្នុងគម្រោងជួញដូរគ្រីបតូ ថា "ខ្ញុំអាចនិយាយបានថាមានជនរងគ្រោះពី៥០ ទៅ ១០០ នាក់ នៅក្នុងប្រទេសមីយ៉ាន់ម៉ា ឡាវ កម្ពុជា"។ កាលពីខែមករាឆ្នាំនេះ ព្រឹទ្ធសមាជិក Risa Hontiveros បានលាតត្រដាងពីការជាប់ពាក់ព័ន្ធពីមន្ត្រីការិយាល័យអន្តោប្រវេសន៍មួយចំនួន ក្នុងការជួញដូរជនជាតិហ្វីលីពីននៅកម្ពុជា ដែលបន្ទាប់មកត្រូវបានបង្ខំឱ្យធ្វើការជា "អ្នកឆបោកគ្រីបតូ" ឱ្យក្រុមម៉ាហ្វីយ៉ាចិន។ អ្នកជ្រើសរើសបុគ្គលិកនៅក្នុងប្រទេសហ្វីលីពីនត្រូវបានគេរាយការណ៍ថាបានបង់ប្រាក់ប្រហែល ៧៥,០០០ ប៉េសូ ទៅ ១០០,០០០ប៉េសូ ដល់មន្ត្រីអន្តោប្រវេសន៍សម្រាប់ជនជាតិហ្វីលីពីនម្នាក់ៗ ដែលពួកគេអនុញ្ញាតឱ្យចេញដោយគ្មានការសាកសួរ៕

# ថ្ងៃទី២៨ ខែ កុម្ភៈ ឆ្នាំ២០២៣

## សមត្ថកិច្ចកម្ពុជា បន្តទទួលបានបណ្តឹង ១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិន ០២នាក់

https://freshnewsasia.com/index.php/en/localnews/279589-2023-02-26-11-17-38.html 2023-02-26 06:17pm

(ភ្នំពេញ)៖ គិតចាប់ពីម៉ោង ៣៖០០ នាថ្ងៃទី២៤ ដល់វេលាម៉ោង ៣៖០០ ថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៣ សមត្ថកិច្ចកម្ពុជាបានទទួលសំណើចំនួន ០១ករណីទៀត ដែលស្នើឱ្យជួយសង្គ្រោះជនជាតិចិនចំនួន ០២នាក់។ នេះបើតាម នាយឧត្តមសេនីយ៍ ខៀវ សុភ័គ រដ្ឋលេខាធិការ និងជាអ្នកនាំពាក្យក្រសួងមហាផ្ទៃ បញ្ជាក់ប្រាប់បណ្ដាញព័ត៌មាន Fresh News។ **បើតាមអ្នកនាំពាក្យ បច្ចុប្បន្នភាពស្រាវជ្រាវ តាមបញ្ជីតាមដាន គិតត្រឹមថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០២៣ រួមមាន៖**

**១៖** សំណើក្នុងបញ្ជីតាមដានរបស់សម្តេចក្រឡាហោម សរុប ៧៦០ករណី មានមនុស្ស ១,៨៩១នាក់

**២៖** បានស្រាវជ្រាវស៊ើបអង្កេតបឋម ៧៣៩សំណើ និងបិទសំណុំរឿង ២៥៦សំណើ (រកឃើញមនុស្ស ១,១១៩នាក់, ឃាត់ខ្លួនជនសង្ស័យ ១២៣នាក់, បិទក្រុមហ៊ុន ៥ទីតាំង, និងផ្អាកអាជីវកម្ម ក៏ដូចជាស្រាវជ្រាវក្រុមហ៊ុន ៤ទីតាំង)

**៣៖** កំពុងបន្តបើកប្រតិបត្តិការស្រាវជ្រាវ និងស៊ើបអង្កេត ២១ករណី៕

## ការស្ទង់មតិ របស់ប្រព័ន្ធសារព័ត៌មាន អាមេរិកបង្ហាញថា តាំងពីឆ្នាំ២០២១មក ការប្រើកម្លាំងពលកម្ម កុមារនៅអាមេរិក បានកើនឡើងយ៉ាងខ្លាំង

https://dap-news.com/international/2023/02/27/315329/ ByPH104Posted on February 27, 2023

**តាមការផ្សាយដំណឹង នៃកាសែតញូយ៉កថៃម កាលពីថ្ងៃទី២៥ខែកុម្ភៈ តាមម៉ោង ក្នុងតំបន់បានឱ្យដឹងថា យោងតាមការស្ទង់មតិមួយ នៃកាសែតញូយ៉កថៃម បានរកឃើញថា ចំនួនកុមារអន្តោប្រវេសន៍ ដែលបានចូលក្នុងប្រទេសអាមេរិក ដោយគ្មានអាណាព្យាបាល មកជាមួយបាន បំបែកកំណត់ត្រាថ្មី ហើយទីបំផុត ការងារដែលកុមារទាំងនេះ បានធ្វើគឺបានល្មើស នឹងច្បាប់ពលកម្មកុមារ ។ ពលកម្មកុមារមាននៅពាស ពេញគ្រប់មុខរបរ នៃរដ្ឋនានា ទូ**

**ទាំងអាមេរិក ក្នុងនោះ ក៏បូករួមការងារអនាម័យដ៏មានហានិភ័យខ្ពស់ នៅទីសត្វឃាតនិងរោងចក្រផលិតគ្រឿង បន្លាស់រថយន្តផងដែរ ។**

តាមការផ្សាយ ដំណឹងឱ្យដឹងថា តាំងពីឆ្នាំ២០២១មក ការប្រើពលកម្មកុមារ នៅអាមេរិក បានកើនឡើងយ៉ាងខ្លាំង នៅឆ្នាំ ២០២២ អនីតិជនគ្មាន អាណាព្យាបាល ដែលបានចូលក្នុងប្រទេសអាមេរិក មានចំនួនឡើងដល់ ១សែន៣ម៉ឺននាក់ តួលេខនេះស្មើនឹង៣ដង នៃរយៈពេល៥ឆ្នាំមុន ហើយតាមការប៉ាន់ប្រមាណ នៅរដូវក្ដៅឆ្នាំនេះ តួលេខនេះនឹងបន្តកើនឡើងថែមទៀត ។ តាមការផ្សាយដំណឹងឱ្យដឹងទៀតថា ប្រព័ន្ធដែលបង្កើតឡើង ក្នុងគោលបំណងការពារកុមារនៅអាមេរិក បានត្រូវបំផ្លាញអស់ហើយ៕

## បញ្ជូនខ្លួនស្ត្រីម្នាក់
## ទៅកាន់តុលាការ ពាក់ព័ន្ធការបង្ក្រាបទីតាំងម៉ាស្សាកោសជប់ បង្កប់សេវាផ្លូវភេទ

http://nokorwatnews.com/archives/970706 27/02/2023

ភ្នំពេញ៖ កម្លាំងនគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ បាន បញ្ជូនខ្លួនស្ត្រីម្នាក់ ទៅកាន់សាលាដំបូងរាជធានីភ្នំពេញ នារសៀលថ្ងៃទី ២៧ ខែកុម្ភៈ ឆ្នាំ ២០២៣ ដើម្បីចាត់ការតាមនីតិវិធី។ សមត្ថកិច្ចមិនទាន់បញ្ជាក់ ពីអត្តសញ្ញាណ ជនសង្ស័យដែលជាស្ត្រីភេទ ដែលបញ្ជូនទៅកាន់សាលាដំបូងនៅឡើយនោះទេ។ សូមបញ្ជាក់ថា ទីតាំងម៉ាស្សា និងកោសជប់មួយកន្លែងយីហោ456 ដែលលួចបើកបម្រើសេវាកម្មផ្លូវភេទ ត្រូវបានកម្លាំងនគរបាលជំនាញប្រឆាំងការជួញដូរមនុស្ស និងការពារអនិតិជន នៃអគ្គស្នងការនគរបាលជាតិធ្វើការឆ្មក់បង្ក្រាបដោយនៅក្នុងនោះឃាត់មនុស្សបាន៥នាក់ដកហូតវត្ថុតាងពាក់ព័ន្ធមួយចំនួន ។

ក្នុងប្រតិបត្តិការបង្ក្រាបខាងលើនេះដែរ បានធ្វើឡើងកាលពីវេលាម៉ោង៨យប់ថ្ងៃសុក្រ ទី២៤ ខែកុម្ភៈ ឆ្នាំ ២០២៣ ស្ថិតនៅក្បែរស្តុបក្បាលថ្នល់ស្ថិតនៅ តាមបណ្តោយផ្លូវ២៧១ ក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ។សមត្ថកិច្ចជំនាញដែលចុះឆ្មក់បង្ក្រាបទីតាំងម៉ាស្សា កោសជប់ យីហោ456 ខាងលើនេះបានឱ្យដឹងថា ទីតាំងនេះត្រូវបានកម្លាំងនគរបាលជំនាញបើកការស្រាវជ្រាវជាច្រើនថ្ងៃមកហើយដែលនៅក្នុងនោះមានលួចទទួលបំរើសេវាកម្មផ្លូវភេទ បន្ទាប់មកក៏រាយការណ៍ទៅថ្នាក់លើសុំគោលការណ៍ដាក់កម្លាំង ដើម្បីចុះបង្ក្រាបតែម្តងដោយនៅក្នុងនោះឃាត់មនុស្សស្រីបានចំនួន០៥នាក់ និងមានមេការម្នាក់ ហើយដកហូតវត្ថុតាងដែលពាក់ព័ន្ធបានមួយចំនួនផងដែរ ។

ក្រោយពីបញ្ចប់ប្រតិបត្តិការបង្ក្រាបទីតាំងខាងលើនេះរួចត្រូវបានបិទហាងជាបណ្តោះអាសន្ន។ រីឯមនុស្សស្រីចំនួន០៥នាក់ រួមនិងវត្ថុតាង ត្រូវបានកម្លាំងនគរបាលជំនាញបញ្ជូនទៅកាន់ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការនគរបាលជាតិ ដើម្បីរង់ចាំអនុវត្តបន្តតាមនីតិវិធី ។ បច្ចុប្បន្នកម្លាំងសមត្ថកិច្ចបើកបញ្ជូនស្ត្រីម្នាក់ទៅកាន់សាលាដំបូងរាជធានាភ្នំពេញ ហើយពេលនេះកំពុងស្ថិតក្នុងដំណាក់កាលតំណាងអយ្យការបើកការស៊ើបសួរនៅឡើយ៕